# ចិញ្ចឹមកូនតាមគន្លងធម៌

ធម្មតាមនុស្សសត្វនៅក្នុងលោកសន្និវាសនេះ តែងតែមាន ប្រុស ស្រី ឈ្មោល ញី ជាគូនឹងគ្នាជារឿងទំនៀមធម្មតាសម្រាប់សព្វសត្វ ។ ប៉ុន្តែចំពោះមនុស្សវិញ ផ្សេងពីសត្វទាំងការរស់នៅទាំងប្រាជ្ញាស្មារតី ព្រោះហេតុនោះ សូមមនុស្សគ្រប់គ្នាកុំយកប្រាជ្ញាស្មារតីរបស់សត្វមកទុកក្នុងសន្តានចិត្តរបស់ខ្លួនឡើយ រហូតធ្វើខ្លួនឯងឲ្យក្លាយទៅជាមនុស្សតិរច្ឆាន គឺខ្លួនជាមនុស្សតែចិត្តសន្តានជាសត្វតិរច្ឆាន ។

ក្នុងលោកយើងនេះ មានមនុស្សច្រើនណាស់ដែលមិនទុកខ្លួនឯងជាមនុស្ស ជាអ្នកមានប្រាជ្ញាស្មារតីដ៏ល្អ ជាងសត្វតិរច្ឆាន ហើយត្រឡប់ទៅជាអ្នកផឹកស៊ី ស្រីញីអូនបងសេពគ្រឿងញៀនមានថ្នាំយ៉ាម៉ា យ៉ាបា ថ្នាំគ្រវីក្បាល និង ហិតកាវជាដើម អ្នកទាំងនេះសុទ្ធតែខ្លួនជាមនុស្សតែសន្តានចិត្តជាសត្វ ។ ប្រសិនបើ យើងជាមនុស្ស



យើងត្រូវធ្វើខ្លួនយើង ជាមនុស្សទាំងកាយ ទាំងចិត្តគំនិត ដោយថាសន្តានចិត្តយើងត្រូវតែជាចិត្តគំនិត អ្នកមានធម៌ មានប្រាជ្ញាស្មារតីមានសតិសម្បជញ្ញៈ ជៀសវាងអំពើទុច្ចរិតមានអបាយមុខជាដើម ។ បើយើងធ្វើដូច្នេះទើបសម ខ្លួនជាមនុស្ស សន្តានចិត្តក៏ជាមនុស្សដែរ ។ ចំណងជើងខាងដើមមានឈ្មោះថា"ចិញ្ចឹមកូនតាមគន្លងធម៌" ដែលមានអត្ថន័យថា ឪពុកម្តាយធ្វើយ៉ាងណាទើបឈ្មោះថា ជាអ្នកចិញ្ចឹមកូនឲ្យក្លាយទៅជាកូនល្អទៅជាមនុស្សល្អក្នុងសង្គម ។ ជារឿងចាំបាច់ណាស់ សម្រាប់ឪពុកម្តាយដែលជាមេគ្រួសារ ជាមេផ្ទះដ៏ច្លាតវៃ ត្រូវចិញ្ចឹមកូនតាមគន្លងធម៌នោះ ។ ប្រសិនបើមិនចិញ្ចឹមកូនឲ្យត្រូវតាមធម៌ទេនោះ កូននឹងក្លាយទៅជាមនុស្សពាល អាវ៉ាសែ ជើងកាងមិនខានឡើយ ។ម្យ៉ាងទៀត កូនមិនមែនមិនសំខាន់ទេ សម្រាប់ឪពុកម្តាយគឺកូនជាមនុស្សសំខាន់បំផុតសម្រាប់ឪពុកម្តាយ ក្នុងលោកយើងនេះ ព្រោះហេតុនោះ ឪពុកម្តាយត្រូវសិក្សាពីវិធីអប់រំចិញ្ចឹមកូនឲ្យត្រឹមត្រូវតាមគន្លងធម៌ជាលំដាប់ ដូចតទៅនេះ ៖

# ១.ត្រៀមខ្លួនធ្វើជាប្តីប្រពន្ធគេ

“អ្នកដែលចូលទៅកាន់សមរភូមិគឺសង្គ្រាម ត្រូវត្រៀមអាវុធ ដាវ លំពែង ជាដើម យ៉ាងណាមិញ បុរស ស្ត្រី ដែលត្រូវធ្វើជាប្តីគេ និងប្រពន្ធគេ ត្រូវត្រៀមខ្លួនក៏យ៉ាងនោះដែរ” ។

ធម្មតា បុរស ស្ត្រី កាលដល់វ័យពេញកម្លោះក្រមុំ ហើយ តែង តែដល់នូវភាពជាអ្នកមាននូវសេចក្តីស្រឡាញ់ស្នេហា ចំពោះអ្នកណាម្នាក់មិនខាន តែសូមសេចក្តីស្នេហានោះ កុំឲ្យហួសព្រំដែនប្រពៃណីឡើយ ។ រឿងសេចក្តីស្រឡាញ់កើតក្នុងចិត្ត មិនមានអ្វីអាចរារាំងបានទេ ព្រោះជាលោកិយវិស័យសម្រាប់មនុស្សសត្វដែលនៅមានរាគៈ ។ តែបើចិត្តកើតមានសេចក្តីស្រឡាញ់ចំពោះអ្នកណាម្នាក់ហើយ មិនត្រូវប្រព្រឹត្តកន្លងទាំងកាយ វាចា ដែលជាហេតុខុសចាកប្រពៃណីឡើយ ។ បើសេចក្តីស្រឡាញ់កើតឡើងខ្លាំង ត្រូវប្រាប់ឪពុកម្តាយឲ្យចូលស្តីដណ្តឹងតាមផ្លូវមេបាយ៉ាងត្រឹមត្រូវ ។ តែមុនចូលស្តីដណ្តឹងគេត្រូវគិត



មើលខ្លួនយើងសិនថាតើខ្លួនយើងមានសមត្ថភាពគ្រប់គ្រាន់អាចធ្វើជាប្តីគេឪពុកគេបានឬនៅ ? បើមិនទាន់មានសមត្ថភាពទេ យើងត្រូវបង្អង់សិនមិនត្រូវចូលស្តីដណ្តឹងគេទាំងប្រញាប់ប្រញាល់នោះទេ ។ តើសមត្ថភាពនោះយ៉ាងណា ទើបសមធ្វើជាប្តីគេ? សមត្ថភាពទាំងនោះ គឺវិជ្ជាសម្បត្តិ ចរិយាសម្បត្តិ ។ សម្បត្តិទាំងពីរប្រការនេះ ជាសម្បត្តិធ្វើឲ្យយើងគ្រប់គ្រងគ្រួសារបានសេចក្តីសុខចម្រើននិងមានសុភមង្គលទៅអនាគត ។

**វិជ្ជាសម្បត្តិ** ជាសម្បត្តិមួយដ៏វិសេសវិសាលបំផុតសម្រាប់យើង បើយើងមិនទាន់មានទេ យើងត្រូវស្វែងរកសម្បត្តិនេះ មកទុកក្នុងខ្លួនយើងឲ្យបាន ដោយត្រូវសិក្សាបន្ថែមនូវជំនាញផ្សេងៗតាមកាលសម័យឲ្យបានច្បាស់ លាស់ ដូចជាភាសាអង់គ្លេស ថៃ ចិន ជប៉ុន កុំព្យូទ័រ ជាដើម។ បើសិក្សាមុខវិជ្ជាណា មុខវិជ្ជានោះឲ្យច្បាស់លាស់ ជំនាញចេះចាំប្រាកដអាចប្រើការបានមិនមានសល់ចន្លោះ ហើយការយកចំណេះមកប្រើនោះ គឺជាសមត្ថភាពផ្ទាល់ខ្លួនរបស់យើង ។ ប្រសិនបើចេះច្រើនផ្នែក តែមិនច្បាស់លាស់ណាមួយ ក៏ប្រើការមិនកើតឡើយ។ ព្រោះហេតុ នោះ

បើយើងគោងយកមុខវិជ្ជាណាមួយ ត្រូវយកមុខវិជ្ជានោះឲ្យច្បាស់លាស់ដូចព្រះសម្ពុទ្ធទ្រង់ត្រាស់ថា[១] **“សិល្បៈគឺសេចក្តីឆ្លៀវឆ្លាសក្នុងហត្ថកម្មរបស់អ្នកបួសនិងគ្រហស្ថ ជាមង្គលដ៏ឧត្តម”** ព្រះសម្ពុទ្ធទ្រង់សំដៅដល់សិល្បសាស្ត្រវិជ្ជាដែលបុគ្គលចេះស្ទាត់ប្រាកដប្រជានេះជាមង្គលដ៏ឧត្តមសម្រាប់បុរសស្ត្រីក្នុងលោក ។

ដូច្នេះ វិជ្ជាសម្បត្តិ ជាគុណធម៌សំខាន់ណាស់សម្រាប់មនុស្សប្រុសស្រីដែលរស់នៅក្នុងលោកសន្និវាសនេះ ព្រោះថាបើយើងខ្វះវិជ្ជាសម្បត្តិហើយ យើងមិនអាចសាងសុភមង្គលឲ្យដល់ក្រុមគ្រួសាររបស់យើងបានឡើយ ។ យើងត្រូវដឹងថា“ **បុគ្គលល្ងង់ខ្លៅជាសត្រូវខ្លួនឯងនឹងអ្នកដទៃ** ” ។

យើងត្រូវសិក្សាមើលគម្ពីរលោកនីតិ ដែលអ្នកប្រាជ្ញបានពន្យល់ថា ៖

សិប្បធនំ ធនំ នត្ថិ សិប្បំ ចោរា ន គណ្ហន្តិ

[១] សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ: ៥២/៤



ឥធ លោកេ សិប្បំ មិត្តំ បរលោកេ សុខាវហំ ។
*មានទ្រព្យមិនស្មើមានវិជ្ជា វិជ្ជាចោរលួចយកពុំបាន*
*វិជ្ជាទុកជាមិត្តសន្តាន ក្សាន្តក្នុងឥធលោកយោគបរលោក ។*

អប្បកំ នាតិមញ្ញេយ្យ ចិត្តេសុ តំ និដ្ឋាបេយ្យ
វម្មិកូទកពិន្ទុវ ចិរេន បរិបូរតិ ។
*កុំមើលងាយថាបញ្ញាតិច រៀនទៅក្រែងភ្លេចមិនចម្រើន*
*សុតម័យបញ្ញាបើក្រវើន យូរទៅគង់ច្រើនពេញហឫទ័យ ។*
*ដូចក្អមតម្កល់លើដំបូក ភ្លៀងដោកៗអចិន្ត្រៃយ៍*
*តំណក់តក់ៗតែរាល់ថ្ងៃ អាស្រ័យយូរទៅគង់ពេញបាន ។*

ខុទ្ទោតិនាតិមញ្ញេយ្យ វិជ្ជំវា សិប្បមថវា
ឯកំ បិ បរិយោទាតំ ជីវិតកប្បការណំ
*កុំមើលងាយមន្តសិល្បសាស្ត្រា គិតថាតិចតួចក្រែងមិនស្រេច*
*វិជ្ជាមួយមែនបើមិនភ្លេច គង់នឹងសម្រេចប្រយោជន៍បាន*
*ចេះមួយចេះពីរតែឲ្យស្ទាត់ ប្រកបប្រាកដអ្នកចំណាន*

*ជាហេតុចិញ្ចឹមជីវិតបាន　　　សន្តានដួលពីងពំនឹងអើយ*

សេលេសេលេ ន មណិកំ　　　គជេគជេ ន មុត្តកំ

វនេ វនេ ន ចន្ទនំ　　　ឋានេ ឋានេ ន បណ្ឌិតំ ។

*កែវមណីមិនមានសព្វថ្មភ្នំ　　គជៈកុម្ភមិនមានសព្វគជេនជ័យ*

*ជាតិខ្លឹមចន្ទន៍មិនមានកើតសព្វព្រៃ　ប្រាជ្ញប្រពៃមិនមានកើតសព្វស្ថាន។*

បណ្ឌិតោ សុតសម្បន្នោ　　　យត្ថ អត្ថីតិ ចេ សុតោ

មហុស្សាហេន តំ ឋានំ　　　គន្តព្វោវ សុតេសិនា ។

*បើឮថាមានអ្នកប្រាជ្ញច្បាស់　　កបសូត្រសិល្បសាស្ត្រក្នុងទីណា*

*អ្នកស្វែងរៀនសូត្រខំឧស្សាហ៍　　យាត្រាចូលទៅទីនោះហោង ។*

សិនេ សិប្បំ សិនេ ធនំ　　　សិនេ បព្វតមារុយ្ហំ

សិនេ កាមស្ស កោធស្ស　　　សិនេ បញ្ច គុណោ ឥមេ ។

*រៀនសិល្បសាស្ត្រកុំរាន់បន្ទាន់ញាប់　ស្វែងរកទ្រព្យសន្សំកុំខំខ្លាំង*

*ឡើងភ្នំសន្សឹមកុំប្រណាំង　　　សេពកាមតាមកម្លាំងតិចវា៉ា ។*



ចំណែកសម្បត្តិមួយទៀតគឺចរិយាសម្បត្តិក៏ជាសម្បត្តិសំខាន់មួយទៀតសម្រាប់បុរស ស្ត្រីក្នុងលោកយើងនេះផងដែរ ។ ចរិយាមានន័យថាប្រព្រឹត្តត្រឹមត្រូវ ធ្វើខ្លួនឲ្យជាមនុស្សល្អ សុភាពរាបសា ។ មនុស្សដែលឈ្មោះថា មានចរិយាសម្បត្តិគឺ ជាអ្នកវៀរចាកអបាយមុខ[២] ពោលគឺប្រធាននៃសេចក្តីវិនាស៤ប្រការគឺ ៖

**១. លេងស្រី**

**២. លេងស្រា**

**៣. លេងល្បែង**

**៤.សេពគប់បាបមិត្ត　　ៗ**

យើងត្រូវដឹងថា ការលេងស្រី វាជាគ្រោះថ្នាក់មួយសម្រាប់យើងគ្រប់គ្នា ដែលជាទោសអាចបណ្តាលឲ្យ មានជម្ងឺកាមរោគ មានជម្ងឺអេដស៏ ស្វាយ ជាដើម រហូតដល់ខ្លួនក្សិណក្ស័យចាកប្រពន្ធកូន

---

[២] សុត្តន្ត. ខុទ្ទក. សុត្តនិបាត ៥៤/៣៩

ជាទីស្រឡាញ់ ។ បើមិនមានជម្ងឺធ្ងន់ធ្ងរទេ ក៏ជាហេតុនាំឱ្យញៀនញ៉ាមត្រេកត្រអាលដោយរាគៈ ត្រូវកាមដឹកមុខហ៊ានរហូតចាប់រំលោភកុមារីមិនទាន់គ្រប់អាយុ ឬចាប់រំលោភសេពសន្ថវៈ ទៅលើប្រពន្ធកូនអ្នកដទៃក៏អាចទៅបាន រហូតដល់ថ្នាក់ត្រូវជាប់គុក ជាប់ខ្នោះច្រវាក់យូរខែ យូរឆ្នាំទៅតាមទង្វើដែលខ្លួនបានធ្វើ ។ នេះដោយសារការលេងស្រី វាជាហេតុនាំឱ្យរឿងញៀនញ៉ាមក្នុងកាមារម្មណ៍ ។ បើយើងមិនលេងស្រីនោះ តើរឿងហេតុទាំងអស់នោះកើតឡើងបានដែរឬទេ? យើងអាចយល់បាន ហើយឆ្លើយយ៉ាងងាយថា រឿងនោះមិនអាចកើតឡើងបានទាល់តែសោះ ព្រោះយើងបានប្រព្រឹត្តចរិយាដ៏ល្អគឺការមិនលេងស្រីនោះឯង ។

ការលេងស្រាក៏ជាទោសមួយផងដែរ សម្រាប់បុរស ស្ត្រីក្នុងលោកយើងនេះ ដោយថាមនុស្សពេញចិត្តស្រា យកស្រាជាទីពឹងឃើញថា មានតែស្រាទេ ដែលជាមិត្តភក្តិជានិច្ចកាលគ្រប់ពេល មនុស្សនោះឈ្មោះថា ខ្វះសតិ បាត់បង់ស្មារតី និងបញ្ញាយកទោសជា



គុណ យកគុណជាទោស ។ កាលណាសុរាជ្រាបចូលដល់ពោះភ្លាម ឃើញថា អញអស្ចារ្យជាងគេ ខ្លាំងជាងគេ ក្លាយទៅជាអ្នកក្លាហានខាងផ្នែកកាប់ចាក់ ទាត់ធាក់កាចឃោរឃៅយង់ឃ្នង ហ៊ានប្លន់ ហ៊ានលួច ហ៊ានសម្លាប់ ហ៊ានចាប់រំលោភ សូម្បីឪពុកម្តាយរបស់ខ្លួនក៏ហ៊ានគម្រាមកំហែង ប្រមាថ ឬហ៊ានសម្លាប់គាត់ទៀតផង ។ មនុស្សដែលមិនមានសតិបញ្ញាស្មារតីគ្រប់គ្រងខ្លួន ឈ្មោះថា ជាមនុស្សវិកលចរិតឬហៅថាមនុស្សវិបល្លាសខ្វះសតិក្នុងខ្លួន ។ ព្រោះហេតុនោះ មនុស្សយើងត្រូវវៀរចាកការលេងសុរាឲ្យបានជាដាច់ខាត ទើបឈ្មោះថា ជាមនុស្សមានចរិយាសម្បត្តិល្អ ។

ការលេងល្បែងភ្នាល់ក៏ជាទោសត្រូវវៀរចាកជាដាច់ខាតផងដែរ ព្រោះថា មនុស្សខ្លះដែលងប់វង្វេងក្នុងវង់ល្បែងភ្លេចអស់ពីការសិក្សារៀនសូត្រ ការកសាងអំពើល្អ ជាពិសេសខ្លួនបានបង្ហាញខ្លួនថា ជាមនុស្សមិនត្រឹមត្រូវ ។ ម្យ៉ាងទៀតអ្នកលេងល្បែងរមែងមិនជាទីសណ្តាប់ ជឿទុកចិត្តនៃអ្នកដទៃឡើយ ពេលនិយាយ

សំដីសាបដូចជាទឹក របហូតដល់ចូលទៅកាន់ទីជំនុំចំណោមខ្លួនមិនជាអ្នកក្លាហាន ។ ល្បែងបៀរ ល្បែងស៊ីសង មានការចាក់បាល់ជាដើមនេះសុទ្ធតែជាមេនៃសេចក្តីវិនាសសម្រាប់យើង ។ ព្រោះហេតុនោះ មនុស្សដែលត្រូវជាប្តីប្រពន្ធគេត្រូវវៀរចាកឱ្យបានទូវល្បែងភ្នាល់គ្រប់ប្រការ កុំលូតលាន់ឱ្យសោះ ។

ការសេពគប់នូវមិត្តក៏មានសារសំខាន់ផងដែរ នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ បើមិត្តប្រកបដោយធម៌(មិត្តសុចរិត)នោះនឹងនាំយើងទៅកាន់សេចក្តីសុខ ប៉ុន្តែបើមិត្តនោះប្រកបដោយអធម៌(មិត្តទុច្ចរិត)នោះ នឹងនាំយើងទៅកាន់សេចក្តីវិនាសជាមិនខាន។

បាបមិត្តមានន័យថា មិត្តអាក្រក់មិត្តនាំឲ្យយើងវិនាសចាកគុណធម៌។យើងត្រូវដឹងថា[៣]មិត្តប្លមមានចំណុចធំៗ៤គឺ ៖

១.មនុស្សដែលគិតយកតែប្រយោជន៍ខ្លួន

២.មនុស្សល្អតែសំដី

[៣] សុត្តន្ត.ទីឃនិកាយ.បាដិកវគ្គ.១៩/៧៨,



៣.មនុស្សដែលនិយាយចាក់បណ្តោយឲ្យគាប់ចិត្ត

៤.មនុស្សជាសំឡាញ់ក្នុងផ្លូវវិនាស ។

នេះជាគោលធំៗរបស់បាបមិត្ត ដែលយើងអាចស្គាល់បានតែយើងក៏ត្រូវដឹងថា យើងអាចស្គាល់បានដោយស្ថាន ៤ យ៉ាងទៀតរបស់មិត្តដែលគិតយកតែប្រយោជនខ្លួនគឺ ៖

១.មិត្តគិតតែប្រយោជន៍ខ្លួន

២.មិត្តប្រាថ្នាយករបស់ច្រើនដោយឲ្យរបស់តិចតួច

៣.ទាល់តែមានភ័យទើបជួយកិច្ចការរបស់មិត្ត

៤.សេពគប់មិត្តព្រោះហេតុតែប្រយោជន៍ ។

**មិត្តល្អតែសំដីត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងគឺ៖**

១.មិត្តទទួលរាក់ទាក់ដោយរបស់ដែលកន្លងហើយ

២.ទទួលរាក់ទាក់ដោយរបស់មិនទាន់មានមក

៣.សង្គ្រោះដោយអំពើឥតប្រយោជន៍

៤.កាលកិច្ចទាំងឡាយកើតឡើងភ្លាមៗក៏សំដែងអាងរបស់ខូចខាត ។

**មិត្តនិយាយចាក់បណ្តោយឱ្យគាប់ចិត្តត្រូវស្គាល់ដោយស្ថាន៤ យ៉ាងគឺ៖**

១.បើមិត្តធ្វើអំពើអាក្រក់ក៏យល់ព្រមតាម

២.មិត្តធ្វើអំពើល្អក៏យល់ព្រមតាម

៣.ពណ៌នាគុណមិត្តតែចំពោះមុខ

៤.ពោលទោសមិត្តតែទីកំបាំងមុខ

**មនុស្សសំឡាញ់ក្នុងផ្លូវវិនាសយើងត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងគឺ ៖**

១.សំឡាញ់នាំយើងទៅផឹកស៊ីស្រីញីអូនបង

២.នាំយើងដើរលេងយប់ព្រលប់ខុសកាលវេលា

៣.នាំយើងទៅមើលកុនវីឌីអូ មហោស្រព ខារ៉ាអូខេ

៤.នាំយើងទៅលេងភ្នាល់ ។



នេះជាកំពូលបាបមិត្ត ដែលនាំឲ្យយើងវិនាសហិនហោចចាកគុណធម៌ចាកអំពើល្អ។ ព្រោះអាស្រ័យបាបមិត្ត មនុស្សយើងសព្វថ្ងៃ ក្លាយទៅជាមនុស្សជើងកាង អ្នកលេងប្រចាំស្រុកភូមិនីមួយៗ មិនហ៊ានថ្លងពីភូមិមួយទៅភូមិមួយឡើយ មានទាំងបក្សពួកបងធំបងតូចស្ទើរពេញប្រទេសគួរឲ្យភ័យខ្លាចណាស់ គឺថាបាបមិត្តនាំយើងជក់គ្រឿងញៀនមាន យ៉ាម៉ា (ថ្នាំសេះ) យ៉ាបា(ថ្នាំឆ្កួត) ថ្នាំគ្រវីក្បាល និងហិតការជាដើម បាបមិត្តនាំយើងផឹកគឺយើងជាអ្នកផឹក បាបមិត្តនាំយើងលេងល្បែងគឺយើងជាអ្នកលេងល្បែង បាបមិត្តនាំយើងលេងស្រីគឺយើងក្លាយជាអ្នកញៀនញ៉ាមក្នុងកាមគុណ នេះឯងសុទ្ធតែទោសនៃការសេពគប់បាបមិត្ត ។ ព្រោះហេតុនោះ បុរសក្នុងលោកដែលបម្រុងខ្លួនធ្វើជាប្តីគេ ត្រូវវៀរចាកអបាយមុខ[៤] ទាំង៤នេះ គឺ ៖

**១.ឥត្ថីធុត្តោ** អ្នកលេងស្រី

**២.សុរាធុត្តោ** អ្នកលេងស្រា

---

[៤] សុត្តន្តបិដក អង្គុត្តរនិកាយ អដ្ឋកនិបាត សទ្ធានវគ្គ ៤៨/២៤៧

**៣.អក្ខធុត្តោ** អ្នកលេងល្បែង

**៤.បាបមិត្តោ** អ្នកសេពគប់បាបមិត្ត

ទាំងបួនប្រការនេះ យើងត្រូវលះបង់ឲ្យបានទើបសមធ្វើជាប្តីគេ សមជាឪពុកគេ និងសមជាមេគ្រួសារដ៏ល្អ ។

ចំណែកស្ត្រីបម្រុងធ្វើជាប្រពន្ធគេយ៉ាងម៉េចដែរ?

បញ្ហានេះយើងជាស្ត្រីត្រូវដឹងថា ខ្លួនយើងត្រូវតែជាអ្នកមានវិជ្ជាសម្បត្តិ និង ចរិយាសម្បត្តិដូចបុរសដែរ ។ ព្រោះថា ការយើងមិនមានចំណេះវិជ្ជាក្នុងខ្លួន ជាមនុស្សល្ងង់ខ្លៅ សូម្បីយើងមានចរិយាសម្បត្តិល្អយ៉ាងណា ក៏នៅមិនជាទីពេញចិត្តរបស់ស្វាមីដែរ ។ ស្វាមីយើងអាចគិតថា ប្រពន្ធល្ងង់ ធ្វើអ្វីក៏ធ្វើមិនកើត ហើយអាចបង្កើតជម្លោះរកាំរកោសគ្នាក្នុងគ្រួសារមិនខាន ។ ព្រោះហេតុនោះយើងជាស្ត្រីត្រូវតែស្វែងរកចំណេះវិជ្ជាមកទុកក្នុងខ្លួនឱ្យមានជាចាំបាច់ តែបើមិនបានខ្ពង់ខ្ពស់ទេ ក៏ត្រូវចេះល្មាក់ល្មមក្នុងគ្រួសារនូវកិច្ចការងារក្នុងផ្ទះ ។ ប្រពៃណីវប្បធម៌ខ្មែរយើង បានលើកតម្កើងស្ត្រីភេទ



ក្នុងឋានៈខ្ពស់ រហូតអាចនិយាយថា គ្រួសារមួយអាចចម្រើនរុងរឿងទៅបានដោយសារស្ត្រី ដូចពាក្យសុភាសិតខ្មែរថា"**សំណាបយោងដីស្រីយោងប្រុស**"ជាដើម ។ ម្យ៉ាងទៀត រឿងព្រេងខ្មែរមួយមានឈ្មោះថា"មៀយើង[៥] " បានសំដែងពីលក្ខណៈស្ត្រីពីរនាក់ ម្នាក់ជាស្រីកញ្ជ្រោះផ្ទះ ម្នាក់ទៀតជាស្រីឈ្លាសច្លាតក្នុងកិច្ចការងារដល់ប្តី ។ រឿងនេះបញ្ជាក់ឲ្យឃើញថា សូម្បីមាណពនោះមិនឈ្លាសក្នុងការងារក៏ដោយ ឲ្យតែស្ត្រីជាអ្នកឈ្លាសអាចជួយគ្រួសាររបស់ខ្លួនឲ្យថ្កុំថ្កើងរុងរឿងបាន ។ ម្យ៉ាងទៀត ក្នុងប្រវត្តិសាស្ត្រខ្មែរយើងមានពោលពីប្រវត្តិរបស់ព្រះនាងឥន្ទ្រទេវី ជាមហេសីរបស់ព្រះបាទជ័យ_វរ្ម័នទី៧ ព្រះនាងជាសាស្ត្រាចារ្យភាសាបាលី_សំស្ក្រឹត ឈ្លាសក្នុងវិធីដឹកនាំប្រទេស រហូតមានវិទ្យាល័យធំៗបីក្នុងសម័យកាលនោះ ហើយព្រះនាងជាមគ្គុទ្ទេសក៍ដ៏ឆ្នើមក្នុងការដឹកនាំប្រទេស ជាមួយព្រះបាទជ័យវរ្ម័នទី៧ ។ ទោះបីព្រះបាទជ័យវរ្ម័នទី៧ ទ្រង់ព្រួយព្រះ

---

[៥] មៀ នេះមកពីភាសាសៀមមានន័យថាប្រពន្ធ ពាក្យសៀមសរសេរថា *เมีย* ។

ទ័យសង្រេងសង្រៃកើតទុក្ខក្នុងការដឹកនាំប្រទេស ការធ្វើសង្គ្រាម ព្រះនាងមានឧបាយកលជួយរំដោះទុក្ខព្រះរាជាឲ្យរួចផុតបាន ។ យ៉ាងណា ស្ត្រីគ្រប់រូបត្រូវតែមានវិជ្ជាសម្បត្តិនិងចរិយាសម្បត្តិគ្រប់គ្រាន់ ទើបអាចកសាងគ្រួសារឱ្យមានសុខដុមរមនា និង ចូលរួមវិភាគទានកសាងសង្គមជាតិឱ្យបានរុងរឿងថ្កុំថ្កើងផងដែរ ហើយអាចកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារមួយយ៉ាងធំ ។ សូម្បីថា រូបសម្បត្តិ យើងស្អាតតាំងពីសក់ មុខ មាត់ រាងកាយ មិនទាស់សោះក៏ដោយ បើគំនិតមារយាទមិនកើតទេ ក៏មិនអាចដឹកនាំក្រុមគ្រួសារឲ្យចម្រើនរុងរឿងបានឡើយ ។

តើយើងត្រូវធ្វើភរិយាប្រភេទណា ? ក្នុងភរិយាទាំងប្រាំពីរ ដែលព្រះពុទ្ធទ្រង់សំដែង[៦] គឺ ៖

**១. វធកសមាភរិយា** *ភរិយាត្រេកអរបុរសដទៃ (មានសហាយ) មើលងាយប្តី ខ្វល់ខ្វាយសម្លាប់ប្តី។*

---

[៦] *សុត្តន្ត. អង្គុត្តរ.សត្តកនិបាត អព្យាកតវគ្គ ៤៧/១៦៨*



**២. ចោរីសមាភរិយា** *ភរិយាលួចទ្រព្យពីផ្ទះ(ទ្រព្យដែលប្តី រកបានមកហើយ លួចយកទៅផឹកស្រាលេងល្បែងចាយវាយផ្តេសផ្តាស) ។*

**៣.អយ្យសមាភរិយា** *ភរិយាធ្វើការកៀបសង្កត់ប្តី ឲ្យនៅក្នុងអំណាចខ្លួន (ភរិយាខ្ជិលច្រអូស ស៊ីច្រើន រឹងរូស កាចពោលពាក្យអាក្រក់ ប្រព្រឹត្តគ្របសង្កត់នូវប្តី ដែលមានព្យាយាមប្រឹងប្រែង) ។*

**៤.មាតុសមាភរិយា** *ភរិយាចេះរក្សាប្តីដូចមាតារក្សាកូន កូន(ភរិយាមានសេចក្តីអនុគ្រោះនូវប្រយោជន៍ សព្វ ។ កាលហើយរក្សានូវទ្រព្យដែលប្តីបានមកអំពីទីផ្សេងៗ) ។*

**៥.ភគិនិសមាភរិយា** *ភរិយាគោរពប្តីដូចប្អូនស្រីគោរពបងប្រុស (ភរិយាមានសេចក្តីអៀនខ្មាសប្រព្រឹត្តទៅតាមអំណាចនៃភស្តា) ។*

**៦.សខីសមាភរិយា** ភរិយាដូចសម្លាញ់ (ភរិយាបាន ឃើញនូវប្ដីហើយក៏រីករាយ ដូចសម្លាញ់បានឃើញសម្លាញ់ដែលមក អស់កាលយូរ ស្ត្រីនោះ បរិបូណ៌ដោយត្រកូលមានសីលធម៌ជាស្ត្រី មានវត្តប្រតិបត្តិក្នុងប្ដី )។

**៧.ទាសីសមាភរិយា** ភរិយាដូចអ្នកបម្រើ(ភរិយាដែលប្ដី ជេរវាយ គម្រាមដោយដំបង មិនមានចិត្តប្រទូស្តវិញបេះអត់សង្កត់ ចិត្ត មិនក្រោធខឹងនឹងប្ដី ប្រព្រឹត្តទៅតាមអំណាចប្ដី ) ។

នេះជាភរិយាទាំងប្រាំពីរពួកក្នុងលោក តើក្នុងនាមយើងជា ស្ត្រីត្រូវជ្រើសរើសខ្លួនឯងឲ្យទៅជាភរិយាទីប៉ុន្មានសម្រាប់គ្រួសារយើង ។

ភរិយាទាំងប្រាំពីរនេះព្រះករុណាព្រះបាទសម្ដេចព្រះហរិរក្ស-រាមាឥស្សរាធិបតី ព្រះអង្គឌួង ព្រះបរមកោដ្ឋ ទ្រង់និពន្ធទុកថា[៧] ៖

មួយសោតព្រះពុទ្ធ ទេសនាចំហុត **ចារិភរិយា**

[៧] ច្បាប់ស្រី ទំព័រ ២៦



មានប្រាំពីរពួក ប្អូននោះចិត្តជា បីនោះមោហា
ចិត្តខុចងាយដាយ៖

១_ឯប្រពន្ធជា **ឯក ឈ្មោះមាតា** ភរិយាដូចម្ដាយ
ឈឺថ្កាលកូនខ្លួន វែងសួនមិនណាយ មិននឹករសាយ
ចិត្តចាំអាណិត។

កូនទុក្ខទោសម្ដេច ខ្សត់ក្រច្រើនតិច ខឹងខុសខូចចិត្ត
ព្រាត់ប្រាស់យូរលង់ ពុំបង់បែកចិត្ត គង់ចាំចិត្តគិត
ឈឺថ្កាលកូនឈ្មោះ។

ប្រពន្ធណាចាប់ ឈឺថ្កាលប្ដីខ្ជាប់ ចិត្តចាំកាន់កោះ
ដូចម្ដាយស្រឡាញ់ កូនពេញពីពោះ ហៅប្រពន្ធនោះ
ថ្លៃឥតផ្ទឹមដល់ ។

២_ប្រពន្ធជាទ្វី ឈ្មោះហៅ**ទាសី_** ភរិយាដូចកល
ខ្ញុំនឹងអម្ចាស់ ប្រើណាស់ខ្វាយខ្វល់ អាចអត់ទប់ទល់

ទម្ងន់បម្រើ។

មិនមានទំនេរ ទោះម្ចាស់វាយជេរ អត់ឱនសារពើ
តាមតែបង្គាប់ ប្រញាប់ចង់ធ្វើ ចិត្តពុំសើរើ
ចៀសវាងក្រោធា។

ប្រពន្ធណាអត់ ឱនអង្គអំណត់ ខ្លាចប្ដីអាត្មា
ដូចខ្ញុំនឹងម្ចាស់ ខ្លាចណាស់ធានា ប្រពន្ធនោះជា
ប្រសើរសុខសួន។

៣_ប្រពន្ធជាត្រី ឈ្មោះភគិនី ភរិយាដូចប្អូន
ស្រលាញ់បងពិត លំអិតលំអួន មានមាត់ពាក្យបង។
ផ្ដាច់ប្ដូរតែមួយ នឹងចង់ជាត្រួយ ចិត្តចាំបំណង
ពំនាក់ពំនឹង ពាក់ពឹងប៉ុនប៉ង តែនឹងអង្គបង
ឥតម៉ែទីទៃ។

ប្រពន្ធណាចូល នឹងប្ដីមួយមូល ចិត្តជាប់អាល័យ
ដូចប្អូននឹងបង ចាំចង់អាស្រ័យ ប្រពន្ធនោះថ្លៃ



មធ្យមពេកពិត។

៤_ប្រពន្ធចញ្ចា ឈ្មោះហៅសខា_ ភរិយាដូចមិត្ត
សម្លាញ់ស្រឡាញ់ អស់អញ្ជូពេកពិត ស្មើខ្លួនស្មើចិត្ត
ស្មគ្រស្មោះចិន្ដា។

បើមិត្តទៅបាត់ ស្ងប់ស្ងួតមុខមាត់ ទុក្ខទន់ទយា
ឃើញមុខមកបាន ចិត្តក្សាន្តសោះសា ស្រស់ស្រួលភត្រ្តា
និរទុក្ខសោកសៅ។

ប្រពន្ធណាពិត ស្រលាញ់ប្ដីពិត គ្មានក្នុងគ្មានក្រៅ
ដូចមិត្តនិងមិត្ត ចង់ចិត្តជាប់នៅ ប្រពន្ធនោះហៅ
ឧត្តមក្រមាន។

សម្ដែងភរិយា ទាំងបួនសឹងជា ក្រស្រីធ្វើបាន

បើស្រីណាគិត ផ្ចង់ចិត្តសន្ដាន ស្រឡាញ់ប្ដីប្រាណ
ដូចធម៌ទេសនា។

លោកថាស្រីនោះ ពុកេក្ដីពីរោះ ទូទៅនានា
បើអស់ជីវិត ទៅស្ថិតសួគ៌ា ចៀសចាកចតុរា
បាយបាបទុក្ខភ័យ។

៥_ប្រពន្ធពុំជា ឈ្មោះ**វធកា**_ ភរិយាដូចនៃ
សត្រូវចាំចង ទោសផងសព្វថ្ងៃ ប្រពន្ធចង្រៃ
ប្ដីមានតែទុក្ខ ។

បើប្ដីខុសចិត្ត វាគ្មានអាណិត ខេរខឹងជាអុក
ចាំចងទោសប្ដី ស្រដីកិចកុក ឲ្យមាត់ឲ្យមុខ
វេះវាងវ្លោះវ្លើយ។

សុខទុក្ខសាំទាំ វាមើលបំណាំ នៅស្ងៀមព្រងើយ
ពុំជួយទុក្ខភ័យ ដោះដៃកន្ដើយ ស្លាប់ដោយរស់ដោយ
គ្មានចិត្តមេត្រី ។

៦_**ចោរីភរិយា** ប្រពន្ធពុំជា លបលួចទ្រព្យប្ដី



គ្មានចិត្តករុណា មេត្តាប្រណី របស់ទ្រព្យអ្វី
លក់ចាយអស់ធន។

៧_**អយ្យាភរិយា** ប្រពន្ធពុំជា តម្កើងតែខ្លួន
ចេះតែប្រើប្ដី ឥតបីមានសួន ធ្វើឫកណាំនួន
ទុកប្ដីដូចខ្ញុំ។

**ប្រពន្ធទាំងបី** ធ្លាក់ទៅអវចី រងទុក្ខដំណាំ
ក្នុងខ្ទះភ្លើងក្ដៅ យូរនៅក្រៀមក្រំ ព្រោះចិត្តជាធំ
ជាងប្ដីអាត្មា។

**ឯប្រពន្ធបួន** មុននោះគួរសួន យកជាភរិយា
នឹងកើតរបស់ កេរ្តិ៍យសសក្ដា ថ្កើងពូជពង្សា
សោយសុខស្ដេរស្ថិត។

សម្ដែងបរិយាយ **ភរិយាទាំងឡាយ** ប្រាំពីរចរិត
ទាំងដូទាំងជា ពណ៌នាពោលពិត ចែកចប់ពិនិត្យ

នាមអត្ថគាថា។

ម្យ៉ាងទៀត យើងជាស្ត្រីត្រូវវៀរឲ្យឆ្ងាយចាកពាក្យតិះដៀលដូចខាងក្រោមនេះ គឺកុំឲ្យមានសូម្បីបន្តិចក្នុងខ្លួនយើងឡើយ ពាក្យនោះគឺ ៖

ពួកស្រីមានកលមារយាដូចចោរ មានពិសខ្លាំង
ដូចសុរាដែលលាយថ្នាំពិស និយាយបិទបាំង
ទោសដូចពាណិជ មានអាការៈប្រែប្រួលដូច
កុយរមាស មានអណ្តាតពីរដូចពស់ ។
ពួកស្រីបិទបាំង (នូវកាយ) ដូចជាគេបិទបាំង
រណ្តៅ បំពេញបានដោយក្រដូចសមុទ្រ
ត្រេកអរបានដោយក្រដូចអារក្សទឹក នាំយក
ទៅដោយដាច់ខាតដូចយមបាល ។ ពួកស្រីដូច
ភ្លើង នាំយកនូវវត្ថុគ្រប់យ៉ាងដូចស្ទឹង មានអាការៈ
រហើររហោចក្នុងកាមដូចខ្យល់ មិនឲ្យមានប្លែក
ដូចភ្នំនេរុ មានផ្លែជានិច្ចដូចឈើមានពិសពុល
ពួកស្រីតែងញុាំងភោគៈ ក្នុងផ្ទះឲ្យវិនាសធ្វើ
សេចក្តីអន្តរាយនូវរតនវត្ថុទាំងឡាយ ។

**ន សា ភរិយា យា បតិនោ ន វិភេតិ**
**ភិយាណាមិនខ្លាចប្តី ភរិយានោះ មិនមែន**
**ជាភរិយាទេ** សុត្តន្ត.សុតសោមជាតក ៦១/២១៣។

## ២.ភារកិច្ចក្រោយពេលរៀបអាពាហ៍ពិពាហ៍

បន្ទាប់ពីពេលរៀបអាពាហ៍ពិពាហ៍រួចហើយ យើងត្រូវដឹងខ្លួនថា យើងមិនមែននៅកម្លោះក្រមុំដូចពីមុនទៀតឡើយ ។ ខ្លួនយើងត្រូវធ្វើខ្លួនឱ្យសមជាអ្នកមានគ្រួសារ ហើយត្រូវតែប្រព្រឹត្តឱ្យបានជាអ្នកមានគ្រួសារមួយដ៏ល្អ ។ យើងមិនត្រូវឱ្យអ្នកដទៃមើលងាយយើងថា មនុស្សមិនបានការ ខ្ជិលច្រអូស គិតតែពីស៊ី គ្មានការងារធ្វើឡើយ ។ មិនថា ជាប្តីឬប្រពន្ធទេ ត្រូវតែជាអ្នកមានភារកិច្ចដូចគ្នាក្នុងគ្រួសារ ហើយត្រូវចេះស្រលាញ់គ្នានឹងគ្នាយ៉ាងស្មោះត្រង់ មិនមានចិត្តគំនិតបែកបែរ ឬពាក្យចាស់ថា បែកឆ្វេងឡើយ ។

ពេលរៀបការហើយមិនយូរប៉ុន្មាននោះ គួរយើងធ្វើបញ្ជីសៀវភៅមួយដើម្បីសុំអ្វីពីគ្នាទៅវិញទៅមក ដូចជា ប្តីត្រូវសូមឱ្យប្រពន្ធស្មោះត្រង់ មិនចូលចិត្តរអ៊ូរទាំច្រើន និយាយច្រំដែល ឬសូមឱ្យប្រពន្ធរក្សាសីល៥... ។



ចំណែកយើងជាប្រពន្ធក៏ត្រូវសូមប្តីវិញដែរ នូវចំណុចណាមួយ ដែលយើងត្រូវការ ដូចកុំឱ្យប្តីមានស្រីទៀតជាដើម...។

កាលយើងបានធ្វើកិច្ចសន្យា រវាងគ្នាទៅវិញទៅមកយ៉ាងហ្មត់ចត់និងច្បាស់លាស់រួចហើយ ខ្លួនយើងត្រូវធ្វើឱ្យបាននូវកិច្ចសន្យានោះ មិនមែនសន្យាតែមាត់នោះទេ ។

សំខាន់បំផុត យើងត្រូវមានការងារធ្វើឱ្យយ៉ាងសមរម្យ តាមសមត្ថភាព ព្រោះថា មនុស្សមិនមានការងារធ្វើសូម្បីអ្នកប្រាជ្ញក៏លោកតិះដៀល ដូចពាក្យថា ៖

អលសោ គិហី កាមភោគី ន សាធុ
អសញ្ញតោ បព្វជិតោ ន សាធុ
រាជា ន សាធុ អនិសម្មការី
យោ បណ្ឌិតោ កោធនោ តំ ន សាធុ[៨] ។

*គ្រហស្ថបរិភោគកាមគុណ កុំដិលស៊ិនហៅពុំប្រពៃ*

---

[៨] សុត្តន្ត.ខុទ្ទក.មណិកុណ្ឌលជាតក ៥៩/២

*បព្វជិតឥតសង្រួមក្នុងវិន័យ មិនជាវិស័យក្នុងសាសនា*
*មហាក្សត្រចាត់ការធ្វើអ្វីៗ មិនមានក្តីគិតមុនដោយបញ្ញា*
*ប្រាជ្ញបណ្ឌិតប្រព្រឹត្តក្រេវក្រោធា ការងារនោះជាប្រពៃទៅពុំបាន។*

មានគាថាមួយទៀតដែលយើងត្រូវសិក្សាហើយ ពិចារណានឹងត្រូវប្រតិបត្តិតាមគាថានោះថា៖

**ឧដ្ឋានកាលម្ហិ អនុដ្ឋហានោ**
**យុវា ពលី អាលសិយំ ឧបេតោ**
**សំសន្នសង្កប្បមនោ កុសីតោ**
**បញ្ញាយ មគ្គំ អលសោ ន វិន្ទតិ ។**

*បុគ្គលនៅកម្លោះមានកម្លាំង តែផ្អែកនឹងខ្ជិល*
*ច្រអូសមិនប្រឹងប្រែងក្នុងកាលដែលគួរប្រឹង*
*ប្រែងមានសេចក្តីត្រិះរិះក្នុងចិត្តលិចចុះ ក្នុង*
*អកុសលវិតក្កៈជាមនុស្សខ្ជិល បុគ្គលខ្ជិលនោះ*



*រមែងមិនបាននូវផ្លូវបញ្ញាឡើយ*[៩] ។

ព្រោះហេតុនោះ យើងត្រូវតែមានការងារធ្វើទៅតាមកម្លាំងរបស់យើង ដូចព្រះសម្មាសម្ពុទ្ធទ្រង់សំដែងនូវសម្បទា ៤ យ៉ាង សម្រាប់គ្រហស្ថយើងអ្នកគ្រប់គ្រងផ្ទះ ឱ្យមានការប្រតិបត្តិ ដើម្បីសេចក្តីសុខចម្រើនកើតសុភមង្គលក្នុងគ្រួសាររបស់យើងគឺ៖

**១.ឧដ្ឋានសម្បទា**
**២.អារក្ខសម្បទា**
**៣.សមជីវិតា**
**៤.កល្យាណមិត្តតា**[១០]

**សេចក្តីអធិប្បាយ**

---

[៩] សុត្តន្ត.ខុទ្ទកបាឋ: ធម្មបទគាថា ៥២/៧៩,អដ្ឋកថា ធម្មបទ ៧/៩៧ ,នរទក្ខទីបនី
[១០] សុត្តន្តបិដក អង្គុត្តរនិកាយ អដ្ឋកនិបាត ៤៨/២៤៤

**ខដ្ឋានសម្បទា** មានន័យថា ខ្លួនយើងត្រូវព្យាយាមរកស៊ីទាំងយប់ ទាំងថ្ងៃមិនខ្ជិលច្រអូស ប្រកបដោយឧបាយជាគ្រឿងពិចារណាក្នុងការងារទាំងនោះ ហើយគួរធ្វើ គួរចាត់ចែង ។ កាលបើយើងខ្ជិលរកស៊ី គិតតែពីដើរលេងគ្មានស្គាល់ថ្ងៃយប់នេះ ជាប្រធាននៃសេចក្តីវិនាស សុភមង្គលក្នុងគ្រួសាររបស់យើង មិនអាចចម្រើនរុងរឿងទៅបានឡើយ ព្រោះហេតុនោះ យើងត្រូវមានសតិដាស់តឿនខ្លួនឯងថា អាត្មាអញមិនមែននៅកម្លោះក្រមុំ ដូចពីមុនទេ គឺអញមានប្តីប្រពន្ធហើយ ដូច្នេះអញត្រូវធ្វើខ្លួនឱ្យសមជាអ្នកមានគ្រួសារមួយដ៏ល្អ មិនគួរធ្វើជាអ្នកអាវ៉ាសែ ដូចបុគ្គលពាលឡើយ ត្រូវតែព្យាយាមរកស៊ីដើម្បីឱ្យមានទ្រព្យធន ដើម្បីចិញ្ចឹមប្រពន្ធកូន ប្តីឱ្យបានសេចក្តីសុខ ។

**អារក្ខសម្បទា** បានន័យថា កាលយើងរកលុយកាក់



បានមកហើយ ត្រូវសន្សំទុកឱ្យបានល្អ ត្រូវចេះបែងចែកឱ្យបានសមគួរ មានចំណាយលើម្ហូបប្រចាំថ្ងៃ របស់របរសម្រាប់ប្រើប្រាស់ក្នុងផ្ទះ ចិញ្ចឹមឪពុកម្តាយ ធ្វើបុណ្យជាដើម ។ កាលបើយើងបែងចែកបានល្អនោះ លុយកាក់របស់យើងនឹងគង់វង្សសម្រាប់តម្កល់ទុកទៅខាងមុខ ។ ដូច្នេះលុយកាក់ដែលយើងខំព្យាយាមរកមកទាំងយប់ទាំងថ្ងៃនោះ យើងត្រូវដឹងថាជាការលំបាកណាស់ទម្រាំបានមក បើយើងធ្វើការរាជការត្រូវដឹងថា វាហត់នឿយលំបាកខួរក្បាលដោយសារការគិត ។ បើលក់ដូរក៏លំបាកក្នុងការចំណេញបានមួយពាន់ពីរពាន់ ដូច្នេះ យើងមិនគួរចំណាយទៅលើអ្វីៗ ដែលឥតប្រយោជន៍ដូចជា ខ្ជះខ្ជាយមិនដឹងប្រមាណឬយកទៅលេងល្បែងភ្នាល់ជាដើម ។ ចំណែកយើងជាស្រីកុំឱ្យដូចជាពាក្យខ្មែរបុរាណពោលថា **"ស្រីករញ្ជើផ្ទះ"** ឡើយ ។ ក្នុងរឿង **"មៀយើង"** មាន ពោលពីនាងកញ្ជើធ្លុះថា

នាងមិនបានថែរក្សានូវត្រី កំពឹស ដែលប្តីរកបានមកនោះទេ គិតតែពីយកឈើចាក់កញ្ច្រោងឱ្យធ្លុះ ធ្លាក់ត្រីកំពឹសអស់ ដែលបានន័យថា ស្ត្រីខ្លះក្នុងលោកនេះ ពេលដែលប្តីរកទ្រព្យបានមក ខ្លួនមិនខំថែរក្សាឱ្យបានល្អ គិតតែចាយវាយឥតដឹងមុខ ធ្វើឱ្យទ្រព្យនោះ អស់រលីង ដល់ពេល មានកិច្ចចាំបាច់រកប្រាក់គ្មាន ព្រោះហេតុនោះចាស់ ៗ តែងថា **"មេស្រីកញ្ជើធ្លុះ"** ។ ហេតុនោះឯង មិនថា ស្ត្រីឬបុរសទេ យើងមានភារកិច្ចជួយគ្នាថែរក្សាទ្រព្យសម្បត្តិដែលរកបានមក ហើយឱ្យនៅគង់វង្សមិនឱ្យវិនាស បាត់បង់ដោយ ប្រការណាមួយ ឡើយ ។

**កល្យាណមិត្តតា** បានន័យថា ត្រូវចេះសេពគប់មិត្តណាមានប្រយោជន៍ ជាមិត្តនាំមកនូវសេចក្តីសុខចម្រើន ដល់គ្រួសារយើង មិនមែនជាមិត្តប្លម មិត្តពាលដើងកាងអាវ៉ាសែនោះឡើយ ។ ការសេពគប់មិត្តមាននៅទំព័រខាងដើមស្រាប់



សូមប្រិយមិត្តអ្នកអានមើលនៅខាងដើមចុះ ។ តែមានសេចក្តីផ្សេងគ្នាខ្លះគឺថា បើក្នុងស្រុកភូមិណា មានអ្នកមានសីលបរិបូណ៌ដោយសទ្ធា បរិបូណ៌ដោយចាគ: បរិបូណ៌ដោយបញ្ញា យើងត្រូវចូលទៅសាកសួរ សាកច្ចាជាមួយជនទាំងនោះទោះជាក្មេងក៏ដោយ ចាស់ក៏ដោយ យើងត្រូវដឹងថា អ្នកទាំងនោះជាកល្យាណមិត្តដ៏ប្រសើររបស់យើង ។

**សមជីវិតា** បានន័យថា ចិញ្ចឹមជិវិតស្មើ គឺថា យើងចេះដឹងការវិនាសទៅនៃភោគ:ដោយហេតុនេះ ការចម្រើនភោគ:ដោយហេតុនេះ ហើយចេះបរិភោគមិនត្បិតត្បៀតពេកមិនខ្ជះខ្ជាយពេក គួរបរិភោគឱ្យសមល្មមនឹងភោគ:ដែលខ្លួនមាន មិនមែនខ្លួនជាអ្នកមាន តែទៅហូបរបស់សៅហ្មងមិនច្នាញ់ ដូចជាមនុស្សថាំពេក មើលតែមិនមានលុយទិញហូប ។ បើខ្លួនជាអ្នកទាល់ក្រ ហើយស្រាប់តែចំណាយហួស

ប្រមាណដូចភាសិតថា "ស៊ីដូចមុស ដុះដូចដំរី" នេះក៏មិនត្រូវដែរ ។ កាលបើលុយកាក់មានដោយខំប្រឹងរកស៊ីអស់កម្លាំងល្ងិតល្ងៃទាំងថ្ងៃទាំងយប់ ហើយមានលុយកាក់ល្មមគ្រាន់បើហើយយើង មិនហ៊ានហូបចុកទៀត ហាក់ដូចជាអ្នកក្រមិនមានទ្រព្យសោះ អ្នកប្រាជ្ញលោកឱ្យឈ្មោះថា **"អ្នកកំណាញ់គ្រៀវតម្រា** "ឌ

"ទោះមានទ្រព្យប៉ុណ្ណា បើក្នុងចិត្តមិនចេះគ្រប់គ្រាន់ទេ ឈ្មោះថា នៅក្រហាមជានិច្ច" ។

សេចក្តីសុខរបស់យើងអ្នកគ្រប់គ្រងផ្ទះមាន ៤ ប្រការ ដែល ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែង[១១] ហើយយើងត្រូវតែធ្វើឱ្យបាន គឺ ៖

**១.អត្ថិសុខ** សុខកើតអំពីការមានទ្រព្យ

[១១] *សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ៤២/១៣០*



**២.ភោគសុខ** សុខចេះប្រើប្រាស់ចាយវាយទ្រព្យ

**៣.អនណសុខ** សុខមិនជំពាក់បំណុលគេ

**៤.អនវជ្ជសុខ** សុខការងារប្រាសចាកទោស ។

នេះជាសេចក្តីសុខ ៤ ប្រការ សម្រាប់យើងជាគ្រហស្ថដែលព្រះសម្ពុទ្ធទ្រង់ជាសព្វញ្ញូ ទ្រង់ជ្រាបច្បាស់នូវសច្ចធម៌ប្រកាសសម្តែងជាប្រយោជន៍ដល់យើង មានអធិប្បាយថា ៖

**អត្ថិសុខ** បានសេចក្តីថា យើងជាអ្នកនៅគ្រប់គ្រងផ្ទះ ការមានទ្រព្យចាត់ជាសេចក្តីសុខមួយយ៉ាងសំខាន់ ដែលមនុស្សគ្រប់រូបប្រាថ្នាចង់បាន គ្រប់ពេលវេលា បើមិនមានទ្រព្យហើយ សេចក្តីសុខក៏គ្មានដែរ តែក៏គប្បីយល់ដែរថាការបានទ្រព្យនោះមិនមែនបានមកដោយងាយៗឬ ដោយលួចប្លន់ ឆក់ ដណ្តើម កេងប្រវ័ញ្ចគេនោះទេ ត្រូវតែព្យាយាមពោលគឺសេចក្តីខ្នះខ្នែងដោយកម្លាំងដៃ មានញើសហូរចេញ

គួបផ្សំនឹងបញ្ញារបស់យើង ដែលបានសិក្សាមកហើយរហូតមានជំនាញក្នុងការងាររកស៊ីគ្រប់មុខ ឬ មុខរបរណាមួយ ដែលសមត្ថភាពយើងអាចធ្វើបាន ហើយទ្រព្យនោះឯង យើងតែងបានមកដោយធម៌សុចរិតទៀងត្រង់ ធ្វើឱ្យយើងមានសុខសោមនស្សថា ទ្រព្យទាំងឡាយ ដែលបានមកដោយសេចក្ដីព្យាយាមរបស់យើង ជាទ្រព្យប្រកបដោយធម៌ បានមកដោយធម៌ របស់អាត្មាអញ មិនមែនបានមកដោយទុច្ចរិតនោះទេ នេះហៅថា **អត្ថិសុខ** ។

**ភោគសុខ** មានន័យថា សុខកើតពីការចេះប្រើប្រាស់ចាយវាយទ្រព្យ ដែលខ្លួនរកបានមកនោះ ត្រូវបែងចែកទៅក្នុងផ្លូវជាកុសលដូចចិញ្ចឹមមាតាបិតា បុត្រភរិយា ទាសាទាសី កម្មករដែលរួមរស់ក្នុងបន្ទុករបស់ខ្លួនឱ្យមានសេចក្ដីសុខព្រោះអាស្រ័យទ្រព្យដែលខ្លួនមាននោះ ។ ម្យ៉ាងទៀត ចេះចែក



រំលែកឱ្យទានដល់បព្វជិតអ្នកបួស និងអ្នកកំសត់ទុគ៌ត ហៅថាធ្វើបុណ្យ ។ ត្រូវចៀសវាងយ៉ាងដាច់ខាត នូវការប្រើប្រាស់ទ្រព្យក្នុងផ្លូវខុស គឺ ចំណាយទៅលើស្រី ស្រា ល្បែង ជាអំពើអបាយមុខ នាំឱ្យវិនាសទ្រព្យសម្បត្តិ ។

**អនណសុខ** មានសេចក្ដីថា សុខកើតពីការមិនជាប់ជំពាក់បំណុលគេធម្មតាអ្នកជាប់ជំពាក់បំណុលគេ ទោះតិចក្ដីច្រើនក្ដីតែងមានសេចក្ដីទុក្ខព្រួយភ័យខ្លាចក្នុងចិត្តជានិច្ច ក្រែងម្ចាស់បំណុលគេមកតឿនទារ ។ ឯអ្នកមិនជាប់បំណុលគេនេះ តែងមានសេចក្ដីសុខសោមនស្សដូច្នេះថា អាត្មាអញមិនជំពាក់បំណុល ទោះតិចក្ដី ច្រើនក្ដី របស់បុគ្គលណាមួយឡើយ នេះហៅថា **អនណសុខ ៕**

**អនវជ្ជសុខ** មានន័យថា សុខកើតពីការងារប្រាសចាកទោស រាល់ការងារដែលយើងប្រកបក្នុងការរកស៊ី

ចិញ្ចឹមជីវិតសញ្ចថ្ងៃ មានការងារខ្លះអាចផ្តល់ទោសកំហុសដល់អ្នកធ្វើដូចជាត្រូវចូលគុក ជាប់ច្រវាក់ និងត្រូវគេដាក់ទោសទណ្ឌកម្មផ្សេង ។ ផលទាំងអស់នេះបណ្តាលមកពីការងារមិនសុចរិត ។ បុគ្គលអ្នកប្រាថ្នាសេចក្តីសុខ ត្រូវវៀរចាកការសម្លាប់ ការលួច ឆក់ ប្លន់ ការប្រព្រឹត្តិខុសក្នុងកាមនិយាយពាក្យកុហក ផឹកទឹកស្រវឹង ហើយបែរមកប្រកបធម៌ល្អមានការស្រឡាញ់ចំពោះមនុស្សនិងសត្វទូទៅ រកស៊ីក្នុងផ្លូវសុចរិត ត្រេកអរតែនឹងភរិយារបស់ខ្លួន មានភាពស្មោះត្រង់ចំពោះគ្នានឹងគ្នាចម្រើនសតិវៀរចាកគ្រឿងស្រវឹង និងការងារឱ្យស្អាតដោយកាយ ដោយវាចា និងដោយចិត្ត ការពិចារណាឃើញអំពើដែលខ្លួនធ្វើសុទ្ធតែល្អ ដូច្នេះចិត្តក៏រមែងត្រេកអររីករាយអ្នកដទៃក៏រាប់អានស្រឡាញ់ចូលចិត្ត សេចក្តីសុខសោមនស្សក៏កើតឡើងព្រោះការងារមិនមានទោសយ៉ាងនេះ ។ យើងជាអ្នក



ស្រលាញ់កិត្តិយសកេរ្តិ៍ឈ្មោះ យើងត្រូវតែជាអ្នកមានកាយកម្មសុចរិត វចីកម្មសុចរិត មនោកម្មសុចរិត ។ នៅក្នុងអដ្ឋកថាមនោរថបូរណី[១២] អដ្ឋកថាចារ្យសម្តែងថា សុខបីខាងដើមមិនបានចម្រៀកទី១៦នៃសុខ ដែលកើតអំពីការងារប្រាសចាកទោសឡើយ ។

ព្រោះហេតុនោះ សូម្បីតែយើងមិនមានទ្រព្យសម្បត្តិជាសុខក៏ដោយ ក៏យើងមិនត្រូវទៅធ្វើអំពើលាមកមានលួចប្លន់ជាដើមឡើយ យើងត្រូវគិតឃើញថា ទ្រព្យដែលមានវាកើតមកអំពីបុណ្យ បើយើងខ្វះបុណ្យហើយ តើទ្រព្យសម្បត្តិបានអំពីទីណា ។ កាលណាយើងក្រ យើងមិនត្រូវរវើយរវាយចិត្តពេកទេ ត្រូវធ្វើចិត្តឱ្យស្ងប់ ហើយដោះស្រាយបញ្ហាដែល

---

[១២] អដ្ឋកថា អង្គុត្តរនិកាយ ចតុក្កនិបាត ៣៥/២០៨

កើតឡើង ដោយបញ្ញារបស់យើង ។ នៅក្នុងសុត្តន្តបិដក ខុទ្ទកនិកាយ ថេរគាថាព្រះសីវលត្ថេរពោល[១៣] ថា៖

សីលមេវិធ សិក្ខេថ　　　អស្មឹ លោកេ សុសិក្ខិតំ
សីលំ ហិ សព្វសម្បត្តឹ　　　ឧបនាមេតិ សេវិតំ ។

*បុគ្គលគប្បីសិក្សានូវសីលឲ្យជាសីល ដែលខ្លួនសិក្សាល្អហើយ ក្នុងលោកនេះ ព្រោះថា សីលដែលបុគ្គលសេពល្អហើយ រមែងបង្អោនមកនូវសម្បត្តិទាំងពួង ។*

សីលំ រក្ខេយ្យ មេធាវី　　　បត្ថយានោ តយោ សុខេ
បសំសំ វិត្តិលាភញ្ច　　　បេច្ច សគ្គេ បមោទនំ ។

*ជនអ្នកមានប្រាជ្ញា កាលចង់បាន នូវសេចក្តីសុខបីយ៉ាងគឺការសរសើរ ១ ការបាននូវសេចក្តីត្រេកអរ១ ការលះលោកនេះទៅហើយ រីករាយក្នុងស្ថានសួគ៌១*

---

[១៣] សុត្តន្តបិដក ខុទ្ទកនិកាយ ថេរគាថា ទ្វាទសកនិបាត ៥៧/២៨



*គប្បីរក្សានូវសីល ។*

មានសំនួរសួរថា ហេតុអ្វីបានជាព្រះថេរៈពោលថា អ្នកមានសីលតែងមានទ្រព្យសម្បត្តិ ឆ្លើយថា អ្នកមានសីលជាអ្នកមិនប្រមាទក្នុងកិច្ចការងារទាំងពួង ។ បុគ្គលដែលជាអ្នកមានសីលទោះធ្វើការអ្វី ក៏ជាអ្នកធ្វើដោយមានស្មារតីប្រុងប្រយ័ត្នជានិច្ច ជាអ្នកមិនធ្វេសប្រហែសឡើយ ព្រោះថា មនុស្សមានសីលជាអ្នកមាននូវអប្បមាទធម៌ក្នុងខ្លួន ធ្វើការជាអ្នកប្រាកដប្រជា ពេលសម្រាកដឹងនូវពេលសម្រាកមិនដើរលេង មិនខ្ជិលច្រអូសការងារ ស្ថិតនៅក្នុងទីណា ក៏គេស្រលាញ់រាប់អានគ្រប់ៗគ្នា ។ ដោយមានធម៌ក្នុងខ្លួនគឺការមិនធ្វេសប្រហែសនេះហើយ ទើបបានទទួលលទ្ធផលជាអ្នកមានទ្រព្យសម្បត្តិ និងញាតិមិត្តជិតខាងច្រើន ។ មនុស្សជាកល្យាណមិត្ត តែងរាប់រកមនុស្សដែលជាអ្នកមានសីល ទោះបីយើងខាតជំនួញដូញដូរអ្វីមួយ ក៏មនុស្សដែលជាកល្យាណ

មិត្តដ៏ល្អរបស់យើង នឹងជួយដោះទុក្ខឱ្យរួចផុតពីភាពលំបាកនោះបានដែរ ។ ព្រោះហេតុនោះ អ្នកមានសីលតែងមានទូវទ្រព្យសម្បត្តិនិងកិត្តិយសល្អ ព្រមទាំងសេចក្តីសរសើរពីញាតិមិត្តបងប្អូន គ្រប់ៗកាល ។

គម្ពីរលោកនីតិ

អធនស្ស រសង្ខាទា អពលស្ស ហតា នរា
អបញ្ញស្ស វាក្យាកថា ឧម្មត្តកសមា ឥមេ ។

ជនអ្នកខ្វះចង់ស៊ីរសខ្ពស់ខ្ពង់ ជនអ្នកអត់កម្លាំងចង់ចម្បាប់
ជនអ្នកឥតបញ្ញាចង់ថ្លែងស័ព្ទ ជនបីនេះរាប់ទុកស្មើឆ្កួត ។

អ្នកអត់ធនធាន ចង់ទទួលទាន រសឆ្ងាញ់លើសលែង
ជនឥតកម្លាំង ចង់តាំងប្រឡែង ចម្បាប់ទាត់ប៉ែង
សម្តែងអំនួត ។
ជនឥតប្រាជ្ញា ល្មោភថ្លែងចរចា ប្រាថ្នាគេអួត



ជនបីនេះប្រើ ទុកស្មើគេឆ្កួត ព្រោះឡើងអំនួត
ល្មោភហួសប្រមាណ ។

ចំពោះយើងជាស្វាមី មានការអត់ធន់ជាគុណធម៌ប្រចាំលោក ដើម្បីចងជាចំណងសុភមង្គលគូស្វាមីឱ្យស្ថិតស្ថេរ ឱ្យគម្រូដល់កូនប្រុសស្រី ធម្មតាស្ត្រីមានក្តីប្រាថ្នាឱ្យស្វាមីយល់ចិត្ត មិនចូលចិត្តការប្រមាថមើលងាយឡើយ ។ ម្យ៉ាងទៀត បើស្វាមីយល់ថា ស្ត្រីមានសេចក្តីលំបាកច្រើនជាងបុរស គួរឆ្លៀតពេលខ្លះនាំនាងទៅដើរលម្ហែយកខ្យល់អាកាសតាមកាលវេលា ដែលអាចទៅបាន ។ កុំដើរលេងតែម្នាក់ឯងឬជាមួយមិត្តភក្ត្រឡើយ នេះពិតជាពុំប្រពៃឡើយ ។

ចំណែកយើងជាភរិយាត្រូវមានសេចក្តីអត់ធន់ ចំពោះពេលដែលស្វាមីមកអំពីធ្វើការមានទឹកមុខមិនធម្មតា ដូចជាស្រពោនឬមានទឹកមុខប្លែកពីចម្ងាយ ។ បើភរិយាខ្វះការពិចារ-

ណាពិតជាខឹងឬអាក់អន់ចិត្ត ប៉ុន្តែតាមពិតលោកជាស្វាមីនោះ មានបញ្ហានៅកន្លែងធ្វើការឬបញ្ហាស្មុគស្មាញ យើងជាភរិយាគួរយល់ផងដែរ ។ ដូច្នេះ ត្រូវចេះថ្នមពាក្យសម្តីទឹកមុខញញឹមទទួលនាំនិយាយរឿងឱ្យសប្បាយ ឬរៀបបាយទឹក ភេសជ្ជៈជូនចំពោះស្វាមី ។ ហាមដាច់ខាតការនិយាយស្តីបន្ទោសឬពោលពាក្យបញ្ចិតបញ្ចៀងឡើយ ។

ការមានមេត្តាវវាងគ្នាចំពោះប្តីប្រពន្ធ ក្នុងគ្រួសារ មិនមានអំពើហិង្សា ឈ្លោះទាស់ទែងគ្នាឡើយ។



## ៣.ស្ត្រីត្រូវប្រតិបត្តិឱវាទ ១០ យ៉ាង

ឱវាទជាដំបូន្មានដ៏ល្អរបស់ព្រះសម្ពុទ្ធ ឬ មាតាបិតា គ្រូបាអាចារ្យ ព្រឹទ្ធាចារ្យ ចាស់ ទុំ រៀមច្បង ដែលបានទូន្មានតាមពាក្យប្រៀនប្រដៅល្អ។ អាចជាគន្លងដើរទៅបានសេចក្តីសុខក្នុងក្រុមគ្រួសាររបស់យើង ជាពិសេសទំនៀមខ្មែរយើងច្រើនលើកយកឱវាទ១០[១៤] យ៉ាងរបស់ធនញ្ជយសេដ្ឋី

ដែលគាត់បានឱ្យឱវាទ

ពេលនាងវិសាខាត្រូវរៀបអាពាហ៍ពិពាហ៍ថា ៖

**១-មិនត្រូវនាំភ្លើងក្នុងទៅក្រៅ**

**២-មិនត្រូវនាំភ្លើងក្រៅមកក្នុង**

**៣-ឱ្យដល់អ្នកគួរឱ្យ**

**៤-មិនត្រូវឱ្យដល់អ្នកមិនគួរឱ្យ**

---

[១៤] ធម្មបទដ្ឋកថា វិសាខាវត្ថុ ៣/៩៦

**៥-ឱ្យដល់អ្នកគួរឱ្យខ្លះ មិនគួរឱ្យខ្លះ**

**៦-អង្គុយជាសុខ**

**៧-បរិភោគជាសុខ**

**៨-ដេកជាសុខ**

**៩-បម្រើភ្លើង**

**១០-នមស្ការទេវតាខាងក្នុង ៗ**

**មិនត្រូវនាំភ្លើងក្នុងទៅក្រៅ** បានន័យថា រឿងរ៉ាវក្នុងក្រុមគ្រួសារយើងមានការឈ្លោះប្រកែកគ្នាឬវិវាទគ្នាផ្សេង ៗ ជារបស់ឪពុកក្មេក ម្ដាយក្មេក ឪពុកម្ដាយបង្កើត ឬ ស្វាមី យើងមិនត្រូវនាំទៅប្រាប់អ្នកជិតខាងឱ្យគេដឹងឮទេ ព្រោះថា នេះសុទ្ធតែជាបញ្ហាក្នុងគ្រួសារយើង កុំឱ្យគេមើលងាយ មើលថោកដល់យើងគ្រួសារយើងឡើយ ។ ប្រសិនបើរឿងតិចតួចឬធំដុំក៏ដោយត្រូវ



ដោះស្រាយ ដោយបញ្ញា មិនត្រូវបង្កើតឱ្យជារឿងធំបានទេ ។ ការរស់នៅជាមួយគ្នា តែងតែមានរឿងខ្លះជាមិនខាន ដូចចានទៅក្នុង រាវជាមួយគ្នា រឿងអ្វីមិនប៉ះគ្នានោះ ។ កាលបើយ៉ាងនោះត្រូវចេះអនុគ្រោះដល់គ្នានិងគ្នាទៅវិញទៅមក ត្រូវមានមេត្តាដល់គ្នាទៅវិញទៅមក យើងមិនត្រូវស្រលាញ់គ្នាដោយ អំណាចរាគ:នោះទេ ព្រោះថា កាលរាគ:គឺ ស្រលាញ់ខ្សោយចុះអស់ ឬជិនណាយ ពេលនោះយើងលែងមានសេចក្ដីស្រលាញ់ចំពោះគ្នា ព្រោះហេតុនោះ សូមកុំស្រលាញ់គ្នា ដោយអំណាចរាគ: តែម្យ៉ាង ត្រូវចេះមានការអាណិតអាសូរដល់គ្នា មានមេត្តាជាទឹកដ៏ត្រជាក់សម្រាប់រំលត់ភ្លើងគឺជម្លោះរវាងគ្នានឹងគ្នា ។ ពាក្យទូន្មានក្នុងទីនេះលោកថា **អគ្គិ** មានន័យថា ភ្លើង ដែលអាចឆាបឆេះអ្វី ៗ បានទាំងអស់ យើងក៏ដឹងថា ធម្មតាភ្លើងសូម្បីតូចប៉ុនដើងធូបក៏ដោយ កាលយកទៅដាក់កន្លែងមានសម្រាម ឬ

កំទេចកំទីផ្សេង ៗ អាចរាលដាលឆេះបាន ដូចជារឿងរ៉ាវក្នុងគ្រួសារ សូម្បីបន្តិចបន្តួច បើយើងបង្កឱ្យកាន់តែខ្លាំងរឿងនោះកាន់តែខ្លាំងឡើង អាចលែងលះគ្នាក៏មាន ។

**ការនាំភ្លើងក្រៅមកក្នុង** មានន័យថា រឿងគេខាងក្រៅផ្ទះ ក៏មិនត្រូវនាំមកឱ្យជាបញ្ហាដល់ក្រុមគ្រួសារយើងឡើយ។ ព្រោះអាចបង្កឱ្យមានបញ្ហាផ្សេងដល់ក្រុមគ្រួសារយើង ព្រោះហេតុនោះ មិនត្រូវនាំភ្លើងខាងក្រៅមកក្នុងផ្ទះរបស់យើងទេ ។

**ឱ្យដល់អ្នកគួរឱ្យ** ធម្មតាការឱ្យដល់ជនដទៃត្រូវមើលឱ្យច្បាស់លាស់ មិនត្រូវចេះតែឱ្យទេ បើយើងឱ្យទៅគេសងមកវិញតាមកាលសន្យា នោះទើបយើងគួរឱ្យ ។

**មិនត្រូវឱ្យដល់អ្នកមិនគួរឱ្យ** បុគ្គលណាឱ្យទៅហើយមិនសងវិញ បុគ្គលនោះ មិនត្រូវឱ្យទេ ព្រោះថា កាលយើងឱ្យទៅ



ហើយ មិនមានឱកាសបានមកវិញជាការខាតបាត់បង់កម្លាំងយើងនិងទ្រព្យយើងច្រើនណាស់ ។

**ឱ្យដល់អ្នកគួរឱ្យខ្លះ មិនគួរឱ្យខ្លះ** បើញាតិយើងមានចិត្តសប្បុរសធម៌ធ្លាប់មានឧបការៈចំពោះយើង ឬ មិនមានក៏ដោយ ហើយដល់នូវភាពទល់ក្រលំបាក ទោះយើងឱ្យទៅមិនមានឱកាសសងវិញ ឬ អាចសងវិញ យើងគួរឱ្យដល់ញាតិទាំងនោះ ។

**អង្គុយជាសុខ** បានន័យថា កាលឪពុកក្មេកម្តាយក្មេកមកជិត ឬ ដើរមកយើងត្រូវធ្វើឥរិយាបថឱ្យសមរម្យត្រូវអង្គុយក្នុងទីគួរអង្គុយ ត្រូវឈរក្នុងទីគួរឈរ ។

**បរិភោគជាសុខ** បានន័យថា មិនត្រូវបរិភោគមុនឪពុកក្មេកម្តាយក្មេកទេ ត្រូវចាត់ចែងម្ហូបអាហារគួរឱ្យគាត់ពិសារួច សឹមបរិភោគជាខាងក្រោយ ។

**ដេកជាសុខ** បានន័យថា មិនត្រូវដេកមុនឪពុកក្មេកម្តាយក្មេកទេ ត្រូវធ្វើវត្តបដិបត្តតូចធំហើយសឹមដេកជាខាងក្រោយ ។

**បម្រើភ្លើង** បានសេចក្តីថា ត្រូវបម្រើឪពុកម្តាយក្មេកនិងស្វាមី ដូចជាភ្លើង ។

**នមស្ការទេវតាខាងក្នុង** គឺខ្លួនត្រូវធ្វើសេចក្តីគោរពឪពុកក្មេកម្តាយក្មេកឱ្យដូចជាទេវតា ។

ឱវាទទាំង ១០ ប្រការនេះ ដែលធនញ្ជយសេដ្ឋីបានឱ្យឱវាទចំពោះកូនគឺនាងវិសាខា ហើយប្រពៃណីខ្មែរយើងតែងតែយកមកឱ្យឱវាទដល់ គូស្វាមីភរិយាដែលទើបរៀបការហើយថ្មីៗ ដើម្បីឱ្យមានការប្រតិបត្តិចំពោះស្វាមីរបស់ខ្លួន ។ ដូច្នេះយើងជាភរិយាដ៏ល្អត្រូវប្រតិបត្តិឱ្យសមជាភរិយាដ៏ល្អរបស់ស្វាមីយើង ។

> ការប្រតិបត្តិតាមតួនាទីរបស់ភរិយាជាហេតុនាំមកនូវសេចក្តីសុខដល់កូននិងស្វាមី ។



## ៤.ការរួមរស់រវាងប្តីប្រពន្ធមាន ៤ យ៉ាង

នៅក្នុងគម្ពីរអង្គុត្តរនិកាយ ចតុក្កនិបាត[១៥] ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់សម្តែងជាមួយពួកគហបតីនិងពួកគហបតានី ក្នុងចន្លោះស្រុកមធុរានិងចន្លោះស្រុកវេរញ្ជា នូវការរួមរស់រវាងប្តីប្រពន្ធមានបួនគឺ ៖

**១.ឆវោ ឆវាយ សទ្ធឹ សំវសតិ** ខ្មោចប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី

**២.ឆវោ ទេវិយា សទ្ធឹ សំវសតិ** ខ្មោចប្រុសនៅ

---

[១៥] *សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ៤២/១៤០*

រួមគ្នាជាមួយនឹងទេវតាស្រី

**៣.ទេវោ ឆវាយ សទ្ធឹ សំវសតិ** ទេវតាប្រុសនៅ



រួមជាមួយខ្មោចស្រី

**៤.ទេវោ ទេវិយា សទ្ធឹ សំវសតិ** ទេវតាប្រុសនៅ រួមជាមួយទេវតាស្រី ។

ពាក្យដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា ខ្មោចប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រីនោះ សេចក្តីថា ស្វាមីក៏ជាអ្នកមិនមានសីល ៥ ឯភរិយាក៏ជាអ្នកមិនមានសីល ៥ ដូចគ្នាគឺជាអ្នកសម្លាប់សត្វ លួចទ្រព្យសម្បត្តិអ្នកដទៃ ប្រព្រឹត្តខុសក្នុងកាម និយាយកុហក ផឹកទឹកស្រវឹង ។ បុគ្គលមិនមានសីលទាំងពីរចំណែករៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ហើយរួមរស់នៅជាមួយគ្នាទាំងមិនមានសីលនោះ ព្រះអង្គទ្រង់ត្រាស់ថា **ខ្មោចប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី** ។

ខ្មោចប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រីគឺ ប្រុសជាស្វាមីជាមនុស្សមិនមានសីល ធម៌អាថ៌ ឯស្ត្រីជាភរិយាជាអ្នកមានគុណធម៌



គឺជាអ្នកមានសីលចរិយាល្អ ជាអ្នកដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹង ជាទីរលឹក មានសីលវត្តល្អគ្រប់ពេលវេលាមិនមានចន្លោះខកខាន ។ បើប្រុសមិនមានសីល ស្ត្រីជាអ្នកមានសីលនៅរួមរស់ជាមួយគ្នា នេះឈ្មោះថា **ខ្មោចប្រុសនៅរួមជាមួយនឹងទេវតាស្រី** ។

បើប្រុសជាអ្នកមានសីល ធម៌អាថ៌ក្នុងខ្លួនជាអ្នកដល់ព្រះរតនត្រ័យជាទីពឹងជាទីរលឹក មានវត្តប្រតិបត្តិល្អ តែស្រីជាអ្នកមិនមានសីល ធម៌អាថ៌ទេ ហើយរួមរស់នៅជាមួយគ្នា នេះឈ្មោះថា **ទេវតាប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី** ។

បើប្រុសក៏ជាអ្នកមានសីល ស្រីក៏ជាអ្នកមានសីលគឺថា ជាអ្នកមានសីលទាំងពីរនាក់ មានគុណធម៌ល្អទាំងពីរ ហើយរួមរស់

ជាមួយគ្នានេះឈ្មោះថា **ទេវតាប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រី** ។

ម្យ៉ាងទៀត ព្រះអង្គទ្រង់ត្រាស់ថា[១៦] ម្នាលភិក្ខុទាំងឡាយ បើប្រពន្ធនឹងប្តីទាំងពីរនាក់ ប្រាថ្នាឲ្យជួបគ្នាក្នុងបច្ចុប្បន្ននេះផង ឲ្យជួបគ្នាក្នុងបរលោកផងលុះតែជនទាំងពីរនាក់នោះ ប្រកបដោយគុណធម៌ទាំងនេះគឺ **សមសទ្ធា** *(មានសទ្ធាស្មើគ្នា)* **សមសីលា** *(មានសីលស្មើគ្នា)* **សមចាគា** *(មានចាគៈស្មើគ្នា)* **សមបញ្ញា** *(មានបញ្ញាស្មើគ្នា)* ទើបជនទាំងនោះ ជួបគ្នាក្នុងពេលបច្ចុប្បន្ននេះផងជួបគ្នាក្នុងបរលោកផង ។

*ជនទាំងពីរនាក់ ជាអ្នកមានសទ្ធា ជាអ្នកដឹងនូវពាក្យ*
*ពេចន៍នៃស្មូម ជាអ្នកសង្រួម(ក្នុងសីល) ជាអ្នកចិញ្ចឹម*
*ជីវិតតាមគន្លងធម៌ ប្រពន្ធនឹងប្តីទាំងនោះពោលពាក្យ*

[១៦] *សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ៤២/១៥៣*



*ផ្អែមល្ហែមរកគ្នានឹងគ្នា រមែងមានសេចក្តីចម្រើនដ៏*
*ច្រើនទាំងមានការនៅជាសុខ កើតឡើងដល់គ្នានឹងគ្នា*
*ពួកសត្រូវ រមែងអាក់អន់ចិត្ត ចំពោះជនទាំងពីរដែល*
*មានសីលស្មើគ្នា ជនទាំងពីរនាក់ មានសីលនឹងវត្ត*
*ស្មើគ្នា លុះប្រព្រឹត្តធម៌ក្នុងលោកនេះ ហើយ (បើ)*
*មានចំណង់ក្នុងកាម រមែងជាអ្នកត្រេកអរ*
*រីករាយក្នុងទេវលោកបាន ។*

ដើម្បីការរស់នៅរបស់យើងបានសុខ ក្នុងបច្ចុប្បន្នជាមួយប្តីប្រពន្ធយើង នោះយើងម្នាក់ ៗ ត្រូវតែជាអ្នកមានសីលមានវត្តល្អ មានមេត្តាចំពោះគ្នានឹងគ្នា អនុគ្រោះគ្នាទៅវិញ ទៅមក មិនបង្កជម្លោះផ្សេង ៗ ក្នុងរវាងប្តីប្រពន្ធ ដែលមានរឿងបន្តិចបន្តួចឡើយ ។ សូមកុំគិតថា ការមានសីលនាំឱ្យរកស៊ីមិនបាន មិនមានសេចក្តីសុខ កាលគិតតែពីធម៌អាចមិនមានពេលវេលារកស៊ី

គំនិតនេះគួរលះបង់ចោល ហើយកាន់យកនូវគំនិតល្អថា មានសីលដូចគ្នា មានសេចក្ដីសុខខ្លាំងណាស់ មានសុភមង្គលក្នុងគ្រួសាររហូតចាស់ទុំ មិនមានរឿងអាស្រូវអ្វីឡើយ ។ សូមកុំឃើញ អានិសង្សប្រន្ថិចប្រន្តួចនៃការមិនមានសីល ដូចជាសម្លាប់សត្វអាចបានម្ហូបឆ្ងាញ់ជាដើមឡើយ ត្រូវឃើញទោសនៃការមិនមានសីលធ្វើឱ្យប្រពន្ធក្បត់ប្ដី ក្បត់កូន ប្ដីក្បត់ប្រពន្ធនិងមានបញ្ហាជាច្រើនត្រូវកើតមានក្នុងគ្រួសារ ដូច្នេះការមានសីលជាជម្រុំនៃសេចក្ដីសុខក្នុងគ្រួសារ ។

> មានស្វាមី-ភរិយាប្រកបដោយធម៌ ជាហេតុនាំមកនូវសុភមង្គលក្នុងលោកនេះ និង មានទៅក្នុងបរលោក ។



## ៥.ស្ត្រីតែងមើលងាយប្ដីដោយហេតុ ៨ យ៉ាង

ស្ត្រីពួកខ្លះក្នុងលោកនេះមិនមានគុណធម៌ក្នុងខ្លួន តែងមើលងាយស្វាមី ដែលខ្លួនបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមប្រពៃណីហើយដោយហេតុ ៨ យ៉ាង[១៧] គឺ៖

១.ប្ដីទ័លក្រ

២.ប្ដីឈឺជានិច្ច

៣.ប្ដីចាស់ទុព្វលភាព

៤.ប្ដីផឹកសុរា

៥.ប្ដីធ្វេសប្រហែស

---

[១៧] សុត្តន្តបិដក ខុទ្ទកនិកាយ អសីតិនិបាត កុណាលជាតក ៦១/១៦៧

៦.ប្តីល្ងង់ខ្លៅ

៧.ប្តីខ្ជិលច្រអូសក្នុងកិច្ចការងារ

៨.ប្តីមិនញ៉ាំងទ្រព្យសម្បត្តិគ្រប់យ៉ាងឱ្យកើតមាន

សម្រាប់ខ្លួនយើងជាមនុស្សស្រី ត្រូវមានទឹកចិត្តឱ្យបាន ស្មោះស្ម័គ្រភក្តីចំពោះស្វាមី មិនគួរមើលងាយមើលថោកត្មេះតិះដៀលប្តីទេ ទោះជាក្រីក្រ តោកយ៉ាកយ៉ាងណាក៏ដោយ ត្រូវគោរពថា នេះជាស្វាមីរបស់យើង ខ្លួនយើងត្រូវគោរពឱ្យបានល្អ មិនត្រូវមើលងាយដោយហេតុ ៨ ប្រការខាងលើនេះទេ ។ ត្រូវយកចិត្តទុកដាក់ចំពោះស្វាមីទាំងថ្ងៃទាំងយប់ ហើយចេះអនុគ្រោះចំពោះស្វាមី បើមានកំហុសគួរអាចអនុគ្រោះឱ្យបាន មិនត្រូវបង្កឱ្យកាន់តែខ្លាំងក្លានោះទេ ។ ចំណែកខ្លួនយើងជាប្រុសកាលដឹងថាស្ត្រីតែងមិនពេញចិត្តចំណុចខាងលើនេះ ហើយយើងត្រូវប្រតិបត្តិខ្លួនមិនឲ្យមានកំហុសធ្ងាំធ្ងងទាំង៨នេះ ដោយមិនឲ្យមានទាល់តែ



ស្រោះក្នុងខ្លួនយើងត្រូវឧស្សាហ៍ព្យាយាមខ្នះខ្នែងឡើង ដើម្បីធ្វើជាប្តីដ៏ល្អ និងជាទីគោរពរបស់ប្រពន្ធ ។

## ៦.ត្រូវធ្វើជាឪពុកម្តាយដ៏ល្អរបស់កូន

ធម្មតាតាមបវេណីរបស់មនុស្សលោក កាលរៀបការហើយតែងតែត្រូវមានកូនមិនខាន ព្រោះហេតុនោះ ដើម្បីមានកូនហើយត្រូវមានសុភមង្គលល្អដល់កូនយើង កាលណាដឹងថាមានទារកមកបដិសន្ធិក្នុងគភ៌យើងហើយ ត្រូវតែទៅជួបលោកវេជ្ជបណ្ឌិត (ពេទ្យ) ដើម្បីដឹងពីសុខភាពរបស់កូន ឬត្រូវចាក់ថ្នាំការពារយ៉ាងណា តាមវេជ្ជបញ្ជារបស់ពេទ្យ យើងមិនត្រូវទៅចាក់ថ្នាំផ្តេសផ្តាសនោះទេ ។ ពេទ្យសព្វថ្ងៃនេះ គេទំនើបជាងពីមុនច្រាយ យើងត្រូវចាក់ថ្នាំឱ្យបានទៀងទាត់ទៅតាមវេជ្ជបញ្ជា ដើម្បីថែរក្សាទារកក្នុងផ្ទៃឱ្យមានសុខភាពល្អ ហើយក៏ដើម្បី

ជាប្រយោជន៍ដល់យើងជាម្ដាយផង ដែរ ។ ការចាក់ថ្នាំមិន មែនការពារតែទារកក្នុងផ្ទៃទេ គឺការពារទាំងម្ដាយផងដែរ ។ យើងត្រូវហូបម្ហូប អាហារណា ដែលមិនប៉ះពាល់ដល់ទារក ហើយត្រូវហូបអាហារណា ដែលមានវីតាមីនល្អៗទាំងអស់ ដែលអាចជួយឱ្យទារកធំធាត់ល្អ និងមានសុខភាពល្អដល់ពេល ប្រសូតមក ។ កាលយើងបរិភោគអាហារមានវីតាមីនល្អ ៗ នោះ មិនមែននាំឱ្យមានសុខភាពល្អដល់ទារកប៉ុណ្ណោះទេ វាថែមទាំង ធ្វើឱ្យទារកមានបញ្ញាយ៉ាងល្អ ចាប់ចងចាំរៀនអ្វីៗតែងតែចេះ និងឈ្លាសក្នុងការងារទាំងពួង ។ សំខាន់ណាស់សម្រាប់ឪពុក ម្ដាយ សូមកុំបណ្ដែតបណ្ដោយថា វាមិនមានបញ្ហាអ្វីទេ ចេះតែ ហូបឱ្យតែបានទៅ ។ យើងត្រូវដឹងថា ការយើងគិតយ៉ាងនេះ យើងឈ្មោះថា ធ្វើឱ្យកូនយើងមានកម្លាំងខ្សោយ សុខភាពមិន ទៀង មានជម្ងឺរ៉ាំរ៉ៃជានិច្ច ប្រាជ្ញាស្មារតីខ្សោយនេះ សុទ្ធតែជា



ទោស របស់យើងជាឪពុកម្ដាយទាំងអស់ ដែលយើងធ្វើចំពោះ កូនជាទីស្រលាញ់របស់យើង ។ ម្យ៉ាងទៀតខ្លួនយើង ពេលមាន ផ្ទៃពោះគួរបន្ថយការធ្វើការងារធ្ងន់ធ្ងរចេញ ធ្វើតែការងារណា ដែលអាចធ្វើបានបន្តិចបន្តួច មិនប៉ះពាល់ដល់ទារកក្នុងផ្ទៃ ។ ចំណែកឪពុកវិញក៏ត្រូវដឹងថា ភរិយាមានផ្ទៃពោះហើយការងារ ណាដែលភរិយាយើងធ្លាប់ធ្វើមក យើងត្រូវធ្វើជំនួសមិនត្រូវ ប្រចាំនឹងភរិយារបស់យើងទេ យើងត្រូវដឹងថាពេលនេះ គ្នាមាន ផ្ទៃពោះហើយ ហើយនាងត្រូវធ្វើជាម្ដាយដ៏ល្អរបស់កូនយើង ទៀត ។ កាលយើងធ្វើប៉ុណ្ណោះ ឈ្មោះថា ធ្វើដើម្បីកូនជាទី ស្រលាញ់របស់យើងទាំងអស់ ។ ធម្មតាឪពុកម្ដាយតែងតែមាន នូវព្រហ្មវិហារធម៌ ៤ យ៉ាងសម្រាប់កូន បើមិនមានទេ តើកូនជា ទីស្រលាញ់ អាចរស់នៅក្នុងលោកដូចម្ដេចបាន ។ ពេលដែល

មានទារកមកនៅក្នុងផ្ទៃយើងត្រូវមានទូវ **មេត្តា** ចំពោះទារកសព្វៗកាល ។



ពេលជិតសម្រាលកូនឬឆ្លងទន្លេនេះ ជាភារកិច្ចសំខាន់ទាំងម្ដាយទាំងឪពុក ។ យើងត្រូវចាត់ចែងនូវទីសម្រាលឱ្យបានស្រួល បើកូនដំបូងច្រើនតែលំបាកសម្រាល គួរទៅកាន់មន្ទីរពេទ្យ ដើម្បីសម្រាលនៅទីនោះ ។ តែតាម ជនបទភាគច្រើនសម្រាលនៅនឹងផ្ទះ មានលោកយាយឆ្មបមកប្រចាំការ ។ ពេលសម្រាលភរិយាជាស្រីនាងមានការភិត ភ័យជាខ្លាំង ព្រោះហេតុនោះ យើងជាប្ដីគួរនៅជិតមិនត្រូវទៅ ឆ្ងាយទេ គួរនៅផ្ដល់កម្លាំងចិត្តឱ្យនាង សម្រាលបានស្រួល ត្រូវចេះនិយាយពាក្យលួងលោម ផ្អែមល្ហែមចំពោះប្រពន្ធ ធ្វើអាការៈឱ្យជាអ្នកពេញចិត្តចំពោះប្រពន្ធនិងទារក ដែលត្រូវសម្រាលមក ។

ពេលបានជោគជ័យក្នុងភារកិច្ចដ៏ធំនេះហើយ យើងត្រូវកត់ត្រាពេលវេលាកូនសម្រាលមក ថ្ងៃ ខែ ឆ្នាំ ខាងសុរិយាគតិនិងចន្ទគតិឱ្យបានច្បាស់លាស់ ដើម្បីទុកឱ្យកូនជាទីស្រលាញ់របស់យើងនឹងបានដឹង ហើយត្រូវមានសំបុត្រពេទ្យដែលបញ្ជាក់ ពីទីកំណើតនិងបញ្ជីសៀវភៅគ្រួសារ ។

យ៉ាងតិចរយៈពេល ៥ ថ្ងៃក្រោយសម្រាលហើយ យើងត្រូវដាក់ឈ្មោះឱ្យកូនឬមានឈ្មោះថា "**នាមគ្គហណទិវា**" ថ្ងៃសម្រាប់ដាក់ឈ្មោះឬ ខ្មែរតែងហៅថា "ថ្ងៃបង្កក់ឆ្មប" ជាទំនៀមប្រពៃណីខ្មែរ ។ ខ្មែរយើងមានជំនឿទៅលើការដាក់ឈ្មោះកូននេះណាស់ពីសម័យមុនមក ដូចជា កូនត្រូវកើតថ្ងៃព្រហស្បតិ៍ ត្រូវដាក់អក្សរ **ប ផ ព ភ ម** នេះខាងដើមមានឈ្មោះថា បញ្ញិន្ទជាដើម ហើយការដាក់ឈ្មោះនេះត្រូវមាន បីព្យាង្គមានម_គណៈជាដើម ។ ពិធីនៃការដាក់ឈ្មោះ

ត្រូវមានជីដូនជីតា មា មីងញាតិមិត្តមកជួបជុំគ្នា ដើម្បីសម្តែងនូវទឹកចិត្តស្រលាញ់ចំពោះទារកដែលទើបកើតមក ។ ម្យ៉ាងទៀត ជាការបញ្ជាក់ពីសេចក្តីត្រេកអររបស់ឪពុកម្តាយ ដែលមានសមាជិកថ្មី ។

យើងកុំភ្លេចថា ពីសម័យមុនមិនទាន់មានពេទ្យទំនើប យើងសម្រាលហើយ ត្រូវផឹកថ្នាំខ្មែរទាំងថ្នាំង ។ ដើម្បីឱ្យមានទឹកដោះឱ្យទារកមានសុខមាលភាពល្អ តែឥឡូវនេះយើងកុំភ្លេចថា មានពេទ្យទំនើបយើងត្រូវចូលទៅរកវេជ្ជបណ្ឌិត ដើម្បីឱ្យលោកគ្រូពេទ្យពិនិត្យមើល តើមានអាការៈប្លែកយ៉ាងណាខ្លះ ហើយចំណុចមួយទៀត ជារឿងល្អសម្រាប់កូនយើងនោះគឺពេទ្យគេមានថ្នាំចាក់ការពារជម្ងឺថ្លើមប្រភេទបេ ក្រោយពីទារកកើតមក ៧ ថ្ងៃ យើងត្រូវទៅចាក់ថ្នាំការពារកុំឱ្យកូនយើងមានជម្ងឺនេះ ដើម្បីឱ្យកូនយើងមានសុខភាពល្អ មិនមានជម្ងឺរ៉ាំរ៉ៃប្រចាំកាយ ។ ប្រសិនបើមានវេជ្ជបញ្ជាអំពីពេទ្យ យ៉ាងណាៗនោះ យើងត្រូវទៅចាក់ថ្នាំឱ្យកូនយើងបានទៀងទាត់មិនត្រូវខកខានទេ ។

## ៧.ត្រូវគិតថា កូនជាមនុស្សសំខាន់សម្រាប់យើង

យើងកុំគិតឃើញថា កូនជាផលដែលបានមកពីរាគៈរបស់យើងតែម្យ៉ាងឱ្យសោះ កាលយើងគិតយ៉ាងនេះ យើងមិនជាអ្នកយកចិត្តទុកដាក់ចំពោះកូនឡើយ មិនព្យាយាមចិញ្ចឹមកូនឱ្យល្អ យ៉ាងណាក៏ដោយកូនវាជាឈាមជ័ររបស់យើងទាំងពីរនាក់ផងដែរ ។ កាលដែលយើងមានកូនទៅបានអាស្រ័យការប្រជុំព្រមនៃបច្ច័យ ៣ គឺ ៖

១.មាតាបិតានៅរួមគ្នា

២.មាតាមានរដូវ

៣.សត្វអ្នកកើតក្នុងគភ៌[១៨]

ការប្រជុំរួមធម៌បីនេះ ទើបតាំងគភ៌ឡើងបាន ម្យ៉ាង ទៀតអ្នកដែលកើតឡើងជា មនុស្សត្រូវអាស្រ័យ បុណ្យកុសល ដែលគេធ្វើទុកមកហើយផង មិនមែនយើងទៅធ្វើឱ្យកូនកើត ស្រេចតែចិត្តនោះទេ ។ បើយើងអាចបង្កើតកូនបានហេតុអ្វី យើងមិនបង្កើតចិត្តគំនិតរបស់កូនឱ្យដូចយើងផង ពោលដោយ សន្មត យើងជាអ្នកបង្កើតកូន តែដោយពិតវាអាស្រ័យគ្នាទើប បានមានពាក្យថា **“កូន”** ។ ទោះជាការមានកូនវាអាស្រ័យ ទៅលើខ្លួនយើងផង អាស្រ័យបុណ្យរបស់កូនផងក៏ដោយ តែ យើងឈ្មោះថា ជាឪពុកម្ដាយ ជាអ្នកមានភារកិច្ចចិញ្ចឹមកូន ដែលបានកើតមកហើយឱ្យទៅជាកូនដ៏ល្អម្នាក់ ។ តាមក្នុង ព្រះពុទ្ធសាសនាកូនមានពីរប្រភេទគឺ កូនបុណ្យ ១ កូនបាប ១ ។

[១៨] សមន្តប្បាសាទិកា ២ /២៨



កូនបុណ្យ ជាកូននាំមកនូវសេចក្ដីចម្រើនក្នុងគ្រួសារ ដូចអ្នកបដិសន្ធិក្នុងផ្ទៃម្ដាយធ្វើឱ្យកើតមានសេចក្ដីសុខ ទាំងផ្លូវ កាយផ្លូវចិត្ត ដូចជាឪពុកម្ដាយមានជម្ងឺក៏វិនាសចាកជម្ងឺ ត្រូវ មានឧបទ្រពចង្រៃកើតឡើង ត្រូវវិនាសបាត់ ហើយមានតែ សេចក្ដីសុខសុភមង្គលតែម្យ៉ាង មិនមានទុក្ខប្រឡូកប្រឡំ ដូច “ព្រះមហោសថ”ពេលប្រសូតមក ធ្វើឱ្យឪពុកវិនាសចាករោគ ឈឺក្បាលជាដើម ។ កាលយើងបានកូនបុណ្យមកកើតជាមួយ នោះ វាសុទ្ធតែជាបុណ្យរបស់យើងសាងមក មិនមែនព្រះជា ម្ចាស់ឯណា ជាអ្នកប្រទានឱ្យឡើយ សុទ្ធតែបានមកដោយ កុសលកម្មដែលយើងបានធ្វើមកហើយ ព្រោះហេតុនោះ បុរស ស្ត្រីដែលប្រាថ្នាចង់បានកូនល្អមកកើតជាមួយ ត្រូវខំធ្វើបុណ្យ កុសលឱ្យបានច្រើន ដូចជាត្រូវឱ្យទានដល់សមណព្រាហ្មណ៍ ក្នុងព្រះពុទ្ធសាសនា ឬពួកយាចក ។ យើងអាចធ្វើឱ្យខ្ពស់ជាង

នោះទៀត គឺ ការរក្សាសីល ៥ ឱ្យបានជាប់ជានិច្ចកាល កុំគិតថា ក្រែងរក្សាសីលទៅរកស៊ីយ៉ាងម៉េចកើត ! គំនិតនេះ ជាគំនិតមនុស្សល្ងង់ខ្លៅ មិនមានបញ្ញា មិនឃើញថាការមាន សីលមានអានិសង្សយ៉ាងណាក្នុងបច្ចុប្បន្ន នាំមកនូវសេចក្តី សុខយ៉ាងណាដល់គ្រួសារយើង ។ កាលបើយើងមានកូនបុណ្យ មកកើតជាមួយនឹងយើង ហើយខ្លួនយើងមិនត្រូវលះបង់បុណ្យ កុសលចោលឡើយ ព្រោះថា បុណ្យកាលណាឱ្យផលហើយ ក៏អាចអស់ទៅដែរ ព្រោះហេតុនោះ ត្រូវសន្សំបុណ្យឱ្យបាន ច្រើន ដើម្បីឱ្យមានកូនបុណ្យមកកើតនឹងយើងទៀត រហូតគ្រប់ៗ ជាតិ ។ កាលបានកូនបុណ្យធ្វើឱ្យយើងមានចិត្តរីករាយសប្បាយ មិនមានមន្ទិលសៅហ្មងទាំងថ្ងៃ ទាំងយប់ មិនមានកង្វល់ក្រែង កូនខិលខូច អាចទៅធ្វើអំពើអាវ៉ាសែ ។

កូនបាប ជាកូននាំមកនូវវិបត្តិផ្សេងៗក្នុងគ្រួសារគ្រាន់ តែមកបដិសន្ធិក្នុងផ្ទៃពោះម្តាយក៏ធ្វើឱ្យម្តាយមានជម្ងឺ ដូចក្តៅ ពោះជានិច្ចឬត្រូវមានជម្ងឺឈឺរ៉ាំរ៉ៃ ធ្វើឱ្យឪពុកម្តាយមានរឿង ឈ្លោះទាស់ទែងគ្នា រហូតដល់កើតមកក៏នាំរឿងលំបាកច្រើន មកឱ្យឪពុកម្តាយជាអ្នកដោះស្រាយ ។ សូមឪពុកម្តាយដែល មានកូនបាបមកកើតជាមួយ យើងត្រូវដឹងថា នេះសុទ្ធតែជា បាបរបស់យើង ដែលបានធ្វើមកហើយ ព្រោះយើងមិនបានធ្វើ បុណ្យទុក ទើបយើងជួបប្រទះកូនបាប ។ កូនបាបគឺកូនមាន ពៀរជាមួយយើងពីអតីតជាតិ ធ្លាប់ចងពៀរនឹងគ្នាមក កាល បើយ៉ាងនោះ យើងមិនត្រូវចងពៀរជាមួយកូនបាបឱ្យថែម ខ្លាំងទៀតទេ កុំយកបាបទប់ទល់ជាមួយបាប គឺកុំយកអំពើ អាក្រក់ ទៅទប់ទាល់ជាមួយកូនបាបឱ្យសោះ ត្រូវយកអំពើល្អ ផ្អែមល្ហែមទៅទប់ទល់វិញ ត្រូវមានខន្តិធម៌ឱ្យបានស្មើចំពោះ

កូនបាបយើងត្រូវដឹងថា ព្រះសម្មាសម្ពុទ្ធជាសាស្តាក្នុងលោក ទ្រង់ត្រាស់ថា ៖

**ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ**

**អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។**



ពិតមែនតាំងពីកាលណាមកក្នុងលោកនេះ ពៀរទាំងឡាយមិនរម្ងាប់ ដោយពៀរឡើយ ពៀរទាំងឡាយតែងរម្ងាប់ដោយការមិនមានពៀរ នេះជាបវេណីធម៌[១៩] ។

យើងជាពុទ្ធសាសនិកក៏បានដឹងហើយថា ពៀរមិនស្ងប់ដោយពៀរ កាលបើយ៉ាងនោះ យើងមានកូនបាបមិនត្រូវយកបាបទៅតបតទេ ដូចភ្លើងជិតរលត់ទៅហើយ យើងក៏យកសាំងចាក់ថែមឱ្យឆេះខ្លាំងទៀត ឬភ្លើងកំពុងឆេះខ្លាំងយកសាំង

[១៩] សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា ៥២/២២ ,ធម្មបទដ្ឋកថា ១/៧២

ទៅចាក់ទៀត ភ្លើងនោះកាន់តែឆេះខ្លាំងឡើងជាទ្វេ ដូចកូនបាប យើងធ្វើអំពើបាបតបទៅវិញ វានាំឱ្យបាបកាន់តែរីកចម្រើនខ្លាំងជាងមុនទៀត ។



យើងត្រូវពិចារណាពាក្យថា **កម្មស្សកោម្හិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមិ** ។ អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាមត៌ក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរលឹក អាត្មាអញនឹងធ្វើនូវកម្មណា ទោះល្អក្តី អាក្រក់ក្តី នឹងជាអ្នកទទួលនូវផលនៃកម្មនោះ[២០] ។

ដូច្នេះ កូនបាបជាផលនៃបាបកម្ម ដែលយើងបានធ្វើមកហើយ យើងត្រូវទទួលដោយញញឹមនូវផលនេះចុះ មិនត្រូវ

[២០] សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត ៤៤/១៤៦

គ្រាំគ្រា ទុក្ខទោម្នេញ ឡើយ ធ្វើដូចម្តេចដែលយើងអាចជៀស ផុតពីបាបកម្ម ដែលយើងធ្វើមកបាន សូម្បីតែព្រះសម្ពុទ្ធទ្រង់ ជាកំពូលក្នុងលោក ព្រះអង្គទ្រង់ត្រាស់ដឹងនូវអនុត្តរសម្មា-សម្ពោធិញ្ញាណនៅតែព្រះអង្គគេចពីបាបកម្មមិនបាន ដូចត្រូវ ភិក្ខុទេវទត្តប្រមៀលថ្មទម្លាក់កិន ចេញព្រះលោហិតពីព្រះបាទ ជាដើម ឬ ព្រះអរហន្តមានព្រះមោគ្គល្លានជាដើម ត្រូវចោរ ៥00 នាក់ វាយរហូតបរិនិព្វាន នេះសុទ្ធតែជាផលនៃបាបកម្ម ចុះទម្រាំយើងជាបុគ្គលធម្មតាមិនមានឫទ្ធិអភិញ្ញា ដូចព្រះសម្ពុទ្ធ ឬព្រះ អរហន្តនោះ តើយើងអាចគេចផុតពីបាបកម្មដូចម្តេច កើត ។ ព្រោះហេតុនោះ យើងត្រូវយល់ព្រមល្មមជាមួយផល នៃបាបដែលយើងបានធ្វើ ហើយទទួលផលនៃនូវបាបកម្មនោះ ចុះដោយមិនចង់កែសេចក្តីពិត ។ កាលយើងយល់ព្រមថា នេះ ជាបាបរបស់យើងឱ្យផល ធ្វើឱ្យចិត្តយើងមិនសោកសៅទុក្ខទោ ម្នេញក្នុងរឿង ដែលមានកូនបាបនោះឡើយ ។

កាលមានកូនបាបត្រូវណែនាំទៅតាមផ្លូវព្រះធម៌ ផ្លូវ សុចរិត ឬ អាចឱ្យកូនបួសរៀនព្រះធម៌ព្រះវិន័យ ដើម្បីយល់ ពីអំពើល្អ ដែលខ្លួនត្រូវសាងសន្សំ ។ កាលកូនបួសរៀន ក្រែងមានឧបនិស្ស័យក្នុងព្រះពុទ្ធសាសនា ហើយអាចទៅជា មនុស្សល្អម្នាក់នៅក្នុងសង្គមនឹងគេ ។ តែបើកូនមិនចង់បួស រៀនទេ កុំចេះតែបង្ខំឱ្យបួសក្រែងខូចព្រះពុទ្ធសាសនា នាំឱ្យ មានមន្ទិលក្នុងធម៌វិន័យ ព្រោះថា បួសទៅអាចទៅជាអ្នក ខិលខូច រហូតប្រព្រឹត្តខុសធម៌វិន័យនៃព្រះពុទ្ធសាសនា ។ កាលបើកូនចង់បួស ត្រូវឱ្យកូនទៅបួសក្នុងសម្នាក់គ្រូអាចារ្យ ឧបជ្ឈាយ៍ត្រឹមត្រូវ ជាអ្នកចេះដឹងព្រះត្រៃបិដក អដ្ឋកថា ដីកា ខ្មាសបាប ខ្លាចបាប ប្រាថ្នាសិក្សាមានការប្រព្រឹត្តិព្រហ្មចរិយ-

ធម៌ ដើម្បីព្រះពុទ្ធសាសនាតែម្យ៉ាង មិនជាភិក្ខុសម្លឹងលាភជាធំ គិតតែពីតិរច្ឆានកថា និយាយពាក្យគ្រោតគ្រាត មិនសម្គួរជាសមណៈសក្យបុត្តិយ៍ ប្រព្រឹត្តឡេះឡោះមិនសង្រួមឥន្ទ្រិយ មានតែការលេងសើច មើលទូរទស្សន៍ ស្តាប់ចម្រៀង ប្រឡែងគ្នា មិនគិតពីសីល សិក្ខា ដែលខ្លួនជាអ្នកបួស មានអាការៈមិនខុសពីកូនអ្នកស្រុក ។ ម្យ៉ាងទៀត គ្រូអាចារ្យខ្លះគិតតែពីមន្តអាគម ខ្សែយ័ន្ត កថា ដើម្បីឱ្យពុទ្ធបរិស័ទចូលចិត្ត អ្នកបួសទាំងនេះមិនត្រូវឱ្យកូនបួសជាមួយឡើយ វាអាចធ្វើឱ្យកូនយើងក្លាយជាមនុស្សពាលកាន់តែខ្លាំង ព្រោះកាលទៅបួសនោះ មិនបានហ្វឹកហាត់អប់រំខ្លួនឱ្យកាន់តែខ្លាំង មានតែទៅបន្ថែមឱ្យកាន់តែខូចថែម ។ អ្នកបួសក្នុងសាសនានេះ មិនមែនចេះតែល្អទាំងអស់ទេ អ្នកខ្លះបួសដើម្បីលាភសក្ការៈ បួសដើម្បីឱ្យគេសរសើរ បួសដើម្បីបានទ្រព្យ បួសខ្លះដើម្បីរៀនមុខវិជ្ជាអង់គ្លេស ថៃ



ចិន ជប៉ុន កុំព្យូទ័រ បាលី ដើម្បីគ្រាន់តែចិញ្ចឹមជីវិត ។ អ្នកដែលល្អបួសប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីលើកស្ទួយព្រះពុទ្ធសាសនា ដោយសិក្សាព្រះធម៌ព្រះវិន័យរបស់ព្រះសម្មាសម្ពុទ្ធហើយ មានការបដិបត្តិយ៉ាងហ្មត់ចត់ត្រឹមត្រូវ សូម្បីសិក្ខាបទមួយ ក៏មិនហ៊ានប្រព្រឹត្តកន្លងសោះ អ្នកបួសទាំងនេះត្រូវឱ្យកូនយើងទៅបួសរៀនក្នុងសម្នាក់លោកដើម្បីបានជាកូនល្អក្នុងព្រះពុទ្ធសា-សនា ទោះជាមិនចង់បួសតទៅទៀត សឹកមកក៏នៅរក្សាធម៌បានល្អ ដូចជារក្សាសីល ៥ ជាដើម ទាំងនេះក៏ដោយសារយើងឱ្យកូនបួសក្នុងសម្នាក់អ្នកបួសត្រឹមត្រូវ ធ្វើឱ្យកូនយើងបានសេពគប់ជាមួយបណ្ឌិតសប្បុរស រហូតក្លាយទៅជាសប្បុ-រសផងដែរ ។ ខ្លួនខ្ញុំអ្នកសរសេរសៀវភៅនេះផ្ទាល់ធ្លាប់បានឪពុកម្តាយនាំឱ្យទៅបួសក្នុងសម្នាក់ភិក្ខុសាមណេរមិនល្អ ខ្ញុំក៏

ទៅជាអ្នកបួសមិនល្អមិនសិក្សារៀនសូត្រ រហូត ៣_៤ ឆ្នាំ ទើបភ្ញាក់ខ្លួនទៅសិក្សាក្នុងសម្នាក់អ្នកបួសត្រឹមត្រូវ ប្រឹងរៀនសូត្រ ទើបក្លាយទៅជាអ្នកចេះដឹងធម៌អាចំក្នុងបិដក អដ្ឋកថា ខ្លះៗ ។ ដូច្នេះបានខ្ញុំពោលថា ការឱ្យកូនបួសត្រូវឱ្យបួសក្នុងសម្នាក់អ្នកចេះធម៌វិន័យពិត ៗ ទើបកូនយើងអាចទៅជាអ្នកចេះដឹងទាំងផ្លូវធម៌ ផ្លូវលោកយ៉ាងល្អទៅបាន ។ យើងត្រូវជឿថា **"ធម៌សេពគប់នេះជាគុណធម៌ល្អវិសេសបំផុត"** ។



## ៨.កូនមានបីពួក

ក្នុងព្រះពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា កូនមានបី [២១] ពួកគឺ ៖

**១.អតិជាតបុត្រ**

**២.អនុជាតបុត្រ**

[២១] សុត្តន្តបិដក ឥតិវុត្តក: តិកនិបាត ៥៣/ ៨៤

**៣.អវជាតបុត្រ**

ក្នុងបណ្តាកូនទាំងបីពួកនេះ លោកអធិប្បាយថា កូនដែលជាអតិជាតបុត្រជាកូនបុណ្យ ដោយថា កូននេះមិនមានឪពុកម្តាយទូន្មានទេ ខ្លួនចេះដឹងនូវអំពើខុសត្រូវ ដោយខ្លួនឯងរហូតខ្លួនបានដល់ព្រះត្រៃសរណគមន៍គឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាសរណ:ជាទីពឹងទីរលឹក និងជាអ្នកសមាទានសីល ៥



ជាអ្នកមិនសម្លាប់សត្វ មិនលួចទ្រព្យសម្បត្តិគេ មិនប្រព្រឹត្តខុសក្នុងកាម មិននិយាយកុហក មិនផឹកទឹកស្រវឹង ឬ អាចជាអ្នកសមាទានសីល ៨ និងសីល ១០ ឬ មានសទ្ធាដោយខ្លួនឯង ចេញប្រព្រឹត្តនូវនេក្ខម្ម:គឺការបួសដើម្បីបំពេញកុសល ដោយខ្លួនឯង ដោយមិនមានឪពុកម្តាយ ឬ បងប្អូនបបួលដឹកនាំឡើយ ។ កាលខ្លួនបានប្រព្រឹត្តនូវអំពើល្អយ៉ាងនេះ ក៏អាចបបួលដឹកនាំឪពុកម្តាយឱ្យដើរក្នុងគន្លងល្អ ដូចជាឱ្យគាត់ដល់ព្រះត្រៃសរណគមន៍

រក្សាសីល ៥_៨_១០ ជាដើម ។ នេះឈ្មោះថា ដឹកនាំគាត់ឱ្យមាន សទ្ធា សីល ចាគៈ និងបញ្ញា ដើម្បីជាប្រយោជន៍ក្នុងលោកនេះ និងបរលោក ។ កូនដែលមានគុណធម៌យ៉ាងនេះឈ្មោះថា **ជាអតិជាតបុត្រ** ។

ចំណែកអនុជាតបុត្រ ជាកូនដែលដើរតាមគន្លងដំបូន្មាន របស់ឪពុកម្តាយ ។ ឪពុកម្តាយទូន្មានឱ្យដើរតាមផ្លូវល្អជាសុចរិត ក៏ធ្វើតាមមិនឱ្យខុសឆ្គាំឆ្គងឡើយ ជាបុគ្គលងាយទូន្មានប្រៀនប្រដៅហៅថា **"សោវចបុគ្គល"** បុគ្គលងាយប្រដៅ ។ ទោះមានកំហុសខ្លះ តែអាចកែប្រែបាន មិនមែនរឹងរូសឡើយ នេះព្រះសម្ពុទ្ធទ្រង់ត្រាស់ថា **អនុជាតបុត្រ** ។

អតិជាតបុត្រនិងអនុជាតបុត្រនេះ ចាត់ជាកូនបុណ្យដែលកើតក្នុងផ្ទៃរបស់យើង ធ្វើឱ្យយើងមានសេចក្តីសុខរុងរឿងចម្រើនកើតសុភមង្គលក្នុងគ្រួសារ ។

ចំណែកកូនពួកទី ៣ ជាកូនបាបមិនចេះដឹងដោយខ្លួនឯង ហើយមិនស្តាប់តាមពាក្យប្រៀនប្រដៅរបស់ឪពុកម្តាយ គិតតែពីរឿងសប្បាយភ្លើតភ្លើន គេចសាលា ដើរលេងមានមិត្តភក្ក្រ សុទ្ធតែជាអ្នកខិលខូច ខ្ជិលច្រអូស រហូតទៅប្រព្រឹត្តធ្វើអំពើថោកទាប មានលួច ប្លន់អ្នកដទៃជាដើម និងឈ្មោះថា **ជាបុគ្គលពាល** ឬពាក្យសម័យឥឡូវថា **ជើងកាង** ។កូនជំពូកនេះព្រះសម្ពុទ្ធទ្រង់ត្រាស់ថា **អវជាតបុត្រ** ។

អវជាតបុត្រជាកូនបាប ដែលបានរៀបរាប់មកពីខាងដើមហើយ ។ ដើម្បីកុំឱ្យយើងជួបប្រទះកូនបាប ខ្លួនយើងជាឪពុកម្តាយត្រូវធ្វើបុណ្យទាន រក្សាសីលឱ្យបានល្អ ហើយសច្ចាប្រាថ្នា សូមឱ្យជួបតែកូនបុណ្យ ដោយអំណាចបុណ្យដែលបានធ្វើនេះ ។ ព្រោះហេតុអ្វី ទើបត្រូវប្រាថ្នាកូនបុណ្យ

ព្រោះថា **កូនបុណ្យនាំមកនូវសេចក្តីចម្រើន កូនបាបនាំមកនូវសេចក្តីវិនាស** ដូចព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ៖

**អតិជាតំ អនុជាតំ បុត្តមិច្ឆន្តិ បណ្ឌិតា**
**អវជាតំ ន ឥច្ឆន្តិ យោ ហោតិ កុលគន្ធនោ**
**ឯតេ ខោ បុត្តា លោកស្មឹ យេ ច ភវន្តិ ឧបាសកា**
**សទ្ធាសីលេន សម្បន្នា វទញ្ញូ វីតមច្ឆរា**
**ចន្ទោ អព្ភឃនា មុត្តោ បរិសាសុ វិរោចតិ**



បណ្ឌិតទាំងឡាយ តែងប្រាថ្នាអតិជាតបុត្រនិង អនុជាតបុត្រ មិនប្រាថ្នាអវជាតបុត្រ ដែលជាកូនផ្តាច់បង់ត្រកូលឡើយ ។ កូនទាំងនោះឯងតែងមានក្នុងលោក ម្យ៉ាងទៀត កូនទាំងឡាយណាជាឧបាសក (កូនទាំងនោះ) ឈ្មោះថា ជាអ្នកបរិបូណ៌ដោយសទ្ធានិងសីល ជាអ្នកដឹងពាក្យពេចន៍ ជាអ្នកប្រាសចាកសេចក្តីកំណាញ់ រមែងរុងរឿងក្នុងពួកបរិស័ទ ដូចជាព្រះច័ន្ទដែលផុតស្រឡះហើយចាកដុំនៃពពកដូច្នោះ ។

សូមបញ្ជាក់ដល់ឪពុកម្តាយ ដែលមានកូនបាបផងថា យើងមិនត្រូវធ្វើអ្វីជាអំពើអាក្រក់ឱ្យដល់កូននោះឡើយ វាអាចទៅជារឿងគុំគួនចំពោះយើងកាន់តែខ្លាំងឡើង ។ ដូចជាវាយដំធ្លាក់ ប្រើអំពើហិង្សាទប់ទល់ជាមួយកូននោះ វាទៅជារឿងមួយដែលខុសពីធម៌ ដែលព្រះពុទ្ធទ្រង់ឱ្យយើងមានខន្តិធម៌ មេត្តាធម៌ចំពោះសព្វសត្វ ។ តែខ្លួនយើងត្រូវបណ្តុះគុណធម៌ឱ្យកូនដូចជាតែងនិយាយពោលសរសើររឿយ ៗ អំពីគុណតម្លៃសីល ៥ ហើយត្រូវឱ្យកូនឃើញពីទោសនៃបុគ្គលមិនមានសីល យើងក៏អាចដឹងថា មនុស្សលោកយើងនេះ ដែលប្រព្រឹត្តខុសមានចំណុចធំ ៗ ៥ គឺ ៖

១.ទៅសម្លាប់សត្វ បៀតបៀនសត្វ

២.ទៅលួចទ្រព្យគេ

៣.ប្រព្រឹត្តខុសក្នុងកាម ចំពោះកូន ប្រពន្ធអ្នកដទៃ

៤.និយាយកុហកបោកប្រាស់

៥.ផឹកសុរា គ្រឿងញៀនបំផ្លាញសតិស្មារតី

រឿងធ្វើខុសមិនមានការប្រព្រឹត្តដទៃឱ្យក្រៃលែងជាងការមិនមានសីល ៥ នេះទេ ។ ការយើងណែនាំរឿយៗ នាំចូលរួមក្នុងកម្មវិធីបុណ្យសន្ទនាធម៌ សាកច្ឆាធម៌អាថ៌ ហើយឱ្យកូនអង្គុយស្តាប់ដោយយកចិត្តទុកដាក់ ។ ឪពុកម្តាយមិច្ឆាទិដ្ឋិខ្លះ មិនហ៊ានឱ្យកូនស្តាប់ធម៌ទេ មិនឱ្យកូនទៅវត្តទេ ខ្លាចកូនចេះធម៌រកស៊ីមិនកើត នេះជាគំនិតមនុស្សល្ងង់ខ្លៅដែលគិតថា ធម៌ជារឿងធ្វើឱ្យមនុស្សលោកល្ងង់ មនុស្សស្តាប់ធម៌ ចេះធម៌ធ្វើការងាររកស៊ីមិនកើត...។ យើងជាអ្នកឆ្លាតត្រូវចេះនាំកូន



ទៅស្តាប់ធម៌ធ្វើបុណ្យឱ្យទានដើម្បីឱ្យកូនក្លាយទៅជាមនុស្សល្អក្នុងលោកនេះ ។ ព្រោះថា កូនទោះជាខិលខូចយ៉ាងណា កាលបានជួបសប្បុរសហើយ ក៏អាចមានឧបនិស្ស័យជាមួយសប្បុរស ដោយសារបានសេពគប់ញឹកញយជាមួយអ្នកចេះដឹង អាចដើរទៅតាមផ្លូវល្អបាន ។ ដូចព្រះអង្គទ្រង់ត្រាស់ថា៖

**អសេវនា ច ពាលានំ　　បណ្ឌិតានញ្ច សេវនា**

**បូជា ច បូជនីយានំ　　ឯតម្មង្គលមុត្តមំ ។**

ការមិនសេពគប់ជនពាលទាំងឡាយ ១ ការសេពគប់ជនជាបណ្ឌិតទាំងឡាយ ១ ការបូជាចំពោះបុគ្គលដែលគួរបូជាទាំងឡាយ ១ នេះជាមង្គលដ៏ឧត្តម[២២] ។



[២២] *សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ: ៥២/៤*

ហេតុនោះ ពេលយើងនាំកូនឱ្យទៅជួបបណ្ឌិតសប្បុរស ញយ។ អាចជាបច្ច័យឱ្យកូនដើរតាមគន្លងល្អបាន ។ យើងត្រូវដឹងថា កូនខ្លះឪពុកម្តាយមិនស្តាប់ទេ អ្នកដទៃទើបស្តាប់តាម ព្រោះឪពុកម្តាយជាមនុស្សមានពៀរជាមួយកូននោះ ធ្វើឱ្យកូននោះមិនយកចិត្តទុកដាក់ដើម្បីស្តាប់ ។ មនុស្សនៅក្នុងលោកយើងនេះ មិនមែនចេះតែមានពៀរជាមួយមនុស្សគ្រប់គ្នានោះទេ ។ ដើម្បីកុំឱ្យកូនប្រព្រឹត្តកន្លងសីល ៥ ឪពុកម្តាយគួរតែបណ្តុះគុណធម៌ ៥ ទៀតជាគូនឹងសីល ៥ ដល់កូនគឺ ៖



**១.មេត្តា** ឱ្យកូនចេះមានសេចក្តីស្រលាញ់ចំពោះសត្វទាំងពួង ។ កាលមានសេចក្តីស្រលាញ់ចំពោះមនុស្សសត្វហើយ កូនមិនអាចទៅសម្លាប់អ្នកដទៃ ឬសត្វឡើយ ។

**២.សម្មាអាជីវៈ** ឱ្យកូនរកស៊ីក្នុងផ្លូវសុចរិត កុំឱ្យកេងប្រវ័ញ្ចអ្នកដទៃ បើធ្វើការងាររាជការឱ្យស្មោះត្រង់ចំពោះជាតិ

**៣.សទារសន្តោសៈ** ឱ្យត្រេកអរចំពោះតែប្រពន្ធឬប្តីខ្លួនមិនត្រូវប្រព្រឹត្តខុសចំពោះកូនឬប្រពន្ធប្តីគេ ឬមានសហាយស្មន់ឡើយ ។

**៤.សច្ចៈ** បង្រៀនកូនឱ្យចេះនិយាយពាក្យពិតមានសច្ចៈ មិននិយាយបាតដៃជាខ្នងដៃឡើយ ។

**៥.មជ្ជវិរតិ** ឱ្យកូនវៀរចាកអំពើស្រវឹងពាលា ឱ្យកូនមានសតិគ្រប់គ្រាន់ ឱ្យឃើញទោសគ្រឿងស្រវឹងថា ជាទោសធ្វើឱ្យមនុស្សឱ្យវង្វេង ភ្លេចអ្វីៗទាំងអស់ ។



កាលយើងបានបណ្តុះគុណធម៌ ៥ នេះដល់កូនហើយ កូននៅតែប្រព្រឹត្តអាក្រក់ទៀត យើងគួរផ្សាយនូវមេត្តាធម៌ករុណា ចំពោះកូននិងណែនាំកូនថា ឪពុកម្តាយបានយកចិត្តទុកដាក់ចិញ្ចឹមកូនតាមគន្លងល្អហើយ ឱ្យកូនដើរតាមផ្លូវល្អ កូននៅតែមិនប្រព្រឹត្តល្អទៀត ពេលកូនធ្វើខុសអ្វីមួយ ឪពុក

ម្ដាយមិនធានាខុសត្រូវចំពោះកូនទេ បើកូនមានគ្រួសារទៅលំបាក ក៏មិនមែនលំបាកឪពុកម្ដាយដែរ ។ ចូរកូនដឹងថា ឪពុកម្ដាយ បានរិះរកគ្រប់មធ្យោបាយដើម្បីកូន ហើយកូននៅតែយ៉ាងនេះ សូមកូនប្រព្រឹត្តទៅតាមអំពើដែលកូនធ្វើចុះ តែទោះជាយ៉ាងណា កូនក៏នៅតែឈាមជ័ររបស់ឪពុកម្ដាយដដែល ។ ឪពុកម្ដាយនឹងព្យាយាមដឹកនាំកូនឱ្យដើរផ្លូវល្អ រហូតដល់ឪពុកម្ដាយ លាចាកលោកនេះទៅ ។

ម្យ៉ាងទៀត ត្រូវតែព្យាយាមឱ្យកូនលះបង់នូវបាបធម៌ ៥ ប្រការ ឬហៅថា អបាយមុខ គឺ៖

១.លេងស្រី

២.លេងស្រា

៣.លេងល្បែង

៤.សេពគប់បាបមិត្ត



៥.ខ្ជិលច្រអូស

កាលយើងព្យាយាមចិញ្ចឹមកូនយ៉ាងនេះ ទើបយើងឈ្មោះថា ជាឪពុកម្ដាយល្អរបស់កូន ។ ទោះជាកូនមានកំហុសអ្វីក៏មិនបន្ទោសទៅលើឪពុកម្ដាយបានឡើយ ព្រោះថា ឪពុកម្ដាយលោកព្យាយាមចិញ្ចឹមខ្លួនហើយ តែខ្លួនមិនស្ដាប់តាមពាក្យដំបូន្មានរបស់លោកទាំងពីរ ទើបយើងមានគ្រោះថ្នាក់យ៉ាងនេះ ។

## ៩.កុំបង្រៀនកូនឱ្យខ្ជិលនិងខូច

ឪពុកម្ដាយខ្លះមិនដឹងខ្លួនថា ខ្លួនជាអ្នកបង្រៀនកូនឱ្យខ្ជិលទេ តែត្រឡប់ជាបន្ទោសកូនទៅវិញថា វាខ្ជិលខ្លាំងណាស់ ។ ឪពុកម្ដាយត្រូវដឹងថា កាលកូនអាយុបាន ៥ ឆ្នាំ ទៅ ៨ ឆ្នាំ កូនអាចធ្វើការងារបានខ្លះដូចជា លាងចាន បោសផ្ទះ ជូតឥដ្ឋ

ជូតឡាន ឬ ម៉ូតូ កង់ ជាដើម ការងារនេះសុទ្ធតែជាការងារ ដែលកូននៅតូចតែអាចធ្វើបាន ។ យើងត្រូវចេះប្រើកូនឱ្យធ្វើ មិនត្រូវឱ្យកូនជាប់និស្ស័យខ្ជិលទេជួនកាលយើងគិតថាអាណិត កូន តែយើងត្រូវដឹងថា ពេលនោះកំពុងបង្រៀនកូនឱ្យខ្ជិល ហើយ មិនមែនជាការអាណិតកូនទេ ។ ដូចកូនលេងរបស់វា ដាក់ចោលយើងទៅរើសមក ឬប្រើអ្នកដទៃឱ្យរើសជំនួសម្ដាន អ្នកបម្រើជាដើម នេះសុទ្ធតែបង្រៀនកូនឱ្យខ្ជិលដែរ ។ ថ្ងៃក្រោយកូនអាងអ្នកដទៃរើសយកទុកឱ្យ កូនមិនខ្វីរើសយកទុក រហូតអាចជាអ្នកខ្ជិលច្រអូស ។ ដូចជាពេលលាងចាន គួរប្រើកូនឱ្យលាងមិនត្រូវឱ្យកូនទៅមើលទូរទស្សន៍ ស្ដាប់មាញ៉ៅ ឬដើរលេងទេ ។ បើយើងធ្វើខ្លួនឯងវាជាការបង្រៀនកូនឱ្យខ្ជិល កូននៅក្មេងពី៥ឆ្នាំ ទៅ១៦ ឆ្នាំ កូននៅស្ដាប់តាមបង្គាប់ អាចបង្រៀនកូនឱ្យឧស្សាហ៍ព្យាយាមបាន ។ ពេលរៀនសូត្រ



ត្រូវឱ្យកូនរៀនបានទៀងទាត់នូវមេរៀន ដែលកូនយកមកពីសាលា ឬត្រូវមើលមេរៀន សម្រាប់ ថ្ងៃស្អែកទៀត ។ មិនត្រូវឱ្យកូនមើលទូរទស្សន៍ក្នុងពេលម៉ោងកំពុងរៀននោះទេ តែគួរចែកការមើលឱ្យបានល្អដល់កូន មិនមែនហាមដាច់ខាតមិនឱ្យកូនមើលនោះទេ តែត្រូវមើលឱ្យមានរបៀប ។ ពេលព្រឹកគួរដាស់កូនឱ្យក្រោកពីម៉ោង ៥ ហើយឱ្យកូនរៀនហាត់ប្រាណពត់ខ្លួន ឱ្យសរសៃនិងឈាមដើរបានស្រួល បើធ្វើយ៉ាងនេះ ជាការបង្រៀនកូនមិនទ្រមក់ ។ បន្ទាប់មកឱ្យកូនដុសធ្មេញនឹងប្រាសទន់ល្អ កុំឱ្យខូចធ្មេញកូននិងងូតទឹកស្លៀកពាក់ខោអាវ ទទួលទានអាហារពេលព្រឹក ហើយទៅសាលារៀនទាន់ពេលវេលា ។ បើកូនក្រោកពេលម៉ោង ៦ ទម្រាំដុសធ្មេញ ងូតទឹក ស្លៀកពាក់ ទទួលទានអាហារធ្វើឱ្យកូនទៅសាលាទាំងតក់ក្រហល់ភ្លេចមុខ ភ្លេចក្រោយ នាំឱ្យមានបញ្ញាស្មារតីមិនល្អ ។

ព្រោះហេតុនោះ ត្រូវបង្រៀនកូនឱ្យធ្លាប់ក្រោកពីព្រឹកតាំងពីនៅតូច ជាប់និស្ស័យដល់ធំឡើង មិនហត់នឿយការទូន្មាន ។ កាលកូនមកពីសាលាភ្លាម មិនត្រូវឱ្យកូនញុំាបាយទាំងតក់ក្រហល់ទេ ត្រូវដោះសម្លៀកបំពាក់រៀនចេញហើយឱ្យកូនលាងដៃឱ្យស្អាតឬជូតទឹកចេញ ត្រូវមានសាប៊ូសម្រាប់ដុសលាងដៃ ដុសខ្លួនឱ្យស្អាត សម្រាកបន្តិចទើបឱ្យញុំាបាយ ត្រូវឱ្យកូនមានអនាម័យ ដើម្បីថែរក្សាសុខភាពឱ្យរឹងមាំល្អ ។ ការងារទាំងនេះ បើយើងមិនប្រាប់ មិនបង្គាប់បញ្ជាទេ កូននៅតូចវាមិនដឹងឡើយ ។ យើងកុំចាំឱ្យកូនចេះខ្លួនឯងឡើយ យើងត្រូវដឹងថា កូននៅតូចធ្វើអ្វីទៅតាមឪពុកម្តាយជាអ្នកបង្គាប់បញ្ជា បើយើងចេះតែបណ្តែតបណ្តោយទៅ កូនអាចទៅជាមនុស្សខ្ជិលមិនខាន ទាំងអស់នេះយើងត្រូវដឹងថា វាជាភារៈរបស់យើងជាឪពុកម្តាយតែម្យ៉ាង ដែលយើងជាគ្រូបា



អាចារ្យខាងដើមរបស់កូន ។ កូនអាចទៅជាមនុស្សឧស្សាហ៍មានព្យាយាមគ្រប់ពេលវេលា ក៏ដោយសារយើងជាឪពុកម្តាយ ព្រោះហេតុនោះ កាលកូនយើងរៀនក្នុងថ្នាក់ជាប់លេខ ១ យើងត្រូវឱ្យរង្វាន់ដល់កូន ដើម្បីឱ្យកូនមានទឹកចិត្តព្យាយាមរៀនសូត្រ មិនខ្ជិលច្រអូស រហូតអាចជាទីពឹងរបស់យើងទៅក្នុងអនាគត ។ កាលជីដូនជីតាមកផ្ទះឬញាតិមិត្ត ភ្ញៀវមកត្រូវឱ្យកូនចេះជំរាបសួរ លើកដៃសំពះ ទៅយកទឹកមកជូន ហើយជៀសចេញទៅអង្គុយឆ្ងាយ មិនត្រូវឱ្យមកអង្គុយនិយាយចរចានាំឱ្យភ្ញៀវធុញទេ ។ ត្រូវបង្រៀនឱ្យចេះនិយាយតិច ៗ ឱ្យចេះថែរក្សាភាពស្ងប់ស្ងៀម មិនត្រូវឱ្យប្រលែងគ្នានៅមុខភ្ញៀវឡើយ នេះសុទ្ធតែជាដំបូន្មានត្រូវទូន្មានកូនទាំងអស់ មិនត្រូវឱ្យកូនចេះដោយខ្លួនឯងនោះទេ ។ យើងជាឪពុកម្តាយត្រូវបង្រៀនកូនឱ្យចេះ ដើម្បីថែរក្សាពូជពង្សវង្សត្រកូលឱ្យបានល្អ ។

ម្យ៉ាងទៀត សូមកុំបង្រៀនកូនឱ្យខូចឱ្យសោះ ដូចជាកាលកូននៅតូច បង្រៀនកូនឱ្យចេះជេរ ឪពុកម្ដាយទៅវិញទៅមក ពេលកូនចេះជេរនាំគ្នាសើចរអ៊ឹកថា កូនឆ្លាត តែខ្លួនមិនដឹងថា បង្រៀនកូនឱ្យខូចទេ រហូតដល់កូនជាប់និស្ស័យពូកែជេរអ្នកដទៃ ។ ពេលកូនចេះជេរខ្លួនថា កូនរៀនពីណាចេះជេរ តាមពិតខ្លួនជាអ្នកបង្រៀន ហើយត្រូវទៅបន្ទោសកូន នេះជាកំហុសរបស់យើង ដោយយើងមិនដឹងខ្លួនសោះ ។ ដូចពាក្យកាព្យ ច្បាប់ប្រុសរបស់បណ្ឌិត ម៉ឺន មៃ[២៣] ថា៖

រៀនបទរៀនបាទចំាស    កុំក្រឡាស់លើរៀមច្បង
ស្រដីនឹងអ្នកផង    ពាក្យឲ្យគួរកុំងងរឺ ។
អឺអើអញដាច់សាច់    ច្ឆងពាក្យពេចន៍គេស្រដី

[២៣] សៀវភៅច្បាប់ផ្សេងៗរបស់សហគមន៍សម្ដេច ជួន ណាត ទំព័រទី ៣៣ វាក្យខណ្ឌទី ៥





ដើមជៀលឲ្យអប្រិយ    ស្រដីថាកូនអត់ពូជ ។
ចាស់ទុំមិនប្រដៅ    ជេរកូនចៅទើបវាខូច
គេថាកូនឥតពូជ    មិនដឹងច្បាប់នឹងចាស់ទុំ ។
គេជៀលដល់ម៉ែឪ    គេរ៉ឺអាស្រូវស្អុយរហ៊ឹ
គេស្ដីដើមជៀលជុំ    ដំណើរនោះមកដល់ចាស់។

គ្រាលកូននៅតូចចេះមានដៃជើងទៅលួចរបស់គេ ដូចផ្លែឈើជាដើម យើងមិនហាមឃាត់កូនទេ ថែមទាំងសប្បាយជាមួយកូនទៀត រហូតកូនក្លាយជាអ្នកពូកែលួចមានឈ្មោះថា ចោរ ធ្វើឱ្យយើងអ័ព្វមុខកិត្តិយស នេះដោយសារយើងជាអ្នកបង្រៀនឱ្យកូនខូច ។ ការបណ្ដោយចិត្តកូនខ្លាំងពេក ធ្វើឲ្យពួកគេភ្លេចរាល់ទង្វើដែលគេបានធ្វើ នឹងភាពប្រមាទចំពោះកិច្ចការដែលកូនបានធ្វើតាំងពីតូច ធ្វើឲ្យជាទម្លាប់មួយដោយទម្រើសចិត្តកូននឹងមានភាពរឹងរូស មិនយល់ពីចិត្តអ្នកដទៃរហូតដល់ធំពេញ

វ័យនៅតែមានភាពមិនចុះសម្រុងជាមួយអ្នកដទៃ ដោយសារតែឪពុកម្តាយ មិនបានយកចិត្តទុកដាក់ចំពោះភាពទម្រើសកូន និងភាពស្រឡាញ់កូនខ្លាំងពេក ដោយមានមោហៈមកបិទបាំង មិនយល់ពីភាពខុសច្គងនៃកូនរបស់ខ្លួន បែរជាទៅចោទអ្នកដទៃថា មកនាំកូនរបស់ខ្លួនឲ្យខូចទៅវិញ ។ ភាពទម្រើសនិងការទម្រុនចិត្តកូនបែបនេះហើយ ទើបធ្វើឲ្យកូនរបស់ខ្លួនប្រែក្លាយទៅជាមនុស្សពាល គ្មានសីលធម៌ គ្មានការពិចារណាខ្ពង់ខ្ពស់នឹងប្រកបដោយទោសៈគឺការខឹងនេះឯង ដែលជាហេតុនាំឲ្យមានអំពើវាយដំ ទាត់ធាក់ ធ្វើឲ្យគ្មានសេចក្តីសុខក្នុងរង្វង់គ្រួសារ ។ ដោយការមិនស្តាប់បង្គាប់នោះឯង បណ្តាលឲ្យគ្រួសារទាំងមូល មានការមិនសប្បាយចិត្ត លំបាកក្នុងចិត្តជាពិសេសនោះ គឺឪពុកម្តាយតែម្តង ដែលជាអ្នកព្រួយចិត្តយ៉ាងខ្លាំង ហើយអាចធ្វើឲ្យមានជម្ងឺមកយាយីរាងកាយ ខូចសុខភាព



នឹងធ្វើឲ្យបាត់នូវផលប្រយោជន៍មួយចំនួនដូចជា ការព្យាបាលជម្ងឺ ឬ សងនូវសំណងអន្តរាយដែលបណ្តាលមកពីកូនខូច ។

ធម្មតាឪពុកម្តាយ តែងតែដឹងនូវចំណង់ចំណូលចិត្តរបស់កូនខ្លួន គ្រាន់តែតិចឬច្រើនតែប៉ុណ្ណោះ ទៅតាមការសង្កេតពិនិត្យហើយបន្ថែមពីនេះ យើងអាចដឹងនូវអត្តចរិតរបស់កូនបង្កើតទៀតផង រួមទាំងការបង្រៀនផ្សេងៗ ដើម្បីឲ្យកូនមានចំណេះចេះដឹងក្នុងការងារជីវិតប្រចាំថ្ងៃ ។ ប៉ុន្តែការដឹងអំពីចិត្តរបស់កូននេះគឺមានលក្ខណៈផ្សេងៗទៅតាមឪពុកម្តាយ ដូចជាមានឪពុកម្តាយខ្លះបានបង្ហាញអាកប្បកិរិយា ឲ្យកូនរបស់ខ្លួនដឹងថាឪពុកម្តាយពិតជាស្រឡាញ់កូន ទោះជាកូនចង់បានអ្វីក៏រកមកឲ្យទាល់តែបាន ចំណែកឪពុកម្តាយខ្លះទៀត មិនបានបង្ហាញនូវអាកប្បកិរិយាឲ្យកូនរបស់ខ្លួនបានដឹងទេ តែខ្លួនពិតជាស្រឡាញ់កូនខ្លាំងជាងអ្នកដទៃមែន ។ ដោយសារតែឪពុកម្តាយខ្លះគិតថា

ការបង្ហាញទឹកចិត្តឲ្យកូនរបស់ខ្លួនបានដឹងនោះ ប្រាកដជាកូននោះ ប្រមាថមើលងាយជាមិនខាន ហេតុនេះហើយ ទើបឪពុកម្ដាយទាំងនោះបានលាក់បិទបាំងចិត្តដ៏ទន់ភ្លន់ ប្រកបដោយក្ដីស្រឡាញ់ ចិត្តមេត្តា អាណិតអាសូរ ដល់កូននៅតែក្នុងចិត្តកប់ក្នុងហឫទ័យ ទោះជាពេលខ្លះបាន បញ្ចេញនូវអាកប្បកិរិយាមិនស្រឡាញ់ក៏ដោយ តែព្រោះចង់ឲ្យកូនរបស់ខ្លួនបានល្អ ដើម្បីឲ្យកូនចេះកែប្រែរាល់ទង្វើដែលមិនសមរម្យ ។ ផ្ទុយទៅវិញ កូនខ្លះបែរជាមិនយល់ពីបំណងដ៏ល្អរបស់ឪពុកម្ដាយ ហើយបន្ថែមនូវសេចក្ដីលំបាកនោះមកដល់ឪពុកម្ដាយ ។ កូននោះចេះតែថា ឪពុកម្ដាយមិនស្រឡាញ់ខ្លួន មិនយកចិត្តទុកដាក់លើខ្លួន ចចេសចចើងមិនគោរពឪពុកម្ដាយ ជាអ្នកមានគុណលើខ្លួន ពេលខ្លះកូនទាំងនោះ ភ្លេចថា អ្នកដែលបង្កើតខ្លួនជាអ្នកណា បែរជាលើកតម្កើងអ្នកដទៃជាងឪពុកម្ដាយខ្លួន ។

ឪពុកម្ដាយរាល់រូបសុទ្ធតែមានព្រហ្មវិហារធម៌ ៤យ៉ាងគឺ ៖

**១.មេត្តា** : សេចក្ដីប្រាថ្នាចង់ឲ្យគេបានសុខ

**២.ករុណា** : សេចក្ដីអាណិតគិតនឹងជួយឲ្យគេរួចចាកទុក្ខ

**៣.មុទិតា** : សេចក្ដីត្រេកអរតាមក្នុងវេលាដែលគេបានល្អ

**៤.ឧបេក្ខា** : សេចក្ដីតាំងចិត្តជាកណ្ដាល មិនសោមនស្ស មិនទោមនស្សក្នុងវេលា ដែលគេបានសេចក្ដីសុខនិង វិបត្តិ។

ដោយសារតែឪពុកម្ដាយ មានព្រហ្មវិហារធម៌បែបនេះ ហើយទើបបានជា មិនមានអ្វីមកផ្ទឹមនឹងគុណដ៏ធំធេងបាន។

## ១០.មិនត្រូវធ្វើគម្រូអាក្រក់ដល់កូន

មានមនុស្សជាច្រើនក្នុងលោកនេះ បានបន្សល់ទុកនូវគម្រូអាក្រក់ឱ្យដល់កូន ធ្វើឱ្យកូនចងចាំក្នុងចិត្តជាប់ជានិច្ច

រហូតក្លាយទៅជារឿងបន្តគម្រូអាក្រក់នោះមកកូនទៀត ។ គម្រូអាក្រក់នោះគឺខ្លួនជាស្វាមីនិងជាឪពុករបស់គេ មានស្រីខាងក្រៅផ្ទះ ឬហៅថាប្រពន្ធចុង ហើយប្រើអំពើហិង្សាក្នុងគ្រួសារ ដូចជាវាយទាត់ធាក់ប្រពន្ធកូនដូចសត្វតិរច្ឆាន មិនមានភក្តីស្រឡាញ់ស្រណោះអាឡោះអាល័យចំពោះប្រពន្ធកូន មិនថាថ្ងៃណាជាថ្ងៃណាទេ ឃើញតែរឿងរ៉ាវ ឡូឡា គម្រាម កំហែងប្រពន្ធកូន ឱ្យដល់នូវភាពភ័យរន្ធត់តក់ស្លុតភ្លេចភ្លាំង មិនមានបញ្ញាស្មារតីក្នុងខ្លួន ។ ឪពុកកាលធ្វើអំពើឃោរឃៅក្នុងគ្រួសារ មានការវាយប្រពន្ធដែលមិនដឹងអ្វីជាដើម នេះសុទ្ធតែជាគម្រូអាក្រក់ដែលយើងធ្វើចំពោះកូន ។ ចំណែកម្តាយខ្លះក្នុងលោកនេះមិនមានចិត្តស្មោះភក្តីចំពោះស្វាមីរបស់ខ្លួន ត្រឡប់ទៅជាត្រេកអរចំពោះបុរសដទៃ (ផិតប្តី) ធ្វើឱ្យកូនអាប់ឱនក្នុងភូមិស្រុក ព្រោះតែពាក្យគេថា កូនមេស្រីផិតប្តី រាល់ពេលដែលកូនទៅ



កាន់ទីណា មានមនុស្សពេបជ្រាយមើលងាយមើលថោកថា កូនមេស្រីផិតប្តី ។ កូនទទួលការឈឺចាប់ក្នុងចិត្តគ្មានពេលស្រាកស្រាន នេះសុទ្ធតែជាគម្រូអាក្រក់របស់ម្តាយផងដែរ ។ កាលយើងទាំងពីរនាក់ប្តីប្រពន្ធ មិនមានសេចក្តីស្នេហ៍ស្មោះចំពោះគ្នានិងគ្នា រហូតឱ្យខុសជ្រុលជ្រួសក្នុងផ្លូវលោកនិងផ្លូវធម៌ដែលជារឿងមិនល្អទាល់តែសោះ ។ កូនយើងត្រូវគ្រាំគ្រាក្នុងចិត្តរាល់ថ្ងៃ ពេលកូនបើកភ្នែកពេលណា ព្រោះតែរឿងឈ្លោះទាស់ទែងគ្នា វាយតប់គ្នារាល់ ៗ ថ្ងៃ ។ កូននោះទៅជាអ្នកមានសតិមិនប្រក្រតី ឈឺចុកចាប់ក្នុងចិត្តរហូតតូចចិត្តចំពោះវាសនាខ្លួនថា មិនគួរណាមកកើតជួបឪពុកម្តាយ មិនមានធម៌ក្នុងខ្លួន ។ កូននោះទៅជាអ្នកអាប់ប្រាជ្ញា រៀនសូត្រមិនចេះ ល្ងង់ខ្លៅ រហូតកូននោះធំឡើង ក្លាយជាអ្នកខិលខូច ដើងកាង បងតូច បងធំ ។ រឿងទាំងអស់នេះ ដោយសារតែឪពុកម្តាយ ធ្វើគម្រូ

អាក្រក់បន្សល់ទុកឱ្យកូន ។ គ្រួសារខ្លះឈ្លោះទាស់ទែងគ្នា រហូតលែងលះគ្នាចែកកូនគ្នា ធ្វើឱ្យបងបែកប្អូនៗបែកបង រហូតលែងមានសេចក្តីស្រឡាញ់ ចំពោះបងប្អូនទៀត នេះដោយសារការដោះស្រាយមិនមានសន្តិវិធី មិនមានមេត្តាចំពោះគ្នានឹងគ្នា ។ តែខ្លួនយើងមិនគួរធ្វើអំពើបែបខាងលើទេ ត្រូវមានធម៌អប់រំគ្នាទៅវិញទៅមករវាងប្តីប្រពន្ធ ត្រូវដោះស្រាយបញ្ហាទាំងអស់ដោយសន្តិវិធី មិនប្រើអំពើហិង្សាក្នុងគ្រួសារ ហើយមិនក្បត់ប្រពន្ធកូនរបស់ខ្លួន ត្រូវជាមនុស្សមានសតិសម្បជញ្ញៈ ហ៊ានទទួលខុសត្រូវថា ខ្លួនជាប្តីគេឪពុកគេ ត្រូវធ្វើខ្លួនឱ្យសមជាប្តីនិងឪពុកដ៏ល្អ ។ កាលយើងធ្វើសេចក្តីល្អចំពោះគ្នានឹងគ្នា នឹងផ្តល់ជម្រកដ៏ត្រជាក់ល្ហឹមឱ្យដល់កូន អាចធ្វើឱ្យកូនយើងបានទទួលភាពកក់ក្តៅពីឪពុកម្តាយ ហើយកូនយើងនិងឈ្លាសឆ្លាតអង់អាចគ្រប់កិច្ចការទាំងពួង មិនថា ផ្លូវលោកឬផ្លូវធម៌ឡើយ ។ ព្រោះកូនយើងសប្បាយចិត្ត រីករាយ ស្រស់ថ្លាគ្រប់ពេលវេលា ដោយខ្លួនតែងតែគិតថា វាជាវាសនាល្អណាស់សម្រាប់ខ្លួនដែលជួបឪពុកម្តាយជាអ្នកមានធម៌សប្បុរស ។

ឪពុកម្តាយបានធ្វើគម្រូអាក្រក់ឱ្យដល់កូន ធ្វើឱ្យកូនដាំពូជអាក្រក់ក្នុងសន្តាន ។ ឪពុកធ្វើគម្រូអាក្រក់ កូនខ្វះនូវជម្រកជ្រកកោន ។ ម្តាយធ្វើគម្រូអាក្រក់ កូនមិនមានជម្រកសុខសាន្ត ។ឪពុកម្តាយជាគម្រូទី ១ របស់កូន ។

## ១១_ធ្វើគម្រូល្អដល់កូន

ខ្លួនយើងជាឪពុកម្តាយ ត្រូវធ្វើគម្រូល្អៗដល់កូនដូចជាខ្លួនទាំងពីរនាក់ត្រូវមានសីល ៥ ជាពុទ្ធសាសនិកជន មានសម្មាទិដ្ឋិ ចិញ្ចឹមឪពុកម្តាយរបស់យើង ។ បើយើងឆ្លាតនោះ

យើងត្រូវអញ្ជើញឪពុកម្តាយរបស់យើងមកនៅជាមួយ ដើម្បីចិញ្ចឹម ថែរក្សាគាត់រៀងរាល់ថ្ងៃ ។ ពេលបាយទឹក រៀបចំបាយទឹកដាក់ថាស ជូនចំពោះគាត់ដោយគោរព មិនមែនធ្វើដើម្បីឱ្យគេសរសើរ ឬយកមុខមាត់នោះទេ គឺត្រូវធ្វើដើម្បីបុណ្យកុសលដ៏ធំធេងរបស់យើង និងដើម្បីតបគុណចំពោះលោកទាំងពីរដែលមានឧបការគុណដ៏ធំក្រៃលែង មិនមានអ្វីយកមកប្រៀបស្មើបាន ហើយទុកជាគម្រូល្អឱ្យដល់កូនយើងផងដែរ ។ ត្រូវចេះទិញកាសែតធម៌ ឬ វិទ្យុជូនគាត់ ដើម្បីឱ្យគាត់បានស្តាប់ធម៌ រៀងរាល់ថ្ងៃ ព្រោះថាគាត់ចាស់ហើយ ចូលដល់បច្ឆិមវ័យហើយ មិនមានទីពឹងក្រៅពីព្រះធម៌ឡើយ ។ ពេលថ្ងៃសីលរៀបចំម្ហូបម្ហារឱ្យគាត់ទៅវត្តវ៉ា សមាទានសីល ដើម្បីបានជាបុញ្ញនិធិដល់គាត់សម្រាប់ទៅបរលោក មិនត្រូវខ្ជិលច្រអូសឬមើលងាយមើលថោកគាត់ជាដាច់ខាត ពេលគាត់នៅជាមួយ



យើងឡើយ ។ កាលយើងចេះដឹងគុណឪពុកម្តាយខ្លួនយើង កូននៅជាមួយយើងតែងឃើញផ្ទាល់ភ្នែក ឮផ្ទាល់នឹងត្រចៀក ពេលកូនទាំងអស់នោះធំឡើង នឹងត្រូវដឹងគុណយើង ដូចយើងដឹងគុណឪពុកម្តាយយើងយ៉ាងនោះដែរ ។ តែផ្ទុយទៅវិញ យើងមាត់តូចមាត់ធំដាក់ឪពុកម្តាយយើង ប្រើពាក្យមិនពីរោះចំពោះគាត់ កូនយើងឃើញគម្រូនេះនឹងមិនដឹងគុណយើង ដូចយើងធ្វើចំពោះឪពុកម្តាយយើងយ៉ាងនោះដែរ ។ ពេលមានកម្មវិធីបុណ្យព្រះពុទ្ធសាសនា មានបុណ្យពិសាខបូជា អាសាឡ្ហបូជាមាឃបូជា ត្រូវនាំកូនទៅចូលរួមក្នុងពិធីបុណ្យនោះ ហើយមិនត្រូវឱ្យកូនដើរលេងឥតប្រយោជន៍ទេ ត្រូវបង្រៀនកូនឱ្យចេះសំពះព្រះពុទ្ធរូប និងព្រះសង្ឃ ហើយនាំកូនបូជាប្រទីបចំពោះព្រះរតនត្រ័យ ។ កាលនាំកូនទៅបុណ្យនោះ មិនត្រូវស្ងៀមៗឥតប្រយោជន៍ ត្រូវបង្ហាញកូនពីបុណ្យនីមួយ ៗ អានិសង្ស

នៃបុណ្យ ប្រវត្តិរឿងរ៉ាវរបស់បុណ្យទាំងនោះ ឬចូលទៅក្នុងព្រះវិហារឃើញគំនូរតាមជញ្ជាំង ត្រូវពន្យល់ប្រាប់រឿងនីមួយ ៗ ឱ្យច្បាស់លាស់ដល់កូន រហូតកូនអាចចងចាំរឿងនោះបាន ចំណុតនេះសំខាន់ណាស់ អាចធ្វើឱ្យកូនយើងមានសម្មាទិដ្ឋិ ជឿបាបបុណ្យ គុណទោស និងជាអ្នកមានគុណធម៌ដុះក្នុងខ្លួន ជាប់ជាឧបនិស្ស័យជាមនុស្សល្អរហូតដល់ចាស់ទុំ ។ ម្យ៉ាងទៀត ក្នុងកម្មវិធីបុណ្យក្នុងវត្តអារាមផ្សេងៗមានភ្ជុំបិណ្ឌជាដើម ត្រូវនាំកូនយើងទៅចូលរួមផង ដើម្បីឱ្យកូនយើងមាននិស្ស័យក្នុងកាលធ្វើបុណ្យទានតទៅខាងមុខ ក្រោយអស់ពីយើងទៅ និងបានជួយថែរក្សាទំនៀមទម្លាប់ខ្មែរយើង ។ តំណាតទៅខាងមុខ កូននឹងធ្លាប់ធ្វើបុណ្យទានតាមឪពុកម្តាយពីមុន គេនឹងជាអ្នករួមចំណែកជួយព្រះពុទ្ធសាសនាឱ្យស្ថិតស្ថេរចីរកាលអស់កាលយូរអង្វែង ។

**យោ មាតរំ វា បិតរំ វា ជិណ្ណកំ គតយោព្វនំ**
**បហុសន្តោ ន ភរតិ តំ បរាភវតោ មុខំ ។**





## ១២. ឪពុកម្តាយត្រូវផ្តល់វិជ្ជាជាមត៌កដល់កូន

"ទ្រព្យសម្បត្តិក្នុងលោកនេះស្មើដោយវិជ្ជា មិនមានទាលតែសោះ" ។ ឪពុកម្តាយត្រូវតែជាអ្នកបណ្តុះចំណេះវិជ្ជា

ឱ្យដល់កូន ត្រូវចេះឱ្យកូនរៀនបានខ្ពស់មានចំណេះវិជ្ជាល្អូត លាស់អាចប្រើការបាន ។ ធម្មតាសម្បត្តិក្នុងលោកនេះ កូនអាចវាយអស់មិនមានសេសសល់បាន តែចំពោះចំណេះវិជ្ជាវិញ កូនចាយវាយយ៉ាងណា ក៏មិនចេះអស់ មានតែរឹងរឹតចម្រើនឡើង ៗ ។ ព្រោះហេតុនោះ ត្រូវតាំងចិត្តថា អាត្មាអញនឹងផ្តល់ចំណេះវិជ្ជាដល់កូន អញមិនត្រូវធ្វើឱ្យកូនល្ងង់ឡើយ ។ ឪពុកម្តាយខ្លះ គាត់មិនបានសិក្សារៀនសូត្រមិនមានចំណេះវិជ្ជាក្នុងខ្លួន គាត់រកស៊ីដោយលំបាក មិនអាចចិញ្ចឹមកូនឱ្យសុខ



ស្រួលបាន គាត់ក៏គិតថា មិនឱ្យកូនអញលំបាកដូចអញឡើយ ។ គាត់ក៏ព្យាយាមផ្តល់ចំណេះវិជ្ជាដល់កូន ដោយចំណាយលុយកាក់សម្រាប់រៀនសូត្រតាំងពីបឋមសិក្សាដល់ថ្នាក់ខ្ពស់ ហើយឱ្យកូនរៀនគួរទៀត ខ្លាចកូនរៀនមិនទាន់សិស្សដទៃ ។ នេះជាទឹកចិត្តដ៏ល្អរបស់ឪពុកម្តាយត្រូវមានចំពោះកូន មិនត្រូវ

មើលងាយចំណេះវិជ្ជាថា មិនមានប្រយោជន៍ឡើយ ។ សព្វថ្ងៃបើមិនមានចំណេះវិជ្ជាគ្រប់គ្រាន់ទេ មិនអាចស្វែងរកការងារធ្វើបានឡើយ ។ អ្នកមានចំណែះវិជ្ជាខ្ពស់ ធ្វើការងារស្រួល ចំណែកយើងមិនមានចំណោហះវីជ្ជាត្រូវធ្វើការងារលំបាក ។ នៅក្នុងគម្ពីរព្រះពុទ្ធសាសនាបានសម្តែងពីកំហុស របស់ឪពុកម្តាយមិនផ្តល់វិជ្ជាដល់កូនថា ៖

ក្នុងក្រុងពារាណសីមានត្រកូលមហាសេដ្ឋីមានទ្រព្យ ៨០ កោដិ គាត់មានកូនប្រុសមួយនាក់ឈ្មោះថា សេដ្ឋីបុត្រ



ដែលជាកូនជាទីគាប់ចិត្តរបស់គាត់ ។ គ្រាកូននោះធំឡើង គាត់គិតថា ទ្រព្យសម្បត្តិរបស់យើងមានច្រើនរហូតដល់ ៨០ កោដិ ទោះបីកូនអញដេកចាយវាយមួយជីវិតក៏មិនអស់ដែរ បើអ៊ីចឹងអញមិនឱ្យកូនរៀនវិជ្ជាផ្សេងៗនាំឱ្យបានទ្រព្យទេ ឱ្យកូនដេកចាយវាយទ្រព្យបានហើយ ។ សេដ្ឋីបុត្រមិនបានរៀន

សូត្រអ្វីទាំងអស់ គិតតែពីសប្បាយរីករាយជាមួយតូរ្យតន្ត្រីរាំរែកជាមួយមិត្តភក្រ្ត ច្រៀងលេងរៀងរាល់ថ្ងៃ ។ ក្រោយមកលោកសេដ្ឋីនិងភរិយាក៏លាចាកលោកនេះទៅ នៅសល់តែសេដ្ឋីបុត្រនិងភរិយារបស់គាត់ ដែលមិនចេះដឹងដូចគ្នា គិតតែពីសប្បាយជាមួយមិត្តភក្រ្ត មិនគិតរកស៊ីអ្វី ៗ ទេ រហូតគាត់ចាយទ្រព្យសម្បត្តិនោះអស់ពីផ្ទះ ធ្លាក់ខ្លួនដើរសូមគេ ។ ក្រោយមកចូលដៃដើងជាមួយចោរទៅលួចគេ គេចាប់បានក៏យកគាត់ទៅប្រហារជីវិត[២៤] ។

រឿងនេះបញ្ជាក់ឱ្យឃើញថា ឪពុកម្ដាយជាអ្នកធ្វើឱ្យកូនល្ងង់ខ្លៅ តែគាត់យល់ថា គាត់អាណិតកូន មិនចង់ឱ្យកូនលំបាក ទើបមិនឱ្យកូនរៀនសូត្រ ។ **កាលកូនល្ងង់អាស្រ័យ**

[២៤] អដ្ឋកថា បរមត្ថទីបនី វិមានវត្ថុ, អដ្ឋកថា ធម្មបទដ្ឋកថា ។



**យើងធ្វេសប្រហែស កាលកូនចេះអាស្រ័យយើងជាអ្នកឈ្លាស ។**

ឪពុកម្ដាយចែកចំណេះវិទ្យាឱ្យដល់កូន ប្រសើរជាងការចែកទ្រព្យ ។ ឪពុកម្ដាយដ៏ល្អរបស់កូន ត្រូវតែចែកនូវវិជ្ជាជាមត៌កដល់កូនទាំងឡាយ ។ វិជ្ជាមត៌កកូនចាយមិនចេះអស់ក្នុងលោកនេះនិងលោកខាងមុខ ។



## ១៣. ឥទ្ធិពលខាងក្រៅនាំឱ្យកូនខូច

កូនខ្លះទោះបីឪពុកម្ដាយខំទូន្មានប្រៀនប្រដៅ អប់រំយ៉ាងណាក៏ដោយ តែនៅអាចខូចបាន ព្រោះឥទ្ធិពលខាងក្រៅអូសទាញ ។

ឥទ្ធិពលគឺកម្លាំងដ៏មានប្រសិទ្ធភាពខាងក្រៅ បានដល់សង្គម សាលាឬមិត្តភ័ក្តិ ។ កាលបើក្នុងសង្គមសម្បូរណ៍ទៅដោយអំពើទុយ្ចិស ដូចជា បងតូចបងធំ ជីកស៊ី រាំច្រៀង ជាដើម ធ្វើឱ្យកូនបែរងាកទៅតាមសង្គមអូសទាញផងដែរ ។ ព្រោះហេតុនោះ ត្រូវប្រុងប្រយ័ត្នជានិច្ច កុំឱ្យកូនសេពគប់បុគ្គលដែលមាននិស្ស័យមិនល្អ ចរិតមិនល្អ ហើយនាំកូនទៅដើរលេងមិនមានខកខាន ។ យើងត្រូវខំព្យាយាមហាមឃាត់កូនមិនឱ្យដើរជាមួយបុគ្គលប្រភេទនោះឡើយ ។ សម័យឥឡូវជាសម័យទំនើបឬគេថា **"សម័យកុំព្យូទ័រ"**នេះ មនុស្សមានរាគៈ ទោសៈ មោហៈច្រើន ឃើញគុណជាទោស ឃើញទោស



ជាគុណ ។ ឥទ្ធិពលខាងក្រៅនាំឱ្យខូចបាន ដូចព្រះរាជកុមារអជាសត្តុគ្រាដំបូង ទ្រង់មិនទាន់ដល់ថ្នាក់ឃោរឃៅយង់ឃ្នងទេ តែអាស្រ័យការសេពគប់ភិក្ខុទេវទត្ត ក៏ហ៊ានធ្វើឃាតព្រះបិតាដែលជាធម្មិករាជបាន ។ ដូច្នេះឥទ្ធិពលខាងក្រៅនេះ ត្រូវប្រុងប្រយ័ត្នឱ្យមែនទែន មិនត្រូវធ្វើលំ ៗ នោះទេ ។ មាតាបិតាជាឥទ្ធិពលទី ១ របស់កូន កាលបើមាតាបិតាប្រព្រឹត្តធ្វើឱ្យមានកំហុស ធ្វើឱ្យកូនមានចិត្តធ្លាក់លិចចុះទៅក្នុងហេតុមិនប្រក្រតីដូចជាឈើចុកចាប់ក្នុងចិត្ត ព្រោះទង្វើរបស់មាតាបិតា មិនជាទីពេញចិត្តរបស់ខ្លួន រហូតដល់កូនទៅប្រព្រឹត្តធ្វើអំពើមិនសមរម្យបាន ។ សាលាក៏ឥទ្ធិពលដ៏មានកម្លាំងខ្លាំងមួយដែរ ព្រោះកាលកូនទៅសាលាជួបជាមួយមិត្តភក្តិមិនល្អ ក៏នាំឱ្យខូចបាន ឃើញកូនទៅបាត់ ៗ បើមិនប្រយ័ត្នទេ កូនទៅដើរលេងមិនចូលសាលាក៏មាន ។ សម័យយើងនេះ កូនអាងឡេះថាទៅ

សាលា។ ទៅរៀនគួរ ៗ តែជួនកាលកូនទៅដើរលេង មិនបាន ចូលសាលាបន្តិចសោះក៏មាន ។ ព្រោះហេតុនោះ ត្រូវប្រយ័ត្ន ប្រយែងចំពោះ ឥទ្ធិពលខាងក្រៅឱ្យមែនទែន កុំធ្វេសប្រហែស ណា !។

ឥទ្ធិពលខាងក្រៅមានកម្លាំងខ្លាំង អាចរុញច្រានឱ្យកូន ល្អនិងអាក្រក់ ។ ឥទ្ធិពលសាលា _មិត្រភ័ក្រ្តទាំងនេះ សុទ្ធតែមានកម្លាំងមហិមាអាចឱ្យកូនល្អនិងអាក្រក់ ។ ឥទ្ធិពលសង្គមក៏មានអំណាចណាស់ដែរ សម្រាប់កូន ។

## ១៤. ត្រូវសង្គ្រោះកូនដោយសង្គហធម៌ ៥

នៅក្នុងព្រះពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធទ្រង់ជាព្រះសាស្តាក្នុងលោកទ្រង់ចង្អុលបង្ហាញនូវធម៌សង្គ្រោះ ៥ យ៉ាង ដែលឪពុកម្តាយត្រូវមានចំពោះកូន គឺ៖

**១.បាបា និវារេន្តិ** ហាមឃាត់កូនចាកអំពើអាក្រក់

**២.កល្យាណេ និវេសេន្តិ** ឱ្យកូនតម្កល់នៅតែក្នុងអំពើល្អ

**៣.សិប្បំ សិក្ខាបេន្តិ** ឱ្យកូនរៀនសូត្រសិល្ប-សាស្ត្រ

**៤.បតិរូបេ ទារេន សញ្ញោជេន្តិ** ដណ្តឹងភរិយាស្វាមីឱ្យសមគួរដល់កូន ។



**៥.សមយេ ទាយជ្ជំ និយ្យាទេន្តិ** បែកទ្រព្យឱ្យកូនក្នុងសម័យដ៏គួរ[២៥] ។

ព្រះបរមសម្មាសម្ពុទ្ធទ្រង់បានបង្ហាញអំពីគុណធម៌របស់ឪពុកម្តាយចំពោះកូនគឺ ត្រូវហាមឃាត់មិនឱ្យកូនធ្វើអំពើបាបគ្រប់យ៉ាង មិនថា សម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម និយាយកុហក ផឹកសុរា នោះទេ ទោះបីអំពើបាបដទៃ ក៏ត្រូវហាមឃាត់ផងដែរ ។ កាលហាមមិនឱ្យធ្វើបាប ត្រូវតែចេះជំរុញឱ្យកូនបំពេញកុសលធម៌ទាំងឡាយ មានការឱ្យទាន រក្សាសីល ចម្រើនភាវនាជាដើម ។ ដោយឡែកត្រូវផ្តល់ចំណេះចេះដឹងឱ្យកូន ដើម្បីបានជាទីពឹងអាស្រ័យរបស់កូន ។ ដល់កូនធំពេញរូបរាងត្រូវស្តីដណ្តឹងភរិយាស្វាមីឱ្យបានសមរម្យនិង តាម

---

[២៥] សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ សិង្គាលកសូត្រ ១៩/៨៥ ។

ម្ចាស់ខ្លួនព្រមផង ។ ទី ៥ ត្រូវចែកមត៌កល្មមសមគួរអាចយកទៅប្រកបមុខរបរចិញ្ចឹមជីវិតបាន ។

កាលឪពុកម្តាយក្នុងលោកបានបំពេញភារកិច្ចទាំង ៥ នេះបាន ទើបសមជាមេគ្រួសារដ៏ល្អ និង ជាឪពុកម្តាយដ៏ល្អរបស់កូន ។

> ចែកទ្រព្យសម្បត្តិ មិនស្មើចែកវិជ្ជាសម្បត្តិ



# ១៥.កូនមានជម្ងឺត្រូវខំព្យាបាល

មនុស្សណាម្នាក់ ដែលថាមិនមានជម្ងឺនោះ គឺមិនមានទេ គ្រាន់តែតិចឬខ្លាំង តែកាលកូនមានជម្ងឺហើយ សូមនាំគ្នាខ្វល់ខ្វាយថែរក្សា ព្យាបាលឱ្យកូនបានជាសះស្បើយ មិនត្រូវទុកឱ្យកូននៅមានជម្ងឺរ៉ាំរ៉ៃនោះទេ ។ មានឪពុកម្តាយមិនតិចទេក្នុងលោកនេះ ពេលដែលកូនមានជម្ងឺមិនយកចិត្តទុកដាក់ព្យាបាលកូន ដោយអាងឡេះថា មិនមានលុយព្យាបាល ។ តែបើយើងជាឪពុកម្តាយដ៏ល្អនោះ ត្រូវស្វះស្វែងរកប្រាក់មកព្យាបាលឱ្យកូនបានជាឡើង ។ កាលមិនខ្វល់ខ្វាយព្យាបាលកូននៅមានជម្ងឺជានិច្ចកាលរ៉ាំរ៉ៃធ្វើឱ្យកូន មានទឹកចិត្តមិនគោរពចំពោះយើងបាន ព្រោះកូនតែងគិតថា ខ្លួនមានជម្ងឺនេះ មកពីឪពុកម្តាយមិនព្យា-បាល ទើបនៅឈឺរហូតមក ធ្វើឱ្យកូនចងគំនុំទៀតផងក៏មាន ។ ឪពុកម្តាយខ្លះ មានលុយកាក់ដែរ តែស្តាយមិនហ៊ានព្យាបាលទេ

ដោយខ្លាចអស់ទ្រព្យសម្បត្តិ នេះជាកំហុសមួយដ៏ធំ ដែលឃើញលុយជាធំ មិនឃើញកូនជាធំឡើយ ។ នៅក្នុងព្រះពុទ្ធដីកាព្រះអង្គទ្រង់ត្រាស់ថា ៖

**អារោគ្យមិច្ឆេ បរមញ្ច លាភំ** បុគ្គលគប្បីប្រាថ្នាលាភ ដ៏ឧត្តមគឺ ការមិនមានរោគ[២៦] ។

**អារោគ្យបរមា លាភា** លាភមានការមិនមានរោគជាយ៉ាងក្រៃលែង[២៧] ។

ព្រះអង្គទ្រង់ត្រាស់ជាមួយមាគណ្ឌិយបរិព្វាជកថា

**អារោគ្យបរមា លាភា និព្វានំ បរមំ លាភំ**
**អដ្ឋង្គិកោ ច មគ្គានំ ខេមំ អមតគាមិនំ។**

លាភទាំងឡាយមានការមិនមានរោគប្រសើរបំផុត

២៦ សុត្តន្តបិដក ខុទ្ទកនិកាយ ឯកនិបាត ៥៨/ ៣៧

២៧ សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា ៥២/៦៤, មជ្ឈិមនិកាយដីកា



ព្រះនិព្វានជាសេចក្តីសុខដ៏ប្រសើរ មគ្គដែលប្រកបដោយអង្គ ៨ ដ៏ក្សេមក្សាន្តជាងមគ្គទាំងឡាយ សម្រាប់ដើរទៅកាន់ព្រះនិព្វាន ឈ្មោះអមតៈ[២៨] ។

ក្នុងបាទព្រះគាថាទាំងអស់នេះ ព្រះអង្គទ្រង់ត្រាស់ថា ការមិនមានរោគជាកំពូលលាភក្នុងលោកនេះ មិនមានអ្វីប្រៀបបាន ។ កាលយើងមានសទ្ធាជឿព្រះបរមសម្ពុទ្ធ ត្រូវខំព្យាបាលជម្ងឺឱ្យកូនឱ្យជា វៀរលែងតែជម្ងឺមើលមិនជាមានអេដស៍ជាដើម យើងមិនដឹងធ្វើយ៉ាងណា តែបើមានជម្ងឺអាចមើលជាឬបន្តិចបន្តួចត្រូវព្យាបាលឡើង មិនត្រូវទុកឱ្យជាខ្លួនឯងឡើយ ។

[២៨] សុត្តន្តបិដក មជ្ឈិមនិកាយ ២៤/៨០ ។

## ១៦.ពាក្យទូន្មានឪពុកខ្ញុំ

នៅក្នុងខ្ទមមួយដ៏តូចប្រក់ទៅដោយស្បូវសែនត្រជាក់ រហឹមនិងមានខ្យល់បក់ប៉ះពុក្រោក ៗ និងមានសំឡេងសត្វតូច ៗ យំជុំវិញផ្ទះរបស់ខ្ញុំ ។ ពេលនោះមានភ្លើងចង្កៀងប្រេងកាតឆេះភ្លឺបភ្លែត ៗ នៅជិតឪពុកខ្ញុំ ស្រាប់តែមានសំឡេងឪពុកខ្ញុំហៅកូនមកថា កូនមាសឪពុក សូមកូនមកអង្គុយទីនេះ ឪពុកនឹងទូន្មានកូន ។ កូនមាសឪពុក ឪពុកធ្លាប់ជាអ្នកនៅវត្ត ធ្លាប់សិក្សាព្រះពុទ្ធវចនៈនៃព្រះសម្មាសម្ពុទ្ធហើយឃើញថា មានតែព្រះពុទ្ធវចនៈនៃព្រះសម្ពុទ្ធទេ ទើបដឹកនាំឪពុកដើរតាមគន្លងល្អឥឡូវឪពុកនឹងនាំព្រះពុទ្ធវចនៈ[២៩] នៃព្រះពុទ្ធអង្គនោះ ប្រាប់ដល់កូន ។ កូនមាសឪពុក ចូរកូនលះបង់នូវកម្មក្កិលេស គឺអំពើដ៏

[២៩] *សុត្តន្តបិដក ទីឃនិកាយ ១៩/៦៧_៩៣*



សៅហ្មង ៤ ប្រការផង មិនធ្វើបាបកម្មអំពើអាក្រក់ ព្រោះហេតុ ៤យ៉ាង មិនសេពនូវអបាយមុខគឺប្រធាននៃសេចក្ដីវិនាសនៃភោគៈ ៦ យ៉ាងផង ។ កូនមាសឪពុក តើកម្មក្កិលេស ៤ យ៉ាងដូចម្ដេច ? គឺ ការសម្លាប់សត្វ ជាកម្មក្កិលេសទី ១ ,ការលួចទ្រព្យគេ ជាកម្មក្កិលេសទី ២ ការប្រព្រឹត្តខុសក្នុងកាម ជាកម្មក្កិលេសទី ៣ ការនិយាយកុហក ជាកម្មក្កិលេសទី ៤ ។ កូនមាសឪពុក ចូរកូនលះបង់ឱ្យបាននូវកម្មក្កិលេសទាំង ៤ ប្រការនេះ ឱ្យបានណា ! ។ កូនមាសឪពុក កូនមិនត្រូវធ្វើបាបកម្ម ព្រោះហេតុ ៤ យ៉ាងទេ គឺ

**១_ឆន្ទាគតិ** លុះអគតិព្រោះស្រលាញ់ ក៏ធ្វើបាបកម្ម

**២_ទោសាគតិ** លុះអគតិព្រោះស្អប់ ក៏ធ្វើបាបកម្ម

**៣_មោហាគតិ** លុះអគតិព្រោះល្ងង់ ក៏ធ្វើបាបកម្ម

**៤_ភយាគតិ** លុះអគតិព្រោះខ្លាច ក៏ធ្វើបាបកម្ម ។

កូនមាសឪពុក កូនមិនត្រូវសេពធម៌ជាប្រធាននៃសេចក្តីវិនាស ទ្រព្យ៦ យ៉ាងទេ គឺ៖

១_ផឹកទឹកស្រវឹង

២_ដើរលេងខុសកាលវេលា

៣_ដើរមើលមហោស្រព

៤_ការលេងល្បែងភ្នាល់

៥_ការសេពគប់បាបមិត្រ

៦_ការខ្ជិលច្រអូស

កូនមាសឪពុក ចូរកូនដឹងថា បុគ្គលផឹកទឹកស្រវឹងមិនមែននាំមកនូវភាពចម្រើនទេ គឺនាំមកនូវការវិនាសសព្វគ្រប់ប្រការ រហូតឃើញបច្ចុប្បន្ន កូនចូរចងចាំថា ទោសនៃការផឹកសុរាមាន ៦ ប្រការគឺ៖

១_វិនាសទ្រព្យដែលឃើញជាក់ស្តែងខ្លួនឯង



២_ការកឱ្យកើតជម្លោះ

៣_ហេតុនាំឱ្យកើតរោគទាំងឡាយ

៤_ការនាំឱ្យខូចឈ្មោះ

៥_ការបង្ហាញកេរ្តិ៍ខ្មាស

៦_ធ្វើឱ្យបញ្ញាមានកម្លាំងថយ

កូនមាសឪពុក ចូរកូនដឹងថា មនុស្សដែលដើរលេងតាមច្រកល្ហកខុសកាលវេលា(ពេលយប់)មានទោស៦ ប្រការគឺ៖

១_អ្នកនោះឈ្មោះថាមិនគ្រប់គ្រងរក្សាខ្លួន

២_អ្នកនោះឈ្មោះថា មិនគ្រប់គ្រងរក្សាកូនប្រពន្ធ

៣_អ្នកនោះឈ្មោះថាមិនគ្រប់គ្រងរក្សាទ្រព្យសម្បត្តិ

៤_សេចក្តីរង្កៀសតែងកើតមានដល់កន្លែងខ្លួនទៅដល់

៥_ពាក្យមិនពិតតែងធ្លាក់មកត្រូវបុគ្គលនោះ[៣០]

---

[៣០] ព្រោះដាន់ដានចោរ

៦_បុគ្គលនោះឈ្មោះថា បំពេញនូវធម៌ជាទុក្ខច្រើន

កូនមាសឪពុក មនុស្សដែលចូលចិត្តដើរមើលល្បែងមហោស្រព នេះមានទោស ៦ យ៉ាងគឺ ៖

១_របាំក្នុងទីណា ក៏ទៅក្នុងទីនោះ

២_ចម្រៀងក្នុងទីណា ក៏ទៅក្នុងទីនោះ

៣_ការប្រគំក្នុងទីណា ក៏ទៅក្នុងទីនោះ

៤_គេប្រជុំរឿងព្រេងឥតប្រយោជន៍ក្នុងទីណាក៏ទៅទីនោះ

៥_ល្បែងវាយគងក្នុងទីណា ក៏ទៅក្នុងទីនោះ

៦_ល្បែងវាយរនាតក្នុងទីណា ក៏ទៅក្នុងទីនោះ

កូនមាសឪពុក មនុស្សដែលចូលចិត្តលេងល្បែងស៊ីសង រមែងមានទោស ៦ ប្រការគឺ ៖

១_បុគ្គលនោះបើឈ្នះគេ រមែងបានពៀរ

២_បើចាញ់គេតែងសោកស្ដាយទ្រព្យសម្បត្តិ



៣_វិនាសទ្រព្យសម្បត្តិដែលឃើញជាក់ស្ដែងទាន់ភ្នែក

៤_កាលទៅសាលាវិនិច្ឆ័យគេ មិនជឿស្ដាប់ពាក្យ

៥_ពួកមិត្រតែងលះបង់ចោល

៦_ជាបុគ្គលដែលគេមិនត្រូវការដណ្ដឹងឬឱ្យកូនស្រី ព្រោះគេគិតថា បុរសបុគ្គលអ្នកលេងល្បែងភ្នាល់មិនអាចចិញ្ចឹមប្រពន្ធបានទេ ។

កូនមាសឪពុក បុគ្គលដែលជាអ្នកសេពគប់បាបមិត្ត មានទោស ៦ ប្រការគឺ ៖

១_ជនណាជាអ្នកលេងល្បែងភ្នាល់ ជាមិត្តអ្នកនោះ

២_ជនអ្នកលេងស្រី

៣_ជនអ្នកផឹកសុរា

៤_ជនអ្នកបោកប្រាសបញ្ឆោតអ្នកដទៃ

៥_ជនអ្នកបំបាត់ប្រវញ្ចន៏អ្នកដទៃក្នុងទីចំពោះមុខ

៦_ជនអ្នកចក់ដណ្តើមទ្រព្យអ្នកដទៃ

កូនមាសឪពុកបុគ្គលទាំង ៦ ពួកនេះ តែងតែជាមិត្ររបស់អ្នក នោះឯង ។

កូនមាសឪពុក បុគ្គលអ្នកខ្ជិលច្រអូសមិនធ្វើការងារ ដោយអាងហេតុ ៦ ប្រការគឺ ៖

១_ត្រជាក់ណាស់

២_ក្តៅណាស់

៣_ល្ងាចណាស់

៤_ព្រឹកណាស់

៥_ឃ្លានណាស់

៦_ស្រេកណាស់

កូនមាសឪពុក បុគ្គលដែលខ្ជិលច្រអូសយ៉ាងនេះ មិនអាចធ្វើឱ្យទ្រព្យសម្បត្តិដែលមានហើយ ឱ្យតាំងនៅបានឡើយ ហើយ



មិនអាចញុំាងទ្រព្យមិនទាន់មាន ឱ្យមានឡើងទេ ។

កូនមាសឪពុក កូនត្រូវដឹងថា មាតាបិតាជាទិសខាងកើត , អាចារ្យអ្នកត្រូវដឹងថា ជាទិសខាងត្បូង, កូននិងប្រពន្ធអ្នកត្រូវដឹងថា ជាទិសខាងលិច , មិត្ត អាមាត្យអ្នកត្រូវដឹងថា ជាទិសខាងជើង , ទាសៈកម្មករអ្នកត្រូវដឹងថា ជាទិសខាងក្រោម, សមណព្រាហ្មណ៍អ្នកត្រូវដឹងថា ជាទិសខាងលើ ។ កូនមាសឪពុក ការទំនុកបម្រុងចិញ្ចឹមមាតាបិតា រមែងបានបុណ្យកុសលច្រើនខ្លាំងណាស់ កូនត្រូវតែទំនុកបម្រុងលោកដោធម៌ ៥ យ៉ាងគឺ ៖

**១_ភតោ នេសំ ភរិស្សាមិ** អាត្មាអញមាតាបិតាបានចិញ្ចឹមរក្សាមកហើយ នឹងចិញ្ចឹមមាតាបិតាវិញ

**២_កិច្ចំ នេសំ ករិស្សាមិ** នឹងជួយធ្វើការងារមាតាបិតា

**៣-កុលវំសំ ឋបេស្សាមិ** នឹងតម្កល់វង្សត្រកូល

**៤-ទាយជ្ជំ បដិបជ្ជាមិ** ប្រតិបត្តិឱ្យសមគួរជាអ្នកទទួលទ្រព្យមត៌កបាន

**៥-បេតានំ កាលកតានំ ទក្ខិណំ អនុប្បទស្សាមិ** ឧទ្ទិសទក្ខិណាទានដល់មាតាបិតា ដែលធ្វើកាលកិរិយាទៅកាន់បរលោកហើយ ។

កូនមាសឪពុក កូនជាកូនសិស្ស កូនត្រូវប្រតិបត្តិគ្រូអាចារ្យដោយស្ថាន ៥ យ៉ាងគឺ ៖

**១-ឧដ្ឋានេន** ក្រោកទទួល

**២-ឧបដ្ឋានេន** គាល់បម្រើ

**៣-សុស្សូសាយ** ជឿស្តាប់តាម

**៤-បារិចរិយាយ** ដោយការបម្រើតូច ។

**៥-សក្កច្ចំ សិប្បំ បដិគ្គហណេន** រៀនសិល្ប-



សាស្ត្រដោយគោរព ។

កូនមាសឪពុក កាលកូនបានគោរពប្រតិបត្តិតាមឱ្យវាទទាំង ៥ ខាងលើនេះ គ្រូអាចារ្យរបស់កូននឹងអនុគ្រោះកូនវិញ ដោយស្ថាន ៥ យ៉ាងគឺ ៖

**១-សុវិនីតំ វិនេន្តិ** ដឹកនាំល្អ

**២- សុគ្គហិតំ គាហាបេន្តិ** ឱ្យរៀនល្អ

**៣- សព្វសិប្បេសុ តំ សមក្ខាយិនោ ភវន្តិ** ប្រៀនប្រដៅសិស្សឱ្យចេះត្រឹមត្រូវក្នុងសិល្បសាស្ត្រសព្វគ្រប់,

**៤-មិត្តាមច្ចេសុ បដិវេទេន្តិ** តែងលើកតម្កើងក្នុងទីប្រជុំមិត្តអាមាត្យ,

**៥-ទិសាសុ បរិត្តាណំ ករោន្តិ** ធ្វើសេចក្តីការពារក្នុងទិសទាំងឡាយ ។

កូនមាសឪពុក ក្នុងកាលអនាគត កូននឹងត្រូវធ្វើជាស្វាមីគេ ព្រោះហេតុនោះ កូនត្រូវទំនុកបម្រុងភរិយារបស់កូនដោយធម៌៥ យ៉ាងគឺ៖

**១.សម្មាននាយ** ដោយការរាប់អានជាភរិយាពេញទី

**២.អវិមាននាយ** ដោយមិនមើលងាយ

**៣.អនតិចរិយាយ** មិនប្រព្រឹត្តក្បត់ចិត្ត

**៤.ឥស្សរិយវោសគ្គេន** ប្រគល់ឱ្យជាធំក្នុងផ្ទះ

**៥.អលង្ការានុប្បទានេន** ឱ្យគ្រឿងអលង្ការតែងខ្លួន។

កូនមាសឪពុក កាលកូនបានធ្វើឱ្យត្រូវតាមតួនាទីហើយ ភរិយាកូននឹងទំនុកបម្រុងកូនវិញដោយស្ថាន ៥ យ៉ាងដែរគឺ៖

**១.សុសំវិហិតកម្មន្តា** ចាត់ចែងការងារដោយល្អ

**២.សុសង្គហិតបរិជនា** សង្គ្រោះជនជាញាតិទាំងពីរខាងដោយល្អ,



**៣.អនតិចារិនី** មិនប្រព្រឹត្តក្បត់ចិត្ត

**៤.សម្ភតញ្ច អនុរក្ខតិ** ថែទាំទ្រព្យដែលស្វាមីរកបានមក,

**៥.ទក្ខា ច ហោតិ អនលសា សព្វកិច្ចេសុ** ឈ្លាសមិនខ្ជិលច្រអូសក្នុងកិច្ចការសព្វគ្រប់។

កូនមាសឪពុក កូនមានមិត្តជាសប្បុរស កូនត្រូវចេះអនុគ្រោះនូវមិត្តនោះ ដោយស្ថាន៥ យ៉ាងគឺ៖

**១.ទានេន** ដោយការឱ្យរបស់

**២.បិយវាចេន** ដោយការនិយាយតែពាក្យគាប់ចិត្ត

**៣.អត្ថចរិយាយ** ដោយការប្រព្រឹត្តិឱ្យជាប្រយោជន៍

**៤.សមានត្តតាយ** ដោយការប្រព្រឹត្តខ្លួនស្មើ

**៥.អវិសំវាទនតាយ**ដោយការមិនកុហកបញ្ឆោត។

កូនមាសឪពុក បើកូនបានអនុគ្រោះនូវមិត្តដោយស្ថាន ៥ យ៉ាងខាងលើនេះហើយ មិត្តរបស់កូននឹងអនុគ្រោះដល់កូនដោយធម៌ ៥ វិញ គឺ៖

**១.បមត្តំ រក្ខន្តិ** រក្សាមិត្តដែលធ្វេសប្រហែស

**២.បមត្តស្ស សាបតេយ្យំ រក្ខន្តិ** ជួយថែទាំទ្រព្យសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស,

**៣.ភីតស្ស សរណំ ហោន្តិ** ជាទីពឹងរបស់មិត្តដែលមានភ័យ,

**៤.អាបទាសុ ន ជហន្តិ** មិនបោះបង់គ្នាក្នុងគ្រាមានវិបត្តិ,

**៥.អបរបជំ បិស្ស បដិបូជេន្តិ** រាប់អានរហូតដៅពង្សរបស់មិត្ត ។



កូនមាសឪពុក កូនត្រូវអនុគ្រោះទាសៈកម្មករ ដោយស្ថាន ៥ យ៉ាង គឺ៖

**១.យថាពលំ កម្មន្តំ សំវិធានេន** ដោយការចាត់ចែងការងារសមគួរតាមកម្លាំង,

**២.ភត្តវេត្តនានុប្បទានេន** ដោយការឲ្យនូវភត្តាហារ និងថ្លៃឈ្នួល,

**៣.គិលានុបដ្ឋានេន** ដោយការព្យាបាលក្នុងវេលាឈឺថ្កាត់,

**៤.អច្ឆរិយានំ រសានំ សំវិភាគេន** ដោយការចែករំលែកនូវរបស់មានរសត្រកាលចំឡែក,

**៥.សមយេ វោស្សគ្គេន** ដោយការឲ្យឈប់សម្រាកក្នុងសម័យគួរ,

កាលបើកូនទំនុកបម្រុងទាសៈនិងកម្មករដោយស្ថាន៥ យ៉ាងនេះហើយ កូនរមែងបានការអនុគ្រោះត្រឡប់ពី ទាសៈនិងកម្មករដោយស្ថាន ៥ យ៉ាងវិញគឺ ៖

**១-បុព្វុដ្ឋាយិនោ ច ហោន្តិ** ក្រោកឡើងធ្វើការងារមុនចៅហ្វាយនាយ,

**២-បច្ឆានិបាតិនោ ច** ឈប់ធ្វើការងារក្រោយចៅហ្វាយនាយ,

**៣-ទិន្នាទាយិនោ ច** កាន់យកតែរបស់ដែលចៅហ្វាយ នាយឲ្យ,

**៤-សុកតកម្មករា ច** ធ្វើការងាររបស់ចៅហ្វាយនាយដោយយកចិត្តទុកដាក់,

**៥-កិត្តិវណ្ណហរា ច** នាំកិត្តិគុណរបស់ចៅហ្វាយនាយ



ទៅថ្លែងក្នុងទីនោះៗ។

កូនមាសឱពុកសមណព្រាហ្មណ៍ជាទិសខាងកើត កូនត្រូវផ្គត់ផ្គង់ដោយស្ថាន៥យ៉ាងគឺ ៖

**១-មេត្តេន កាយកម្មេន** កាយកម្មប្រកបដោយមេត្តា,

**២-មេត្តេន វចីកម្មេន** វចីកម្មប្រកបដោយមេត្តា

**៣-មេត្តេន មនោកម្មេន** មនោកម្មប្រកបដោយមេត្តា

**៤-អនាវដទ្វារតាយ** ជាអ្នកមិនបិទទ្វារផ្ទះ

**៥-អាមិសានុប្បទានេន** ដោយកិរិយាឲ្យអាមិសទាន។

កាលបើកូនបានទំនុកបម្រុងសមណព្រាហ្មណ៍ ដោយស្ថានប្រាំយ៉ាងនេះហើយ កូនរមែងបានសេចក្ដីអនុគ្រោះពី សមណព្រាហ្មណ៍៥យ៉ាងវិញគឺ ៖

**១-បាបា និវារេន្តិ** ហាមឃាត់កូនចាកអំពើអាក្រក់,

**២-កល្យាណេ និវេសេន្តិ** ឲ្យតាំងនៅតែក្នុងអំពើល្អ,

**៣-កល្យាណេន មនសា អនុកម្បន្តិ** អនុគ្រោះដោយចិត្តដ៏ល្អ,

**៣-អស្សុតំ សាវេន្តិ** ឲ្យបានស្តាប់ពាក្យដែលមិនធ្លាប់បានស្តាប់,

**៤- សុតំ បរិយោទបេន្តិ** បំភ្លឺសេចក្តីដែលធ្លាប់ស្តាប់ហើយឱ្យច្បាស់,

**៥-សគ្គស្ស មគ្គំ អាចិក្ខន្តិ** ប្រាប់ផ្លូវសួគ៌ដល់កូន។

កូនមាសឪពុក កាលដែលកូនបានប្រតិបត្តិតាមឱវាទនេះហើយ ក្នុងគ្រួសាររបស់កូនមានតែសេចក្តីសុខ ចម្រើនសុភមង្គល វិបុលសុខអស់កាលជានិច្ច ។ កូនមាសឪពុក កូនត្រូវដឹងថា នេះជាឱវាទដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងមកហើយ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ សេចក្តីចម្រើនដល់កុលបុត្រទាំងឡាយក្នុង លោកនេះ ។ កូនត្រូវមានសម្មា-



ទិដ្ឋិថា ព្រះពុទ្ធវចនៈគឺជាពាក្យពិត មិនមានក្លែងក្លាយឡើយ ដូច្នេះ ការប្រតិបត្តិតាមរមែងនាំមកនូវសេចក្តីសុខ សេចក្តីចម្រើនមែន ។

កូនមាសឪពុក កាលកូនចេះចាំព្រះពុទ្ធវចនៈនេះហើយ កូនត្រូវបង្រៀនឱ្យដល់កូនរបស់កូនទៀត ។ កាលបន្តគ្នានូវព្រះពុទ្ធវចនៈយ៉ាងនេះ កូនចៅរបស់កូនរមែងជួបប្រទះតែសេចក្តីសុខចម្រើនរហូតនឹងក្លាយជាមនុស្សល្អ កូនតែងឮពាក្យខ្មែរថា "កូនចៅមានពូជ" ពាក្យនេះគេពោលសរសើរដល់កូនចៅដែលមានឪពុកម្តាយជាអ្នកចេះដឹងល្អ ប្រតិបត្តិល្អ ។

## ១៧.កូនត្រូវមានកតញ្ញូកតវេទិតាតបវិញ

កាលមាតាបិតាបានចិញ្ចឹមកូន ត្រូវតាមគន្លងធម៌យ៉ាងនេះហើយ ខ្លួនយើងជាកូនត្រូវជាអ្នកដឹងគុណគាត់វិញ ដោយជួយចិញ្ចឹមបីបាច់ថែរក្សាគាត់ ដូចគាត់ធ្វើមកលើយើង ទើបសមជាកូនដ៏ល្អរបស់មាតាបិតា ។ សូម្បីព្រះសម្មាសម្ពុទ្ធក៏ទ្រង់ទុកមាតាបិតាដូចជាភ្លើង ដូចទ្រង់ត្រាស់ថា ៖

ម្នាលព្រាហ្មណ៍ ភ្លើង ៣ ប្រការនេះបុគ្គលគួរធ្វើសក្ការៈ គោរព រាប់អាន បូជា រក្សា បម្រើឱ្យល្អដោយប្រពៃ។ ភ្លើង ៣ ប្រការតើដូចម្តេចខ្លះ ? ភ្លើងគឺអាហុនេយ្យបុគ្គល ១ ភ្លើងគឺបុគ្គលជាម្ចាស់ផ្ទះ ១ ភ្លើងគឺ ទក្ខិណេយ្យបុគ្គល ១[៣៧] ។

**អាហុនេយ្យបុគ្គល** បានដល់ មាតាបិតាជាបុគ្គលគួរ

[៣៧] សុត្តន្តបិដក អង្គុត្តរនិកាយ សត្តកនិបាត ៤៧/៨៣



បូជារបស់កូនប្រុសស្រី ព្រោះកាលកូនគោរពបូជារមែងបានបុណ្យកុសលដ៏ច្រើន ហើយតែងបានផលអាចឃើញទាន់ភ្នែកទៀតផង ដូចជាការសរសើរជាដើម ។

**គហបតគ្គិ** ភ្លើងគឺ ម្ចាស់ផ្ទះ បានដល់ ប្រពន្ធ កូន ខ្ញុំបម្រើ អ្នកទាំងអស់នេះ ត្រូវតែប្រុងប្រយ័ត្នបីបាច់ថែរក្សាឱ្យបានល្អ មិនត្រូវធ្វេសប្រហែសទេ ។

**ទក្ខិណេយ្យគ្គិ** ភ្លើងគឺទក្ខិណេយ្យបុគ្គល បានដល់ សមណព្រាហ្មណ៍ជាអ្នកមិនមានសេចក្តីប្រមាទ ស្ថិតនៅក្នុងខន្តិនិងសោរច្ចៈ ទូន្មាននូវចិត្តមួយ រម្ងាប់នូវចិត្តមួយ រលត់នូវចិត្តមួយ ត្រូវតែគោរពប្រតិបត្តិឱ្យបានល្អ ដោយការថ្វាយបង្គំ និងការឱ្យទានជាដើម ។

ហេតុអ្វីបានទ្រង់ត្រាស់ថា ជាភ្លើង ? ព្រោះភ្លើងនាំមក

នូវសេចក្ដីចម្រើនដល់យើងក៏មាន សេចក្ដីវិនាសក៏មាន ដូចភ្លើងចង្ក្រានយើងឈ្លាសដាំបាយហូបបាន តែមិនឈ្លាសធ្វើឱ្យឆេះផ្ទះអស់ក៏បាន យ៉ាងណា ភ្លើងនេះ បើយើងប្រតិបត្តិគោរពតែងនាំមកនូវសេចក្ដីចម្រើន សុភមង្គល វិបុលសុខ បើយើងបៀតបៀនមើលងាយ មើលថោកតែងនាំមកនូវសេចក្ដីវិនាសទុក្ខព្រួយជានិច្ច ។

នៅក្នុងអង្គុត្តរនិកាយ[៣២] ព្រះអង្គទ្រង់ត្រាស់ថា ៖

ម្នាលភិក្ខុទាំងឡាយ កូនរបស់ត្រកូលទាំងឡាយណា បានបូជាមាតាបិតា ក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងអស់នោះឈ្មោះថាប្រកបដោយបុព្វាចារ្យ(អាចារ្យដើម) ម្នាលភិក្ខុទាំងឡាយ កូនរបស់ត្រកូលទាំងឡាយណា បានបូជាមាតាបិតាក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងនោះឈ្មោះថាប្រកបដោយអាហុ-

[៣២] អង្គុត្តរនិកាយ តិកនិបាត ទេវទូតវគ្គ ៤១/៧៧ ,អង្គុត្ត.ចតុក្កនិបាត ៤២/១៧៤



នេយ្យ (អ្នកគួរទទួលរបស់ដែលកូនប្រុសស្រីបូជា ) ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រហ្មនុ៎ះ ជាឈ្មោះមាតាបិតា ម្នាលភិក្ខុទាំងឡាយពាក្យថា បុព្វាចារ្យនុ៎ះជាឈ្មោះមាតាបិតា ម្នាលភិក្ខុទាំងឡាយពាក្យថា អាហុនេយ្យនុ៎ះ ជាឈ្មោះមាតាបិតា ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះមាតាបិតាជាអ្នកមានឧបការៈច្រើន ជាអ្នកបីបាច់ រក្សាចិញ្ចឹមកូន ជាអ្នកឲ្យកូនបានឃើញលោកនេះ ។

**ព្រហ្មាតិ មាតាបិតរោ**
**បុព្វាចរិយាតិ វុច្ចរេ**
**អាហុនេយ្យា ច បុត្តានំ**
**បជាយ អនុកម្បកា ខ**
**តស្មាហិ នេ នមស្សេយ្យ**
**សក្ករេយ្យាថ បណ្ឌិតោ**

**អន្នេន អថ បានេន**

**វត្ថេន សយនេន ច**

**ឧច្ឆាទនេន ន្ហាបនេន**

**បាទានំ ធោវនេន ច**

**តាយ បរិចរិយាយ**

**មាតាបិតូសុ បណ្ឌិតា**

**ឥធេវ នំ បសំសន្តិ**

**បេច្ច សគ្គេ បមោទតិ ៕**

មាតាបិតាលោកហៅថាព្រហ្មផង ថាបុព្វាចារ្យផងថា អាហុនេយ្យផង របស់កូនទាំងឡាយ ព្រោះជាអ្នកអនុគ្រោះនូវពពួកសត្វ ។ ព្រោះហេតុនោះ បណ្ឌិតត្រូវតែនមស្ការធ្វើសក្ការៈមាតាបិតាទាំងនោះ ដោយបាយ ទឹក សំពត់ ទីដេក គ្រឿងដុសខាត់ទឹកងូត នឹងទឹកលាងជើង បណ្ឌិតរមែងសរសើរ



កូននោះ ព្រោះការបម្រើមាតាបិតានោះក្នុងលោកនេះ (កូននោះ) លុះលះលោកនេះទៅកាន់បរលោករមែងរីករាយក្នុងស្ថានសួគ៌ ។

ក្នុងព្រះសូត្រនេះចង្អុលបង្ហាញឱ្យឃើញថា ព្រះសម្មា-សម្ពុទ្ធទ្រង់ចង្អុលនូវគុណមាតាបិតាដ៏ធំធេង ចំពោះកូនប្រុសស្រីក្នុងលោកនេះ ហើយទ្រង់បានត្រាស់ថា មាតាបិតាជាអាហុនេយ្យបុគ្គលគឺបុគ្គលគួរទទួលយកនូវទេយ្យវត្ថុ ដែលកូនប្រុសស្រីបូជា នឹងបានបុណ្យកុសលរាប់ប្រមាណមិនបាន ។ ព្រោះហេតុនោះ សូមកូនប្រុសស្រីត្រូវជ្រាបថា មាតាបិតាជាអ្នកមានឧបការគុណច្រើន មិនមានអ្វីក្នុងលោកនេះ ប្រៀបប្រដូចបានឡើយ ។ កាលយ៉ាងនោះ កូនប្រុសស្រីមិនត្រូវប្រមាថមើលងាយគាត់ដោយប្រការណានីមួយនោះឡើយ ។ បើខុសភ្លាំងភ្លាត់ ព្រោះល្ងិតល្ងង់ ត្រូវសូមខមាទោសគាត់ កុំ

ខានឡើយណា ! ។

ព្រះអង្គទ្រង់ត្រាស់សម្តែងមួយកន្លែងទៀតថា ៖

ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះរកបានដោយកម្រក្នុងលោក គឺ **យោ ច បុព្វការី** បុគ្គលដែលធ្វើឧបការៈទុកមុន ១ **យោ ច កតញ្ញូ កតវេទី** បុគ្គលដឹងឧបការៈដែលគេធ្វើហើយធ្វើតបវិញ[៣៣] ។

ព្រះពុទ្ធដីកានេះបញ្ជាក់ឱ្យឃើញថា អ្នកត្រូវធ្វើសេចក្តីល្អឱ្យដល់អ្នកដទៃរកបានដោយកម្រណាស់ ដូចមាតាបិតាត្រូវចិញ្ចឹមកូនតាមគន្លងធម៌ក៏មិនងាយរកបានទេ ច្រើនតែចិញ្ចឹមទៅតាមផ្លូវខុស អាងខ្លួនជាឪពុកគេ ម្តាយគេ ប្រើអំពើហិង្សាមកចំពោះកូនដែលមិនដឹងអ្វីជាដើម ។ ចំណែកអ្នកដែលទទួលឧបការៈពីអ្នកដទៃនោះ ច្រើនមិនសូវដឹងគុណគេ ដូច

[៣៣] *សុត្តន្តបិដក អង្គុត្តរនិកាយ ទុកនិបាត ៤០/១៩៥*



កូនច្រើនមិនដឹងគុណមាតាបិតាជាដើម ។

ព្រះអង្គទ្រង់មួយកន្លែងទៀតថា៖

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជាអសប្បុរស កាលប្រតិបត្តិខុសក្នុងបុគ្គលពីរពួក តែងរក្សាខ្លួនដែលខ្លួនបានជីកគាស់ កំចាត់គុណចោលចេញ ជាអ្នកប្រកបដោយទោសផង ប្រកបដោយដំនៀលនៃអ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបាបដ៏ច្រើនផង ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺមាតា ១ បិតា ១[៣៤] ។

នៅក្នុងសម័យពុទ្ធកាលមានព្រាហ្មណ៍ម្នាក់ គាត់ជាអ្នកមានទ្រព្យមហាសាល ហើយគាត់បានចែកទ្រព្យឱ្យកូនគាត់អស់ ពេលនោះគាត់មិនអាចពឹងកូនគាត់បានត្រូវកូនដេញចេញពីផ្ទះហើយជួបព្រះសម្មាសម្ពុទ្ធទ្រង់បង្រៀនគាថាថា ៖

*៣៤ សុត្តន្តបិដក អង្គុត្តរនិកាយ ទុកនិបាត ៤០/២០២*

ខ្ញុំត្រេកអរដោយកូនទាំងឡាយណាដែលកើត ហើយផងប្រាថ្នានូវសេចក្ដីចម្រើនដល់កូនទាំងឡាយ ណាផង កូនទាំងនោះ ក៏សមគំនិតគ្នាជាមួយនឹងប្រពន្ធទាំងឡាយ ហើយបណ្ដេញខ្ញុំដូចជាឆ្កែដេញជ្រូក ក៏កូនទាំងឡាយជាអសប្បុរសលាមកគ្រាន់តែហៅខ្ញុំថា **បិតា បិតា**ប៉ុណ្ណោះទេ ប៉ុន្តែកូនទាំងនោះ ដូចអារក្សទឹក ដែលមកដោយរូប ជាកូន លះបង់នូវខ្ញុំដែលមានអាយុចូលដល់បច្ឆិមវ័យហើយ បិតាចាស់របស់បុគ្គលពាលទាំងឡាយ តែងសូមទានប្របផ្ទះនៃជនដទៃ ដូចជាសេះចាស់ប្រើប្រាស់មិនបាន គេនាំចេញចាកចំណី ឈើច្រត់របស់ខ្ញុំប្រសើរ កូនទាំងឡាយដែលមិនស្ដាប់បង្គាប់ មិនប្រសើរដូចឈើច្រត់ឡើយ ព្រោះឈើច្រត់អាចការពារគោកាចក៏បាន ការពារឆ្កែកាចក៏បាន ច្រត់ក្នុងខាងមុខក្នុងទីងងឹតក៏បាន ស្ទង់ក្នុងទឹកជ្រៅក៏បាន បុគ្គលភ្លាត់រអិល គង់ទប់វិញបាន ដោយអានុភាពនៃឈើច្រត់[៣៥] ។

ព្រាហ្មណ៍គាត់ពោលនេះត្រឹមត្រូវណាស់ ព្រោះថាកូនដែលមិនដឹងគុណឪពុកម្ដាយ ឱ្យគាត់រស់នៅតោកយ៉ាកលំបាកលំបិន រងទុក្ខវេទនារាល់ថ្ងៃនោះ តើកូននោះគាប់ប្រសើរយ៉ាងណាទៅ សូម្បីឪពុកម្ដាយបង្កើតរបស់ខ្លួន មិនអាចធ្វើសេចក្ដីល្អជាមួយផង ចុះទម្រាំអ្នកដទៃរឿងអ្វី ធ្វើសេចក្ដីល្អបាននោះ ។ ដូច្នេះកូននោះ អន់ជាងឈើច្រត់គាត់ទៅទៀត ព្រោះឈើច្រត់អាចការពារគាត់គ្រប់ឧបសគ្គ តែកូនមិនអាចតើកូនប្រសើរជាងឈើច្រត់ដូចម្ដេចទៅ! ។

---

*៣៥ សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ ៣០/១២៥*

ព្រះសាស្តាទ្រង់ត្រាស់មួយកន្លែងទៀតថា ៖

ម្នាលគហបតិ អរិយសាវ័កក្នុងសាសនានេះ ញុំាងខ្លួនឲ្យសុខឲ្យឆ្អែតរក្សាសុខដោយប្រពៃញុំាងមាតាបិតាឲ្យសុខឲ្យឆ្អែតរក្សាសុខដោយប្រពៃញុំាងកូនប្រពន្ធនិង បុរសជាទាសកម្មករឲ្យសុខឲ្យឆ្អែត រក្សាសុខដោយប្រពៃ ញុំាងមិត្ត អាមាត្យឲ្យសុខឲ្យឆ្អែត រក្សាសុខដោយប្រពៃ ដោយភោគ:ទាំងឡាយដែលបានមកដោយ សេចក្តីព្យាយាមពោលគឺសេចក្តីខ្នះខ្នែងសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ជារបស់ប្រកបដោយធម៌បានមកដោយធម៌[៣៦] ។

ចំពោះកូនប្រុសស្រីឯណា មានទ្រព្យសម្បត្តិហើយខ្លួនបានចិញ្ចឹមមាតាបិតា ដែលកំពុងរស់នៅឱ្យមានសេចក្តីសុខ ក្រេមក្សាន្តរស់នៅយ៉ាងស្រួល មិនលំបាកលំបិន ព្រម

[៣៦] សុត្តន្តបិដក អង្គុ.ចតុក្កនិបាត ៤២/១៦៦



ទាំងចិញ្ចឹមប្រពន្ធកូនតាមគន្លងធម៌ ទើបសមជាកុលបុត្រដែលប្រកបដោយធម៌ក្នុងសាសនានេះ ។

មាតាបិតាក្នុងលោកយើងនេះពិចារណាឃើញហេតុ ៥ យ៉ាង ហើយមានបំណងចង់បានបុត្រដែលកើតក្នុងត្រកូលគឺ ៖

**១-ភតោ វា នោ ភរិស្សតិ** បុត្រដែលយើងចិញ្ចឹមហើយនឹងចិញ្ចឹមយើងវិញ,

**២-កិច្ចំ វា នោ ករិស្សតិ** បុត្រនឹងជួយធ្វើកិច្ចយើង

**៣-កុលវំសោ ចិរំ ឋស្សតិ** វង្សត្រកូលនឹងឋិតនៅយូរ,

**៤-ទាយជ្ជំ បដិបជ្ជតិ** បុត្រប្រតិបត្តិទទួលយកមត៌ក,

**៥-អថ វា បន បេតានំ កាលកតានំ ទក្ខិណំ អនុប្បទស្សតិ**មួយទៀត បុត្រនឹងឧទ្ទិសទក្ខិណាទាន

ឱ្យដល់យើងដែលធ្វើមរណកាលទៅកាន់លោកខាងមុខ[៣៧]។

មាតាបិតាដែលលោកចង់បានកូន ព្រោះគិតថា គាត់ចាស់ទៅនឹងមានកូនជួយចិញ្ចឹមបីបាច់ថែរក្សាគាត់ ។ តែបើយើងជាមនុស្សអាវ៉ាសែ មិនដឹងខុសត្រូវធ្វើបាបគាត់រៀងរាល់ថ្ងៃមិនចិញ្ចឹមបីបាច់ទេ នោះពិតជាខុសបំណងគាត់ខ្លាំងណាស់ ។ យ៉ាងនោះកូនប្រុសស្រី ត្រូវភ្ញាក់ខ្លួនឡើង ហើយងាកមករកផ្លូវត្រង់គឺថា មិនត្រូវធ្វើជាមនុស្សសោះកក្រោះមិនអើពើជាមួយមាតាបិតាឡើយ ។ មានកូនច្រើនគិតថា ឪពុកម្តាយនៅជាមួយ នាំឱ្យលំបាក ជួយចិញ្ចឹមគាត់សែនយ៉ាប់ហើយ អស់លុយច្រើន បើគាត់មិននៅជាមួយអញទេ អញមិនលំបាកយ៉ាងនេះឡើយ នេះជាកូនល្ងង់ ឃើញគុណជាទោសមាតាបិតារស់នៅ មិនគិតជួយចិញ្ចឹមគាត់ យកបុណ្យ! ទៅ

[៣៧] សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត ៤៤/ ៨៥។



នឹកឃើញការលំបាក អស់លុយជាច្រើន មិននឹកឃើញគាត់ចិញ្ចឹមបីបាច់ពីក្មេង ឱ្យដឹងខុសត្រូវសោះ គួរឱ្យកោតណាស់! ។ អ្នកខ្លះគិតតែពីដើរលេង មិនចេះឈប់ឈរតាំងពីព្រលឹមដល់ព្រលប់ ទើបចូលផ្ទះ មិនជួយធ្វើការពុកម៉ែ នេះក៏ខកបំណងរបស់គាត់ដែរ ព្រោះគាត់ចង់បានកូនមកឱ្យកូនជួយធ្វើកិច្ចការងារជំនួស ស្រាប់តែបានកូនខ្ជិលច្រអូសមកវិញ ។ ដូច្នេះ សូមកូនប្រុសស្រីជួយបំពេញបំណងគាត់ផង មិនត្រូវខ្ជិលច្រអូសទេ ។ ឪពុកម្តាយតែងនឹកសញ្ជឹងថា ពេលអញមានកូនក្រោយពីអញស្លាប់ទៅនឹងមានកូន ធ្វើបុណ្យឧទ្ទិសដល់អញ ចុះបើយើងគិតតែពីចង់បាន ខ្លាចអស់ទ្រព្យមិនហ៊ានធ្វើបុណ្យទានឧទ្ទិសឱ្យគាត់សោះ នេះក៏ខកបំណងគាត់ប្រាថ្នាចង់បានកូនដែរ ។ ដើម្បីត្រូវបំណងគាត់ យើងត្រូវធ្វើបុណ្យឧទ្ទិសកុសលឱ្យគាត់បានត្រេកអរអនុមោទនា ទើបសមជាកូនល្អ។

នៅក្នុងព្រះពុទ្ធសាសនាព្រះអង្គទ្រង់ត្រាស់ថា កុលបុត្រលើកនូវមាតាដាក់ស្មាខាងស្ដាំ លើកបិតាដាក់លើស្មាខាងឆ្វេង បម្រើគាត់រហូតអស់អាយុ ។ តែព្រះអង្គនៅទ្រង់ត្រាស់ថា **ន ត្វេវ ភិក្ខវេ មាតាបិតុន្នំ កតំ វា ហោតិ បដិកតំ វា** ម្នាលភិក្ខុទាំងឡាយ ហេតុមានប្រមាណប៉ុណ្ណោះ គង់មិនទាន់ហៅថា ធ្វើ ឬថាធ្វើតបដល់មាតានិងបិតាឡើយ ។ ព្រោះមាតាបិតាជាអ្នកមានឧបការៈច្រើនដល់កុលបុត្រទាំងឡាយ ព្រោះជាអ្នកថែរក្សាចិញ្ចឹមបង្ហាញនូវលោកនេះដល់កូន ។ បើកុលបុត្រណាមួយ ដឹកនាំមាតាបិតាដែលមិនមានសទ្ធា ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងសទ្ធាសម្បទា បើទ្រុស្តសីល ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងសីលសម្បទា បើកំណាញ់ ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងចាគសម្បទា បើឥតបញ្ញា ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងបញ្ញាសម្បទា ហេតុមានប្រមាណ



ប៉ុណ្ណោះ ទើបហៅថា ធ្វើ ឬថាធ្វើតបដល់មាតានិងបិតាមែន [៣៨] ។ ព្រះសម្មាសម្ពុទ្ធព្រះអង្គតែងទ្រង់សរសើរនូវការចិញ្ចឹម ថែរក្សានូវមាតាបិតាក៏ពិតមែន តែទ្រង់សរសើរក្រៃលែងជាងនោះទៀតគឺ ការដឹកនាំមាតាបិតាឱ្យមានសម្មាទិដ្ឋិ យល់ត្រូវត្រង់មានសទ្ធាជឿកម្មនិងផលរបស់កម្ម ហើយជាអ្នកត្រេកអរក្នុងការរក្សាសីល ការឱ្យទាន និងមានបញ្ញា ។ យើងជាកូនត្រូវធ្វើតបមាតាបិតា ដោយជួយចាត់ចែងរកឧបាយកលយ៉ាងណាឱ្យគាត់មានសទ្ធា ដូចត្រូវរកខ្សែអាត់ព្រះធម៌ចាក់ជូនគាត់ស្ដាប់ ទិញសៀវភៅធម៌ជូនគាត់មើល បបួលគាត់ទៅវត្តឱ្យស្ដាប់ព្រះធម៌ពីព្រះសង្ឃជាអ្នកប្រាជ្ញ ឱ្យដើរសេពគប់ជាមួយសប្បុរស ជាអ្នកមានសទ្ធា មានហិរិ ឪតប្បៈ ។ ការធ្វើយ៉ាងនេះគាត់អាចមានឧបនិស្ស័យល្អជាមួយសប្បុរស រហូតមានសទ្ធា មានសីល មាន

---

[៣៨] សុត្តន្តបិដក អង្គុត្តរនិកាយ ឯក_ទុកនិបាត ៤០ / ១៣៨ ។

ចាគៈ និងបញ្ញា ។ យើងជាកូនត្រូវតាំងចិត្តថា ត្រូវតែជួយមាតា-បិតាឲ្យដើរតាមគន្លងនៃព្រះសទ្ធម្ម ។

កាលកូនប្រុសស្រីធ្វើបានយ៉ាងនេះ ទើបឈ្មោះថា ជាកូនដ៏ល្អ បានឈ្មោះថា ធ្វើតបគុណគាត់ ។

**-ន បាបសម្បវង្កេន មាតា បុត្តេន នន្ទតិ**

-មាតាមិនបានរីករាយជាមួយនឹងកូន ព្រោះតែកូនគប់រកសម្លាញ់អាក្រក់[៣៩] ។

**-មាស្សុ ពាលេន សង្គច្ឆិ ទុក្ខោ ពាលេហិ សង្គមោ** ។

-ចូរអ្នកកុំគប់រកបុគ្គលពាលឡើយ ព្រោះការគប់រកបុគ្គលពាលទាំងឡាយ តែងនាំមកនូវសេចក្តីទុក្ខ[៤០] ។

**-តថាហិ ធីរា សុកតញ្ញូរូបា** ពិតដូច្នោះមែន បណ្ឌិតមាន

[៣៩] សុត្តន្ត.ខុទ្ទកនិកាយ មនោជជាតក ៥៩/៧៣ [៤០] ហលិទ្ទុរាគជាតក ៥៩/១៥៤



សភាពជាមនុស្សកតញ្ញូល្អ[៤១] ។

**-កដ្ឋំ និប្លវសារិតំ សេយ្យោ នត្វេវេកច្ចិយោ នរោ**

ឧសដែលគេស្រង់ឡើងអំពីទឹកប្រសើរជាងនរៈពួកខ្លះ ដែលគេស្រង់អំពីទឹក មិនប្រសើរឡើយ[៤២] ។

**យោ បុព្វេ កតកល្យាណោ កតត្ថោ នាវពុជ្ឈតិ**

**បច្ឆា កិច្ចេ សមុប្បន្នេ កត្តារំ នាធិគច្ឆតិ ។**

បុគ្គលណាមិនដឹងនូវអំពើល្អ ដែលគេធ្វើហើយ នូវប្រយោជន៍ដែលគេធ្វើហើយ ក្នុងកាលមុន បុគ្គលនោះកាលបើកិច្ចកើតព្រមហើយ ក្នុងកាលខាងក្រោយ រមែងមិនបាននូវបុគ្គលអ្នកធ្វើ (ឧប-ការគុណមុននោះជាគ្នា) ឡើយ[៤៣] ។

[៤១] សុត្តន្ត.ខុទ្ទក.ជុណ្ហជាតក ៥៩/២១៥ , [៤២] សច្ចង្កិរជាតក ៥៨/៣១

[៤៣] សុត្តន្ត.ខុទ្ទក.ឯកនិបាត អកតញ្ញូជាតក ៥៨/៣៩

**អកតញ្ញុមកត្តារំ　　កតស្ស អបជិការកំ**

**យស្មឹ កតញ្ញុតា នត្ថិ　និរត្ថា តស្ស សេវនា ។**

សេចក្តីដឹងគុណដែលគេធ្វើហើយក្នុងបុគ្គលណា ការសេពគប់នឹងបុគ្គលអ្នកមិនដឹងគុណដែលគេធ្វើហើយ មិនធ្វើ( គុណនឹងអ្នកណា) មិនតបស្នងសងគុណដល់អ្នកដែលធ្វើគុណហើយ ដល់ខ្លួននោះ ជាការឥតប្រយោជន៍[៤៤] ។

**-យថា បិតា វា អថវាបិ មាតា អនុកម្បកា អត្ថកាមា បជានំ**

-បិតាឬមាតាជាអ្នកអនុគ្រោះប្រាថ្នានូវសេចក្តីចម្រើនដល់បុត្រទាំងឡាយ[៤៥] ...។

**-ន តេ បុត្តា យេ ន ភរន្តិ ជិណ្ណំ** ពួកបុត្រណាមិនចិញ្ចឹមមាតា-

[៤៤] សុត្តន្ត.ខុទ្ទក.ចតុក្កនិបាត ជវសកុណជាតក ៥៨/១៩៣

[៤៥] សុត្តន្ត.ខុទ្ទក.សុតសោមជាតក ៦១/២១០



បិតាជាបុគ្គលចាស់ទុំ ពួកបុត្រនោះ មិនមែនជាកូនទេ[៤៦] ។

**-ករំ បុរិសកិច្ចានិ ន ច បច្ឆានុតប្បតិ**

កាលធ្វើតាមនាទីកូនប្រុសហើយរមែង មិនក្តៅក្រហាយក្នុងកាលជាខាងក្រោយ[៤៧] ។

**-យោ ច បុត្តានមស្សវោ** កូនដែលជឿស្តាប់មាតាបិតាជាកូនដ៏ប្រសើរ[៤៨] ។

**-ធម្មេន មាតាបិតរោ ភរេយ្យ** វិញ្ញូជននោះ គួរចិញ្ចឹមមាតា-បិតាដោយធម៌[៤៩] ។

**-កតញ្ញុនោ ហិ សារីបុត្ត សប្បុរិសា កតវេទិនោ**

នែសារីបុត្ត ធម្មតាពួកសប្បុរសរមែងជាអ្នកកតញ្ញូនិងកតវេទី[៥០]

[៤៦] សុត្តន្ត.ខុទ្ទក.សុតសោមជាតក ៦១/២១៣, [៤៧] សុត្តន្ត.មហាជនកជាតក ៦២/២១

[៤៨] គម្ពីរនេរទក្ខទីបនី ត្រង់បញ្ញានិទ្ទេស គាថាទី ៩៦, [៤៩] សុត្តន្ត.សុត្តនិបាត ៥៤/១២៩

[៥០] វិនយបិដក មហាវគ្គ ៦/១៦៨ ។

## សេចក្តីប្រាថ្នារបស់អ្នកនិពន្ធ

ដោយអំណាចបុណ្យដែលខ្ញុំបានរចនាសៀវភៅនេះ សូមឱ្យ
បានជួបតែមាតាបិតាជាសប្បុរស ជាអ្នកមានកល្យាណធម៌
មានសទ្ធា មានសីល មានចាគៈនិងមានបញ្ញា ហើយជាអ្នក
ចិញ្ចឹមកូនតាមគន្លងធម៌ ។ ខ្ញុំបដិសន្ធិជាកូនរបស់ឪពុក
ណា ជាកូនរបស់ម្តាយណា សូមឱ្យឪពុកនោះម្តាយនោះ
ចិញ្ចឹមខ្ញុំឱ្យដើរតាមគន្លងធម៌ដូចក្នុងសៀវភៅនេះ
បើខ្ញុំកើតក្នុងត្រកូលណា សូមឱ្យខ្ញុំជួយ
ដឹកនាំត្រកូលនោះឱ្យជាសម្មាទិដ្ឋិ
ទាំងអស់ សូមឱ្យខ្ញុំមានសុខភាព
ល្អនិងមានបញ្ញាលើសគេ
បំផុតក្នុងលោក
នេះ



## ឧទ្ទិសកថា

**ឧបាសិកា អៀង គឹមហួយ** សូមឧទ្ទិសបុណ្យ
កុសលកើតពីធម្មទាននេះចំពោះ_

កុង **ឡៃ អ៊ី** និង កុង **ចាប**

លោកយាយឧបាសិកា **ប្រិច** ត្រូវជាជីដូន

លោកយាយឧបាសិកា **ឈាវ** ត្រូវជាជីដូន

លោកឪពុក **ហួយ មេន**និងម្តាយ **អ៊ឹង ស៊ីណៃ**

លោកឪពុកក្មេក **ស៊ី ថាំឆ្វន់** ម្តាយក្មេក **ជ្រៀន**

បង **ហួយ លឹមហៀង**

ប្អូន **ហួយ គឹមអ៊ុល ...**

សូមអ្នកទាំងអស់គ្នា ត្រេកអរអនុមោទនាយកបុណ្យកុសល
ដែលខ្ញុំបានប្រារព្ធធ្វើហើយ សូមឱ្យបានសេចក្តីសុខ ចុះ ។

# ចិញ្ចឹមកូនតាមគន្លងធម៌

*រៀបរៀងដោយ*

**វ៉ាន់ ចាន់សារ៉េន**

ក្រុមជំនុំព្រះត្រៃបិដក

នៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ព.ស.២៥៤៧

គ.ស.២០០៤


| | |
|---|---|
| ឈ្មោះសៀវភៅ | ចិញ្ចឹមកូនតាមគន្លងធម៌ |
| អ្នករៀបរៀង | វ៉ាន់ ចាន់សារ៉េន |
| ត្រួតពិនិត្យ | លោក លឹម លឿម លោក គង់ សំអឿន ក្រុមជំនុំព្រះត្រៃបិដក,ឧបាសក ដាំ កុយ ឧ.សិ. ម៉ម សុខហេង, |
| វាយអត្ថបទកុំព្យូទ័រ | វ៉ាន់ ចាន់សារ៉េន |
| ស្ថានទីធ្វើ | ការិយាល័យក្រុមជំនុំព្រះត្រៃបិដក វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមនរាជធានីភ្នំពេញ |
| អ្នកឧបត្ថម្ភ | ពុទ្ធបរិស័ទ |
| បោះពុម្ពទី ១ | ព.ស.២៥៤៧ គ.ស.២០០៤ |
| ចំនួនបោះពុម្ព | ១០០០ ច្បាប់ |

## សប្បុរសជនចូលរួមធម្មទាន

១_ឧបាសិកា **អៀង គីមហួយ** សហរដ្ឋអាមេរិក ៤០០$

២_លោក **យូ ម៉េង** និងមាតាបិតា ១០០$

៣_លោក **ម៉ា ស៊ុនហួត** និងភរិយាបុត្រ ១០០$

៤_លោក **ចាន់ ការ៉ង** និង **សោម គីណា** ៣០$

៥_ឧ.សិ. **តាំង លាងស៊ុយ** និងស្វាមី ២០$

៦_ឧ.សិ. **ស សោភ័ណ** និងស្វាមី ២០$

៧_ឧ.ស.**សុន សែនហេង**ឧ.សិ.**កៅ ស្រ៊ាម** (គីឡូលេខ ៦) ៥០

៨_ពុទ្ធបរិស័ទគីឡូលេខ ៦_៧ ២៣៥០០ ៛

៩_អ្នកស្រី**ណៃ ស៊ីណា** សហរដ្ឋអាមេរិក ២០$

១០_ឧបាសិកា **ឌុន យ៉េម** ១០$

១១_ឧបាសក **ចឹក ថ្រឹច** ឧបាសិកា **ឡាយ ម៉ិច** ១០$

១២_លោក កែវ ប៊ុនធឿន ព្រមទាំងភរិយានិងបុត្រ ១០$

១៣_ឧបាសិកា **ឈឹម អ៊ី** ៥$

១៤_ឧ.សិ. **ប៉ែន ថន** ៥$

១៥_ឧ.សិ.**ពៅ សារ៉ាន** ៥$

១៦_ឧ.សិ.**សុខ សុថារត្ន** ៥០០០៛

១៧_លោក **ម៉េង ខួន** និងភរិយាព្រមទាំងបុត្រ ២០០០០៛

១៨_លោកសាស្ត្រាចារ្យ **សុខ សេងយ៉ន**២០០០០៛

១៩_ឧបាសក **ដាំ ក្មុយ** ព្រមទាំងភរិយានិងកូន ២០០០០៛

២០_ឧ.សិ.**ញឹក ស៊ីន** ព្រមទាំងបុត្រ ១៥០០០៛

២១_ឧ.សិ.**ការ៉ង ម៉ៅឡៀង** ព្រមទាំងស្វាមីបុត្រ ១០០០០៛

២២_តា**ម៉េង** យាយ **អ៊ាម សេង** (អូរាំងឪ) ១០០០០៛

២៣_ឧ.សិ.**ឈាង ណារី** ព្រមទាំងបុត្រ ៥០០០៛

២៤_ឧ.សិ.**ប៉ែន សារឿន** ៥០០០៛

២៥_ឧបាសក **គី** ឧបាសិកា **យ៉េង** ៥០០០៛

២៦_ឧបាសិកា **ហួ** ៥០០០៛

២៧_ឧ.សិ.**ម៊ុន សុខា** ព្រមទាំងបុត្រ ១$

២៨_ឧបាសិកា**ពៅ ស៊ីផាត** ៤០០០៛

២៩_លោក**រិន ផល្លៃ** ៣០០០៛

៣០_កញ្ញា **ម៉ិន រតនា** (កោះក្របី) ៣000៛

៣១_ឧ.ស.**ឯម យិន** ឧ.សិ.**មាលា** (អូរាំងឪ) ២000៛

៣២_កញ្ញា **ង្រ៉ីវ គឹមឈុង** ២000៛

៣៣_កញ្ញា **ហៃ ឆុយគី** ២000 ៛

៣៤_ឧ.សិ. **យ៉ាវ អាត់** ៥000 ៛

៣៥ _ ឧ.ស.**អ៊ាត ឡៀង** ឧ.សិ. **ដួង សោភា**ព្រមទាំងបុត្រ ១0$

៣៦_កញ្ញា **អ៊ាត ច័ន្ទរស្មី** ១0000 ៛

៣៧_កញ្ញា **ចាន់ សិរីរត្ន** ៣000 ៛

៣៨_លោក **ប៊ូ លីន** និងភរិយា**តាំងតិច ស៊ីម** ព្រមទាំងបុត្រ ៥$

៣៩_ឧ.សិ.**ស៊ី ឈុនហ៊ាង**ព្រមទាំងបុត្រ ១0000៛

៤0_ឧ.សិ.**តាំង ស៊ីម**ព្រមទាំងបុត្រ ១0000៛

៤១_លោក**ផាន់ណា** អ្នកស្រី **អាំងអ៊ឹម** ព្រមទាំងបុត្រ ៦000៛

៤២_អ្នកស្រី **ប៊ូ សារ៉េត** ៣000៛

៤៣_ លោក **កែម ទូច** និង **រ៉ុមផល្លី** (ស្ទើងជ័យ ) ១0000៛

៤៤_ឧ.ស. **កែម** និង ឧ.សិ.**សយ** (ស្ទើងជ័យ) ៥000៛



៤៥_លោក **លឹម ទុត្តា**និង អ្នកស្រី **សន ស្រីប៉ុល** ៥000៛

៤៦_លោក **ស៊ឹម សែល** និង**កែម ផល្លី** ៣000៛

៤៧_លោក **ឡេង វិចិត្រ** និង**នង សុខនាង** ៥000៛

៤៨_លោក **សោត វណ្ណះ** នឹង **គង់ ច័ន្ទតារ៉ា**នឹងបុត្រ ៥000៛

៤៩_លោកស្រី **ម៉ន សីណារ៉ា** ព្រមទាំង បុត្រ ១0000៛

៥0_លោក**ឈាង ហួត** អ្នកស្រី**តាន់ រតនទេវិ**ព្រមទាំងបុត្ត ១0000៛

៥១_អ្នកស្រី**សំ សុខេត**និងស្វាមីព្រមទាំងបុត្រ ២0000៛

៥២_អ្នកស្រី**អៀង សុខហៀង**និងស្វាមីព្រមទាំងបុត្រ ១0000៛

៥៣_ឧបាសិកា**គុយ ឡេងស៊ឹង**ព្រមទាំងបុត្រ ១0000៛

៥៤_អ្នកស្រី **តាំង អ៊ីសៀវ** និងប្អូនសុខព្រមទាំងបុត្រ ១0000៛

៥៥_យាយ**ទូច អ៊ឹមមុនី** ៥000៛

៥៦_អ្នកស្រី **ង៉ោ ហ៊ុយណៃ** ៥000៛

៥៧_ឧបាសិកា**វ៉ាយ រ៉ាវី** ព្រមទាំង បុត្រ ៥$

៥៧_កញ្ញា **អ៊ឹង ស៊ីវឆេង** ១0000៛

៥៨_លោក**តាំង ឡុងឃីម**និង**អ៊ឹង ស៊ីវហុង**ទាំងបុត្រ ១0000៛

៥៩_លោក**យក ច្រឹង**ឧ.សិ.**អ៊ីវ ណារ៉េត**ព្រមទាំងកូនចៅ ១០$

៦០_ឧបាសិកា **អ៊ូ ស្វ៊ីគា** ព្រមទាំងកូនចៅ ៥$

៦១_ឧបាសិកា**ឃួន ប៊ុនណា** ៥០០០៛

៦២_លោក**ហ៊ី ឆ៉ាវ** អ្នកស្រី **ណៃ ជា** ១០$

៦៣_ឧបាសិកា**ឃន ជឿក** ព្រមទាំងបុត្រ ៥$

៦៤_ឧបាសក**ស៊ីន ស៊ា**ឧ.សិ.**សា ស៊ីណាត**ព្រមទាំងបុត្រ ៥$

៦៥_លោក **យ៉ាង គឹមសេង** ១០០០០៛

៦៦_លោក**កែវ រស្មី** អ្នកស្រី **នាង សុខា**ព្រមទាំងបុត្រ ១០០០០៛

៦៧_ឧបាសិកា**ហេ ហ៊ន** ព្រមទាំងបុត្រ ៥០០០៛

៦៨_លោក **តូ សំអាង**និង **តាំង គឹមអេង**ព្រមទាំងបុត្រ ៥០០០៛

៦៩_និស្សិតឈ្មោះ **កៅ រតនា** ៥០០០៛

៧០_ឧបាសិកា **ប៊ិះ សាយប៊ី** ព្រមទាំងគ្រួសារនិងបុត្ត ១៥០០០៛

៧១_លោក **ម៉ុក ខេមរិទ្ធី** និងអ្នកស្រី **ច្រាប សាវី** ២០០០០៛

៧២_លោក **ជា នាង** ៣០០០៛

៧៣_យុវជន **ខុក ប្រុស** ៣០០០៛ និង ឧ.សិ.**រ៉ិច សៀង** ៣០០០៛



## ពុទ្ធបរិស័ទសិក្សាព្រះបរិយត្តិបដិបត្តិ

## ព្រះពុទ្ធសាសនានាវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

១_ឧ.សិ. បួន គឹមណៃ ៥$

២_ឧ.សិ. ឌឹម យន់ ១០$

៣_ឧ.សិ. ទូច សុភី (៣ក្បាល) ១០៥០០៛

៤_ឧ.សិ. ចាប សាផន ១០០០០៛

៥_ឧ.ស. ថាច់ សឹន ១០០០៛

៦_ឧ.សិ. ប្រាក់ គុយឡាំង ១០០០០៛

៧_ឧ.សិ. វ៉ា ផល្លា ស្វាមីព្រមទាំងបុត្រ ១$

៨_ឧ.ស. ទុំ គឹមសុន និង ឧ.សិ. អៀង វ៉ាន់នី ៥$

៩_កញ្ញា ប៊ុន ហ៊ូរ៉ាដែត ១០០០០៛

១០_ឧ.សិ. ឈាវ គឹមស៊ាង ព្រមទាំងកូនចៅ (១០ក្បាល) ៩$

១១_ឧ.សិ. កែវ ពៅ ២០០០០៛

១២_យុវជន ស៊ិន សុភា ២០០០០៛

១៣_ឧ.សិ. ម៉ម សុខហេង ១០០០០៛

១៤_ឧ.សិ. ណៃ ស៊ីម (ថ្នល់ទទឹង) ១០$

# អារម្ភកថា

**ការចិញ្ចឹមកូនតាមគន្លងធម៌** ជាភារកិច្ចរបស់មាតាបិតា ដែលនៅក្នុងលោកយើងនេះ ជាអ្នកត្រូវប្រព្រឹត្តខ្លួនយ៉ាងណា ឲ្យសមជាមាតាបិតារបស់កូន ។ ចំពោះសៀវភៅនេះ ខ្ញុំបានដកស្រង់ព្រះធម៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងទុកក្នុងព្រះត្រៃបិដក អដ្ឋកថា ដីកា ដោយបង្ហាញពីពិធីចិញ្ចឹមកូនដ៏ល្អ និង ជាឱវាទានុសាសនីចំពោះបុគ្គលដែលត្រូវធ្វើជាឪពុកម្តាយរបស់កូនត្រូវអប់រំទូន្មានខ្លួនយ៉ាងណា ឲ្យជាគម្រូដ៏ល្អដល់កូន ឲ្យកើតមានសេចក្តីសុខ សេចក្តីចម្រើន និងសុភមង្គលក្នុងគ្រួសារ និងជាម្លប់ដ៏ត្រជាក់របស់កូន ។ ម្យ៉ាងទៀត សៀវភៅនេះក៏បានបង្ហាញដល់មនុស្សគ្រប់រូបថា ព្រះពុទ្ធសាសនាមិនមែនដឹកនាំមនុស្ស ឲ្យបានសម្រេចសួគ៌និព្វានតែម្យ៉ាងប៉ុណ្ណោះទេ ថែមទាំងបង្ហាញពីសេចក្តីសុខក្នុង



ក្រុមគ្រួសារ ដែលប្រកបដោយធម៌យ៉ាងណាខ្លះក្នុងបច្ចុប្បន្ន ដោយបំបាត់អំពើឃោរឃៅ អំពើហិង្សាក្នុងគ្រួសារ និង ការបណ្តុះសេដ្ឋកិច្ចដល់មនុស្សគ្រប់គ្នា ដើម្បីឈានទៅរកការអភិវឌ្ឍន៍ប្រទេសតាមគោលព្រះពុទ្ធសាសនាផង ។ ក្នុងសៀវភៅនេះ ភាគច្រើនជាពាក្យដកចេញពីព្រះត្រៃបិដកសុទ្ធ ៗ និង ការនិពន្ធរបស់ខ្ញុំខ្លះ តាមដែលបានឃើញបានច្លងកាត់មក ហើយបានផ្សំគ្នារៀបរៀងឡើងជាសៀវភៅនេះ តែទោះជាយ៉ាងណា សៀវភៅនេះ មិនទាន់សុក្រិតដល់អ្នកអាននៅឡើយទេ ដោយខ្ញុំជាអ្នកសរសេរសៀវភៅនេះ មិនធ្លាប់មានប្រពន្ធកូន មិនទាន់ស្គាល់រឿងរាក់ជ្រៅក្នុងគ្រួសារ ហេតុនោះ ការសរសេរមិនអាចសុក្រិតបានឡើយ ។ ដោយឡែកទៀត ខ្ញុំមានសុខភាពមិនល្អ ដោយមានជម្ងឺច្រើនប្រភេទ ឈឺក្បាល គ្មានពេលស្រាកស្រានសោះ តែទោះបីមានជម្ងឺមកយាយីយ៉ាង

ណាក៏ដោយ តែជម្ងឺនោះមិនអាចបៀតបៀនឆន្ទៈរបស់ខ្ញុំក្នុងការធ្វើសៀវភៅនេះឡើយ រហូតដល់កើតជារូបរាងសៀវភៅនេះឡើងសម្រាប់ពុទ្ធសាសនិកទាំងឡាយ ។ ម្យ៉ាងទៀត ក្រុមជំនុំព្រះត្រៃបិដកយើង នឹងបន្តធ្វើសៀវភៅជាច្រើនទៀតសម្រាប់ជាផលប្រយោជន៍ដល់ពុទ្ធសាសនិក ដែលត្រូវការចង់ចេះដឹងនូវធម៌វិន័យព្រះពុទ្ធសាសនា ។ ខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងផ្តល់ផលប្រយោជន៍ដ៏ច្រើន ដល់អ្នកអានទាំងឡាយមិនខាន តែក៏សូមអធ្យាស្រ័យអភ័យទោសពីសំណាក់វិញ្ញូជន ជាបណ្ឌិតក្នុងព្រះពុទ្ធសាសនា ក្រែងមានកំហុសដោយអក្ខរាវិរុទ្ធពិនិត្យមិនសព្វគ្រប់ឬសេចក្តីខុសឆ្គាំឆ្គង ក៏សូមអធ្យាស្រ័យផង ។ ខ្ញុំសង្ឃឹមថា លោកអ្នកប្រាកដជាជួយកែសម្រួលសម្រាប់បោះពុម្ពលើកក្រោយទៀតជាមិនខាន ។



ខ្ញុំសូមប្រគេន_ ជូនបុណ្យកុសលចំពោះអតីតៈក្រុមជំនុំព្រះត្រៃបិដកមានសម្តេចព្រះសង្ឃរាជ **ជួន_ណាត** ជាដើម សូមមកត្រេកអរអនុមោទនាផងចុះ ។ ចំពោះបុព្វការីជនមានមាតាបិតាសាច់ញាតិទាំងអស់ ព្រមទាំងសហធម្មិកៈគ្រប់រូបដែលបានជួយឧបត្ថម្ភបោះពុម្ពសៀវភៅនេះ ហើយសូមបានជាបច្ច័យសម្មាទិដ្ឋិ រហូតព្រះនិព្វានកុំបីខានឡើយ ។

ថ្ងៃ ព្រហស្បតិ៍ ៤ រោច ខែ ចេត្រ ឆ្នាំ មមែ បញ្ចស័ក

ព.ស. ២៥៤៧

ត្រូវនឹងថ្ងៃទី ៨ ខែ មេសា ឆ្នាំ២០០៤

**ថាន់ ចាន់សារ៉ែន**

ក្រុមជំនុំព្រះត្រៃបិដក

នៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

## សេចក្តីបញ្ជាក់សម្រាប់អ្នកអាន

សូមជ្រាបថា ក្នុងសៀវភៅនេះមានលេខយោងគម្ពីរ នៅខាងក្រោម លេខយោងយើងខ្ញុំធ្វើតាមបែបអន្តរជាតិ មិនដូចពីសម័យមុនឡើយ ។ សម័យមុនក្នុងសន្លឹកណាគឺមានលេខ ១ -២ ក្នុងសន្លឹកនោះ សន្លឹកផ្សេងទៀតក៏ដាក់លេខយោងដូចគ្នា តែលេខយោងក្នុងសៀវភៅនេះគឺលេខ ១ តាមលំដាប់រហូតដល់លេខយោង ៥០ តែម្តង ។

លេខនៅខាងដើមជាលេខក្បាលគម្ពីរ លេខខាងក្រោយជាលេខទំព័រ ដូចជា ៥២/៤ អានថា បិដកលេខ ៥២ ទំព័រ ៤ គ្រប់ៗ លេខយោងទាំងអស់ សូមអានយ៉ាងនេះ។

អាទិសង្កេតសព្ទ (អក្សរកាត់)

សុត្តន្ត. អានពាក្យពេញថា សុត្តន្តបិដក

ខុទ្ទក. អានថា ខុទ្ទកនិកាយ ។



## មាតិកា


| លេខរៀង មាតិកាអត្ថបទ | ទំព័រ |
|---|---|
| ១-អារម្ភកថា | ក |
| ២-ចិញ្ចឹមកូនតាមគន្លងធម៌ | ១ |
| ៣-ត្រៀមធ្វើជាប្តីប្រពន្ធគេ | ៣ |
| ៤-អបាយមុខ ៤ប្រការ | ៨ |
| ៥-បាបមិត្តមានចំណុចធំ៤ | ១២ |
| ៦-ភរិយាមាន ៧ ពួក | ១៧ |
| ៧-កាតព្វកិច្ចក្រោយពេលរៀបអាពាហ៍ពិពាហ៍ | ២៧ |
| ៨-សម្បទាមាន៤យ៉ាង | ៣០ |
| ៩-សេចក្តីសុខរបស់គ្រហស្ថ៤យ៉ាង | ៣៥ |
| ១០-ស្ត្រីត្រូវប្រតិបត្តិឱវាទ១០យ៉ាង | ៤៦ |
| ១១-ការរួមរស់រវាងប្តីប្រពន្ធមាន៤យ៉ាង | ៥២ |
| ១២-ស្ត្រីតែងមើលងាយប្តីដោយហេតុ ៨យ៉ាង | ៥៨ |
| ១៣-ត្រូវធ្វើជាឪពុកម្តាយដ៏ល្អរបស់កូន | ៦០ |

១៤-ត្រូវគិតថា កូនជាមនុស្សសំខាន់សម្រាប់យើង.................... ៦៦
១៥-កូនមានបីពួក ។................................................................. ៧៧
១៦-កុំបង្រៀនកូនឱ្យខ្ជិលនិងខូច................................................ ៨៨
១៧-មិនត្រូវធ្វើគម្រូអាក្រក់ដល់កូន.......................................... ៩៨
១៨-ធ្វើគម្រូល្អដល់កូន.............................................................. ១០២
១៩-ឪពុកម្ដាយត្រូវផ្ដល់វិជ្ជាជាមត៌កដល់កូន............................. ១០៦
២០-ឥទ្ធិពលខាងក្រៅនាំឱ្យកូនខូច............................................. ១១០
២២-ត្រូវសង្គ្រោះកូនដោយសង្គហធម៌ ៥.................................... ១១៣
២៣-កូនមានជម្ងឺត្រូវខំព្យាបាល................................................. ១១៦
២៤-ពាក្យទូន្មានឪពុកខ្ញុំ........................................................... ១១៩
២៥-កូនត្រូវមានកតញ្ញូកតវេទិតាតបវិញ.................................. ១៣៧
២៦-គាថាចុងក្រោយ................................................................ ១៥៣
២៧-សេចក្ដីប្រាថ្នារបស់អ្នកនិពន្ធ............................................. ១៥៨